00816637

E1/85.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2012, 13:44

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅជំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០៦ នាទី**

**សវនាការលើកទី៧៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោកស្រី ណាតាចា វ៉ីស៊ែល រីស៊ឺ

*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្មី

លោក វ៉េង ហ៊ិត

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកធួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក សំ សុគង់

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោក គីម ម៉េងឃី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក អាកឡូរ វែកគែន | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្វាស្តើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី ទ្រី ស្រ៊ីនណា | ខ្មែរ |
| លោក សៅ សារុន (TCW-604) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សៅ សារុន** (TCW-604)

សួរបន្តដោយលោកស្រី ទី ស្រ៊ីនណា ផ្ដើមពី៖...................................ទំព័រ ៣

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វតផ្ដើមពី៖ ...................................ទំព័រ ២១

សួរបន្តដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្ដើមពី៖...................................ទំព័រ ៣៩

សួរដោយលោក ហ្សាស្ដេី ប៉ៅ ផ្ដើមពី៖ ...................................ទំព័រ ៥១

សួរដោយលោក អាកទួរវ៉េកគែន ផ្ដើមពី៖ ...................................ទំព័រ ៨២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះយើងបន្តស្ដាប់សក្ខីកម្មសាក្សី សៅ សារុន ដែលនឹងការតាំងសំណួរដេញដោលជាបន្តដោយមេធាវីទទួលសិទ្ធិ នៃមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ បូករួមទាំងសាក្សីបម្រុងផងប្រសិនបើមាន។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាននៅក្នុងបន្ទប់សវនាការលើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដោយឡែកសាក្សីបម្រុងសម្រាប់ថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម TCW-488 មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះសាលាដំបូងទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុង

បន្ទប់សវនាការនេះ ដោយគាត់សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាពមិនអាចអង្គុយតាមដានស្ដាប់កិច្ចដំណើរការសវនាការយូរបាន។

ហើយសំណើនេះ ក៏មានការគាំទ្រដោយអនុសាសន៍របស់វេជ្ជបណ្ឌិតទទួលបន្ទុកក្នុងការពិនិត្យព្យាបាលជនជាប់ចោទ ប្រចាំនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ដែរ ដែលបានឲ្យអនុសាសន៍ថា គាត់មិនអាចចូលរួមផ្ទាល់ក្នុងបន្ទប់សវនាការខាងលើបានឡើយ ប៉ុន្តែគាត់អាចចូលរួម និងបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមនេះបាន។

[០៩:១០:០៥]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី បានស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីរបស់គាត់បាន។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

ហើយបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី មានលទ្ធភាពអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់អំឡុងពេលដំណើរការសវនាការថ្ងៃនេះ។

ហើយជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិពីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[០៩:១១:២៥]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ជាដំបូង សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និង

អង្គសវនាការទាំងមូលសាជាថ្មី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ជម្រាបសួរលោក សារុន។ កាលពីម្សិលមិញ ខ្ញុំបានសួរលោកដល់ដំណាក់កាល លោកឡើងកាន់តំណែងជាលេខាតំបន់១០៥ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំសូមសួរលោកបកក្រោយបន្តិចវិញ ទៅដំណាក់កាលដែល តាឡាំង កាន់អំណាចវិញ។ ម្សិលមិញលោកបានលើកឡើងថា មន្ទីរតំបន់ គឺជាមន្ទីរ១៧។ សួរថាតើកាលសម័យនោះ មន្ទីរតំបន់នេះទទួលខុសត្រូវលើការងារអ្វីដែរ? សូមលោកជួយជម្រាបជូនអង្គសវនាការ?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំ មន្ទីរតំបន់ហ្នឹង គឺគេ ខ្ញុំមិនសូវយល់ដែរ ពីព្រោះខ្ញុំនៅខាងស្រុក អត់សូវយល់ទេ អត់យល់ទេ និយាយមួយម៉ាត់ទៅ គឺអត់យល់បាទ។

**ស៖** ខ្ញុំសូមធ្វើការបន្តសំណួរទៀត។ តើលោកធ្លាប់ដែលដឹងឬទេ ថាតើតំបន់១០៥ទាំងមូលហ្នឹង មានមន្ទីរចំនួនប៉ុន្មានដែរកាលពីសម័យតាឡាំង កាន់អំណាចនោះ?

**ឆ៖** បាទ តាមដឹងហ្នឹង គឺមានមន្ទីរបី បួន និងខាងពាណិជ្ជកម្មបាទ។ ទាំងអស់ហ្នឹងមានបួន។

[០៩:១៣:២៣]

**ស៖** តើលោកអាចជួយរៀបរាប់ឈ្មោះមន្ទីរទាំងបួននោះ ជូនអង្គសវនាការបានឬទេ?

**ឆ៖** បាទ អាចរៀបរាប់បាន គឺទីមួយ ក-១៧, ទីពីរ ក-១១, ទីបី ក-១៦, ទីបួនហ្នឹងគឺខាង ខ្ញុំអត់ដឹងលេខទេ គឺខាងពាណិជ្ជ ខាងពាណិជ្ជកម្ម ខាងនៅតំបន់។

**ស៖** ចុះអំឡុងពេលនុ៎ង លោកធ្លាប់ដឹងថា តើមានសមាសភាពដឹកនាំទៅលើថ្នាក់មន្ទីរហ្នឹង គាត់មានសមាសភាពណាដែរ លោកស្គាល់បុគ្គលហ្នឹងដែរ ឬយ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ ពីព្រោះខ្ញុំធ្វើការនៅស្រុក អត់ស្គាល់សមាសភាពហ្នឹង។

**ស៖** ចុះទាក់ទងទៅនឹងការគ្រប់គ្រងមន្ទីរវិញ តើគេគ្រប់គ្រងដោយរបៀបណា ដូចជាឧទាហរណ៍ថា ដូចជាមានប្រធាន អនុប្រធាន ហើយនិងមានសមាជិកប៉ុន្មាននៅក្នុងមន្ទីរនីមួយៗ លោកធ្លាប់ដឹងពីបញ្ហាហ្នឹងឬទេ?

**ឆ៖** បាទ អត់ដឹងទេបាទ។

[០៩:១៥:១៧]

**ស៖** ចុះទាក់ទងទៅនឹងស្រុកនីមួយៗ កន្លងមកលោកបានជម្រាបជូនទៅអង្គសវនាការថា មានបែងចែកចេញជាស្រុក ហើយនៅក្នុងស្រុកនីមួយៗហ្នឹង ខ្ញុំចង់សួរលោក ថាតើមានការបែងចែកចេញជាមន្ទីរ ដូចជាថ្នាក់តំបន់ដែរ ឬក៏យ៉ាងម៉េចដែរលោក? ហើយចំពោះថ្នាក់ឃុំវិញ ក៏មានការបែងចែកដូចគ្នា ឬក៏អត់?

**ឆ៖** បាទ អត់មានទេ មានតែមន្ទីរកន្លែងស្រុកតែមួយកន្លែង ឃុំមួយកន្លែងតែប៉ុណ្ណឹង។ អត់មានបែងចែកជាច្រើនមន្ទីរទេ បាទ។

[០៩:១៦:០៥]

**ស៖** ចុះលោកធ្លាប់ដែលឮពាក្យថា មន្ទីរសន្តិសុខភ្នំក្រោល ឬទេ?

**ឆ៖** បាទ ឮ ប៉ុន្តែខ្ញុំមិនដែលចូលសោះ។

**ស៖** តើលោកមានបានដឹងថា មន្ទីរសន្តិសុខភ្នំក្រោលហ្នឹង បង្កើតឡើងនៅក្នុងឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ ដឹងគេបង្កើតឆ្នាំណា អត់ចាំទេ បាទ។

**ស៖** តើមន្ទីរសន្តិសុខភ្នំក្រោលនេះ គេបង្កើតសម្រាប់ធ្វើអ្វីដែរ លោកដឹងដែរឬទេ?

**ឆ៖** បាទ អត់ដឹងទេ ដឹងគេសម្រាប់ធ្វើអី អត់ដឹងដែរ។ ខ្ញុំនៅស្រុកអត់ដឹង កិច្ចការក្នុងតំបន់នោះ។

**ស៖** តើមន្ទីរសន្តិសុខភ្នំក្រោលនេះ មានចម្ងាយប៉ុន្មានពីមន្ទីរតំបន់ ឬក៏មន្ទីរក-១៧ នោះ។

**ឆ៖** តាមដឹង គឺអត់ឆ្ងាយប៉ុន្មានទេ ប្រហែលជាជាងមួយ១០០ម៉ែត្រ។

[០៩:១៧:៤២]

**ស៖** តើមន្ទីរសន្តិសុខនេះ មានទ្រង់ទ្រាយយ៉ាងម៉េចដែរ? ឧទាហរណ៍ដូចជាមានរបងព័ទ្ធជុំវិញមន្ទីរ ឬក៏មានស្ថានភាពយ៉ាងម៉េច លោកអាចជម្រាបជូនអង្គសវនាការបានឬទេ?

**ឆ៖** បាទ អត់ដឹងទេ ពីព្រោះអត់បានចូល។ មិនដែលចូលសោះ ដឹងជារបង ឬអត់ អត់ដឹង។

**ស៖** តើលោកធ្លាប់បានដឹង ឬក៏ធ្លាប់ឮគេនិយាយអំពីមន្ទីរនេះ ថាតើមានមនុស្សជាប់នៅក្នុងមន្ទីរហ្នឹងដែរឬទេ?

**ឆ៖** បាទ អត់ដឹងទេ។ នៅស្រុក ខ្ញុំមិនដែលចូល មិនដែលអី អត់ដឹងសោះ បញ្ហាហ្នឹង។

**ស៖** ដោយសារតែលោកអត់ដឹង អ៊ីចឹងខ្ញុំសូមលើកនូវឯកសារមួយ ដែលលោកធ្លាប់ឆ្លើយ

ជាមួយនឹងខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីជាជំនួយដល់ការ ដល់រំឭក នឹកឃើញរបស់លោក។ អ៊ីចឹង សូមអាននូវលេខឯកសារដែលខ្ញុំមានបំណងប្រើប្រាស់នៅពេលនេះ គឺឯកសារដែលមានលេខ E3/383 ឬក៏ឯកសារលេខ D201/5 ដែលៗ--

[០៩:១៩:២៥]

**លោកស្រី ទី ស្រ៊ុនណា៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធាន តើខ្ញុំអាចលើកនូវ-- អាននូវឯកសារនេះ ជូនទៅសាក្សី ដើម្បីជាការរំឭកដល់គាត់បានឬទេ?

**ប្រធានអង្គជំនុំ៖**

អាចបាន ហើយឲ្យបុគ្គលិកផ្នែក បុគ្គលិកជំនួយការ បង្ហាញឯកសារនេះ នៅលើអេក្រង់ទូរទស្សន៍ និងអេក្រង់កុំព្យូទ័រ! ដើម្បីឲ្យភាគ និងសាធារណជនបានដឹងផង។

**លោកស្រី ទី ស្រ៊ុនណា៖**

ខ្ញុំសូមជម្រាបជូនលោកប្រធាន ដោយសារតែម៉ោងពេលវេលារបស់ខាងក្រុមខ្ញុំខ្លី។ អ៊ីចឹង ខ្ញុំសូមគ្រាន់តែអានជូនទៅសាក្សី ដើម្បីចៀសវាង-- អ៎! ដើម្បីសន្សំពេលវេលា។ ដូច្នេះសូមអនុញ្ញាតលោកប្រធានសុំត្រឹមតែធ្វើការអានជូនសាក្សីដើម្បីគាត់បាននឹកឃើញឡើងវិញ។

[០៩:២០:១៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ហើយប្រាប់លេខ ERN ឯកសារផង!

**លោកស្រី ទី ស្រ៊ុនណា៖**

ERN ជាភាសាខ្មែរមានលេខ 00345915, ជាភាសាអង់គ្លេសដែលមានលេខ 0035266, លេខ ERN ជាភាសាបារាំងមានលេខ 00361765។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** កាលនោះមានសំណួរ គេសួរលោកថា៖ “អ៊ីចឹង លោកមានដែលបញ្ជូនមនុស្សទៅក្នុងមន្ទីរសន្តិសុខផ្សេងៗនៅក្នុងតំបន់ឬទេ? លោកឆ្លើយថា៖ នៅក្នុងពេលខ្ញុំជាគណៈតំបន់គ្មានទេ មានតែដោះលែង”។ អ៊ីចឹង តើលោកទទួលស្គាល់នូវចម្លើយនេះដែរឬទេ?

[០៩:២១:២៥]

**លោក សៅ សារុន៖**

**ឆ៖** បាទ បានទទួលស្គាល់ គឺបាន-- រឿងចាប់ចូល អត់មាន គឺមានតែដោះលែងបាទ។

**ស៖** ពេលហ្នឹងសំណួររបស់គេសួរថា មន្ទីរសន្តិសុខផ្សេងៗ ខ្ញុំសូមឲ្យលោកបញ្ជាក់ថាតើមន្ទីរសន្តិសុខដែលលោកថាមានការដោះលែងហ្នឹង លោកសំដៅទៅលើមន្ទីរសន្តិសុខណាមួយ?

**ឆ៖** មានតែមន្ទីរសន្តិសុខនៅតំបន់តែមួយហ្នឹងបាទ។

**ស៖** តើមន្ទីរសន្តិសុខនៅតំបន់ហ្នឹងមានឈ្មោះអ្វីដែរ? លោកអាចជម្រាបជូនអង្គសវនាការបានឬទេ?

**ឆ៖** បាទ បញ្ហាហ្នឹងគឺខ្ញុំអត់យល់ទេ ដឹងលេខអីៗអត់យល់។ ឮថាតែមន្ទីរសន្តិសុខតំបន់ ដឹងតែប៉ុណ្ណឹងបាទ។

[០៩:២២:៣៣]

**ស៖** តើមន្ទីរសន្តិសុខតំបន់ដែលលោកលើកហ្នឹង តើមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** នៅទីតាំងជិតមន្ទីរតំបន់ហ្នឹងដែរបាទ ប្រហែលជាដូចខ្ញុំជម្រាបជូនលោកថ្ងៃមុនហ្នឹង គឺសហ-- ឆ្ងាយប្រហែលជាជាង១០០ម៉ែត្រហ្នឹង។

**ស៖** តើនរណាជាអ្នកគ្រប់គ្រងមន្ទីរនោះដែរ?

**ឆ៖** បាទ កាលមុនគឺ សុភា។

[០៩:២៣:២៧]

**ស៖** តើមន្ទីរសន្តិសុខតំបន់ដែលមានចម្ងាយប្រហែល១០០ម៉ែត្រ ដែលលោកបានលើកអម្បាញ់មិញនេះ និងមន្ទីរសន្តិសុខភ្នំក្រោលហ្នឹង ជាមន្ទីរតែមួយ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ សូមបញ្ជាក់ម្តងទៀត ដូចអត់ច្បាស់។

**ស៖** លោកបានលើកឡើងពីខាងដើម នៅពេលដែលខ្ញុំសួរលោកថា មន្ទីរសន្តិសុខភ្នំក្រោលមានចម្ងាយ១០០ម៉ែត្រ ប្រហែលជា១០០ម៉ែត្រពីមន្ទីរតំបន់ ហើយបន្ទាប់មកទៀតលោកក៏បាន-- ខ្ញុំក៏សួរថាតើមានមន្ទីរអីផ្សេងទៀតអត់? លោកថាមានមន្ទីរសន្តិសុខតំបន់។ មន្ទីរសន្តិសុខតំបន់ហ្នឹង លោកថាលោកអត់ស្គាល់ឈ្មោះទេ។ ហើយខ្ញុំក៏ចង់សួរលោកថា តើមន្ទីរសន្តិសុខតំបន់ និងមន្ទីរសន្តិសុខភ្នំក្រោលហ្នឹងជាមន្ទីរសន្តិសុខតែមួយ ឬក៏ជាមន្ទីរពីរដាច់ដោយឡែកពីគ្នា?

[០៩:២៤:៤២]

**ឆ៖** បាទ ដាច់ពីគ្នា មន្ទីរដាច់ពីគ្នាបាទ។

**ស៖** តើលោកអាចចាំបានឬទេ កាលនុ៎ងលោកបានលើកឡើងថា លោកបានដោះលែងមនុស្ស ដែលនៅជាប់ក្នុងមន្ទីរសន្តិសុខតំបន់។ សួរថាតើមនុស្សដែលលោកដោះលែងហ្នឹងមានចំនួនប៉ុន្មាននាក់ ដែរ?

**ឆ៖** បាទ ច្រើននាក់ដែរ ខ្ញុំភ្លេច វាយូរហើយ ភ្លេចការចងចាំហើយវាយូរហើយ។

**ស៖** តើលោកមានការដោះលែងចំនួនប៉ុន្មានដងដែរ?

**ឆ៖** ចំនួនពីរដង។

**ស៖** អ៊ីចឹងខ្ញុំសូមធ្វើការបន្តទៀតថាទៅនឹងសំណួរមួយទៀតនៅក្នុងឯកសារដដែល ទំព័រ ERN ដដែល។ សំណួរបន្តសួរថា៖ "តើនៅពេលលោកដោះលែងអ្នកទោសចាស់ៗ លោកមានសុំយោបល់ទៅ មជ្ឈិមជាមុន ឬទេ? លោកឆ្លើយថា៖ មិនដែលទេ នេះជាសិទ្ធិអំណាចរបស់ខ្ញុំ"។ សំណួររបស់ខ្ញុំចង់សួរ ថា តើមូលហេតុអ្វីបានជាលោកប៊ានដោះលែងអ្នកទោសចាស់ៗនោះ?

[០៩:២៦:៥៦]

**ឆ៖** បាទ បានខ្ញុំប៊ានលែង គឺសាកសួរទៅវាអត់មានបញ្ហាពាក់ព័ន្ធអី មានតែបញ្ហាឈ្លោះ ប្រកែកគ្នាប្ដីប្រពន្ធ ទំនាស់គ្នាបន្តិចបន្តួច។ អ៊ីចឹង បានខ្ញុំលែងហើយ បានខ្ញុំរាយការណ៍ទៅលើវិញបាទ។

**ស៖** ខ្ញុំសូមសួរបន្តទៀត តើការដែលលោកដោះលែងអ្នកទោសចាស់ៗនេះ គឺលោកអនុវត្តនៅ ពេលដែលលោកទទួលគោលការណ៍ណែនាំអំពីគោលនយោបាយថ្មីរបស់បក្ស ដែលខាងសហព្រះរាជ អាជ្ញាបានលើកជូនលោក បង្ហាញលោកនូវឯកសារកាលពីម្សិលមិញហ្នឹង តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ បានទទួលសេចក្ដីណែនាំហើយ គឺលែង។ សួរទៅវាអត់មានការពាក់ព័ន្ធ អី គឺខ្ញុំលែង។

**ស៖** សូមអរគុណ។ ខ្ញុំសូមធ្វើការបន្តសំណួរម្ដងទៀត នៅថ្ងៃទី០៦ ខែ៦ ២០១២ កាលសប្ដាហ៍ មុន លោកបានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាថា "លោកដឹងថា មានមន្ទីរអប់រំកែប្រែនៅ តំបន់"។ តើមន្ទីរអប់រំកែប្រែនៅទីនេះហ្នឹង តើលោកសំដៅទៅលើមន្ទីរអប់-- មន្ទីរសន្តិសុខរបស់តំបន់ ហ្នឹង ឬក៏យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ មន្ទីរតែមួយហ្នឹង មន្ទីរកែប្រែ និងមន្ទីរសន្តិសុខហ្នឹងគេហៅតែមួយហ្នឹងទេបាទ។

[០៩:២៩:០០]

**ស៖** ខ្ញុំសូមបញ្ជាក់ចំណុចមួយទៀត មន្ទីរអប់រំកែប្រែ និងមន្ទីរសន្តិសុខហ្នឹងមានភាពខុសប្លែកគ្នា ឬក៏ខុសគ្នា?

**ឆ៖** បាទ ដូចខ្ញុំជម្រាបអំមិញ-- អម្បាញ់មិញ គឺមន្ទីរតែមួយ។

**ស៖** សូមអរគុណ។ តើលោកមានបានដឹងឬទេ ថាតើមនុស្សប្រភេទសណា ដែលគេយកទៅដាក់នៅក្នុងមន្ទីរអប់រំកែប្រែនោះ?

**ឆ៖** ដូចខ្ញុំជម្រាបខាងលើនោះហើយ ប្រភេទខ្លះទំនាស់ទាស់ទែងជាមួយប្តីប្រពន្ធ ឈ្លោះគ្នាបន្តិចបន្តួចទៅ អ៊ីចឹងគេក៏យកមក អ្នករាយការណ៍ទៅក៏វាពន្លើសទៅ ខ្លះទៅ អីខ្លះទៅ យកមក ដល់យើងមកសួរមានរឿងរ៉ាវអី មានរឿងក្រុមគ្រួសារគេតិចតួចទៅ ចេះតែយកគេមកឃុំឃាំងអីតែផ្តេសតែផ្តាសអ៊ីចឹង។

**ស៖** ចុះដែលមានមនុស្សក្បត់បដិវត្តន៍ គេយកទៅដាក់នៅក្នុងមន្ទីរនោះដែរឬទេ?

**ឆ៖** បញ្ហាហ្នឹង គឺខ្ញុំអត់ឮទេ ថាមនុស្សក្បត់បដិវត្តន៍អី ខ្ញុំអត់ឮ។

**ស៖** ចុះនៅក្នុងសម័យ ឡាំង គាត់កាន់កាប់ ខ្ញុំសូមសួរថាក្នុងករណីដែលមានការចោទប្រកាន់បុគ្គលណាម្នាក់ក្បត់បក្ស ឬក៏ក្បត់បដិវត្តន៍ តើនីតិវិធីគេត្រូវធ្វើដូចម្តេចចំពោះបុគ្គលនោះ?

[០៩:៣១:០៨]

**ឆ៖** បាទ ខ្ញុំអត់យល់ទេ សម័យគាត់-- អំ!ជំនាន់គាត់-- អំ! កាន់កាប់ការងារ ខ្ញុំអត់ដឹងទេ។ កិច្ចការក្នុងតំបន់ខ្ញុំអត់យល់ ខ្ញុំយល់តែការងារក្នុងក្របខ័ណ្ឌស្រុកខ្ញុំបាទ។

**ស៖** ចុះលោកដែលមានធ្លាប់ឮគេនិយាយអំពី បុគ្គលដែលក្បត់បដិវត្តន៍ហ្នឹងនៅក្នុងតំបន់លោកដែរឬទេ?

**ឆ៖** បាទ មិនដែលឮទេ។

**ស៖** ចុះពេលលោកចុះប្រជុំនៅទីក្រុងភ្នំពេញកន្លងមក តើគេមានដែលបង្រៀនលោកអំពី--បង្រៀន ឬក៏ពន្យល់លោកអំពីបុគ្គលក្បត់បដិវត្តន៍ ឬក៏ពន្យល់លោកអំពីថា តើធ្វើយ៉ាងម៉េចដើម្បីកំណត់ថា បុគ្គលណាមួយក្បត់បដិវត្តន៍ឬទេ?

**ឆ៖** បាទ ខ្ញុំអត់ឮទេ។

[០៩:៣២:៣៤]

**ស៖** ខ្ញុំសូមឲ្យលោកជួយបញ្ជាក់បន្ថែម អំពីរបៀបរបបនៅក្នុងការគ្រប់គ្រងរបស់ ឡាំង តើ

យ៉ាងម៉េចដែរ? លោកអាចជម្រាបជូនអង្គសវនាការបានឬទេ?

**ឆ៖** បាទ ខ្ញុំអត់យល់ទេ របៀបគ្រប់គ្រងគាត់យ៉ាងម៉េចៗ ខ្ញុំអត់យល់ទេ គឺខ្ញុំដឹងតែការងារក្នុងស្រុកដូចខ្ញុំជម្រាបខាងលើហ្នឹង។

**ស៖** ចុះទំនាក់ទំនងរបស់ ឡាំង ជាមួយនឹងថ្នាក់ស្រុកយ៉ាងម៉េចដែរ? ដូចជារូបលោក កាលហ្នឹងលោកកាន់ខាងលេខាស្រុក តើទំនាក់ទំនងគាត់ជាមួយនឹងលោក ដូចជាគាត់ជាមួយនឹងលេខាស្រុកផ្សេងៗ ដូចជាគាត់ជាមួយនឹងលេខាឃុំអី។ តើមានការទំនាក់ទំនង ដូចជាការហៅមកប្រជុំ ឬមួយក៏ជជែកអំពីដោះស្រាយទៅលើបញ្ហាអ្វីមួយនៅក្នុងតំបន់ដែរឬទេ?

[០៩:៣៣:៤១]

**ឆ៖** បាទ គឺបញ្ហាទំនាក់ទំនងមានតែដល់ខែគេហៅមកប្រជុំ គ្រប់ស្រុកក៏មកប្រជុំ ប៉ុណ្ណឹងបាទ។

**ស៖** តើពេលមកប្រជុំហ្នឹងមានដែលលើកពីបញ្ហាក្នុងតំបន់ យកមកធ្វើការដោះស្រាយក្នុងកិច្ចប្រជុំហ្នឹងដែរឬទេ?

**ឆ៖** បាទ ពេលប្រជុំហ្នឹង គឺមានបញ្ហាអី គឺបញ្ហាស្រែ បញ្ហាចម្ការ បញ្ហាទំនប់ប្រឡាយអី គឺលើកមកពិភាក្សាត្រូវធ្វើត្រង់ណា ធ្វើត្រង់ណា អាហ្នឹងគឺមានបាទ។

**ស៖** ពេលលើកទំនប់ ខ្ញុំសូមសួរលោកថា តើពេលនោះមានប្រជាជនក្នុងតំបន់ចំនួនប៉ុន្មាននាក់ដែលទៅធ្វើការលើកទំនប់នោះ?

[០៩:៣៤:៥៥]

**ឆ៖** បាទ មានចំនួនច្រើនដែរ ប៉ុន្តែជាកំណត់ថា ប៉ុណ្ណេះ ប៉ុណ្ណោះគឺខ្ញុំអត់ដឹងដែរ គឺគ្រាន់តែឃើញច្រើនថា ច្រើន*(ឮមិនច្បាស់)* ២០០, ៣០០នាក់មិនដឹង យើងស្មានៗទេ ខ្ញុំនិយាយនេះគឺស្មានទេ។ ច្រើនដែរ។

**ស៖** តើប្រជាជនដែលទៅលើកទំនប់នោះ គឺគេតម្រូវឲ្យប្រជាជនតែក្នុងស្រុកមួយ ឬក៏ប្រជាជនក្នុងតំបន់ទាំងមូលត្រូវមានកាតព្វកិច្ចក្នុងការទៅលើកទំនប់?

**ឆ៖** បាទ គឺមានតែប្រជាជន ស្រុកណា គឺស្រុកហ្នឹងលើកបាទ។

**ស៖** តើការងារលើកទំនប់នោះយ៉ាងម៉េចដែរ?

**ឆ៖** បាទ គឺលើក-- មានអីគឺការភ័យ-- លើកដាក់ៗតែប៉ុណ្ណឹងមានយ៉ាងណា។

**ស៖** តើមួយថ្ងៃប្រជាជនត្រូវទៅលើកទំនប់រយៈពេលប៉ុន្មានម៉ោងដែរ?

**ផ៖** បាទ ពេលស្រស់ស្រូបម៉ោងប្រាំមួយហើយ ម៉ោងប្រាំពីរចេញទៅធ្វើការ ម៉ោងដប់កន្លះគេឈប់សម្រាក។

[០៩:៣៦:៥៤]

**ស៖** ខ្ញុំសូមសួរលោកបន្តទៅទៀតទាក់ទងទៅនឹងការធ្វើស្រែ តើផលស្រូវដែលទទួលបានលោកបានលើកកាលពីម្សិលមិញក៏ដូចជាកាលពីសប្តាហ៍មុនថា ផលស្រូវដែលទទួល-- ធ្វើបានគឺសម្រាប់ផ្គត់ផ្គង់ជីវភាពប្រជាជនក្នុងតំបន់ ខ្ញុំសូមសួរថាតើមានផលស្រូវដែលនៅសេសសល់ពីការផ្គត់ផ្គង់ប្រជាជនដែរឬទេ?

**ផ៖** បាទ ផលស្រូវដែលបង្កបង្កើនផលបាន គឺគិតជារបបឲ្យប្រជាពលរដ្ឋហូបហ្នឹងគឺ ក្នុងមួយឆ្នាំ ៣០ប៉ោតទាំងតូចទាំងធំគឺ គិត៣០ប៉ោត ទាំងអស់។ លើកលែងតែបួនខែចុះអាហ្នឹងគេគិត១៥ប៉ោតបាទ។

[០៩:៣៧:៥១]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី សូមលោកស្រីចាប់អារម្មណ៍លើការតាំងសំណួរកុំឲ្យហួសក្រៅ-- ចេញក្រៅអង្គហេតុ។ នៅក្នុងដីកាដំណោះស្រាយអង្គហេតុចោទប្រកាន់ចំពោះជនជាប់ចោទនៅតំបន់មណ្ឌលគិរីឬក៏តំបន់១០៥ មានតែអង្គហេតុពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខភ្នំក្រោលប៉ុណ្ណោះ។ ពុំមានការចោទប្រកាន់ពាក់ព័ន្ធជាមួយនឹងការដ្ឋានទេ។ ការដ្ឋានការងារសហករណ៍គឺនៅតំបន់ផ្សេង ដូច្នេះក្របខ័ណ្ឌគឺសូមពិនិត្យធ្វើការដេញដោលក្នុងក្របខ័ណ្ឌអង្គហេតុ ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ ពិតណាស់ជន អឺ សាក្សីរូបនេះអង្គជំនុំជម្រះបានយល់ស្របតាមសំណើសុំរបស់ខាងសហព្រះរាជអាជ្ញាឲ្យមានការសួរដេញដោលនៅក្នុងក្របខ័ណ្ឌអង្គហេតុដែលមានការចោទប្រកាន់នៅក្នុងសំណុំរឿង០០២ទូលំទូលាយ ប៉ុន្តែពុំមែនឲ្យដេញដោលហួសពីក្របខ័ណ្ឌវិសាលភាពនៃអង្គហេតុដែលបានបង្ហាញនៅក្នុងដីកាដំណោះស្រាយទេ។

សូមរំឭកបញ្ជាក់ឡើងវិញថា ក្នុងដីកាដំណោះស្រាយដែលចោទប្រកាន់ដាក់បន្ទុកទៅលើជនជាប់ចោទ គឺមានតែមន្ទីរសន្តិសុខភ្នំក្រោលទេ។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធានដែលបានជួយរំឭក។

[០៩:៣៩:២៦]

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំសូមសួរលោកទាក់ទងទៅនឹងការបាត់ខ្លួន។ កាលពីសប្តាហ៍មុនលោកបានលើក និងបានឆ្លើយជូនសហព្រះរាជអាជ្ញាថា លោកបាន-- ខ្ញុំសូមធ្វើការរៀបចំសំណួរសាឡើងវិញ ទាក់ទងទៅនឹងកិច្ចប្រជុំ នៅពេលដែលលោកចូលរួមប្រជុំនៅក្នុងថ្នាក់តំបន់ម្តងៗ តើលោកដែលឃើញ ឬក៏ធ្លាប់ជួបប្រទះនៅក្នុងកិច្ចប្រជុំណាមួយ ដែលមានសមាជិកក្នុងកិច្ចប្រជុំធ្វើការតវ៉ា ហើយក្រោយមកមានការបាត់ខ្លួនដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ សំណួរនេះសូមអានម្តងទៀត ខ្ញុំអត់ច្បាស់ទេ។

**ស៖** ខ្ញុំសូមបញ្ជាក់សំណួរឡើងវិញ កាលពីសម័យ ឡាំង គាត់កាន់អំណាចនុ៎ង លោកធ្លាប់ចូលរួមនៅក្នុងកិច្ចប្រជុំតំបន់ជាច្រើនលើកច្រើនសា ខ្ញុំចង់សួរថា តើលោកមានបានកត់សម្គាល់នៅក្នុងកិច្ចប្រជុំណាមួយដែលមានសមាជិកក្នុងកិច្ចប្រជុំនោះធ្វើការតវ៉ា រួចហើយក្រោយមកមានការបាត់ខ្លួនដែរឬទេ?

**ឆ៖** ដូចអត់ឃើញមានពីណាបាត់ខ្លួនពេលហ្នឹង ពេលតវ៉ាហ្នឹង អត់ទេ។

**ស៖** សូមធ្វើការបន្តសំណួរ។ តើលោក ឡាំង ធ្វើការទំនាក់ទំនងជាមួយថ្នាក់លើ ដូចជាការរាយការណ៍ពីស្ថានភាពតំបន់ តើគាត់រាយការណ៍ទៅណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ ពីព្រោះគេខាងលេខា ប្រធានតំបន់ មិនដឹងគេរាយការណ៍ទៅខាងលើ ឬយ៉ាងម៉េចខ្ញុំអត់ដឹងទេ។ គេរាយការណ៍យ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេបាទ។

[០៩:៤២:២៩]

**លោកស្រី ទី ស្រ៊ីនណា៖**

ដើម្បីជំនួយដល់ការចងចាំរបស់លោក ខ្ញុំសូមអនុញ្ញាតលោកប្រធាន សូមអាននូវឯកសារដែលសាក្សីធ្លាប់ឆ្លើយជាមួយនឹងខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានលេខ E3/404 សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រផង។

**លោកស្រី ទី ស្រ៊ុនណា៖**

ខ្ញុំស្នើសុំលោកប្រធាន សុំធ្វើការអានជូនសាក្សី ដោយសារតែពេលវេលាខាងខ្ញុំ-- ដើម្បីសន្សំពេលវេលាខាងខ្ញុំនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញយើងអនុញ្ញាតហើយ!

[០៩:៤៣:២៧]

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** ឯកសារ E3/404 ដែលមានលេខ ERN ជាភាសាខ្មែរ 00398483, ភាសាអង់គ្លេស 00403027, ភាសាបារាំង 00484201។ សំណួរសួរថា៖ "តើលោកដឹងទេថា ពេល តាឡាំង កាន់អំណាចហ្នឹង គាត់រាយការណ៍ទៅណា? លោកឆ្លើយថា៖ គាត់រាយការណ៍ទៅ ប៉ុល ពត ដដែលហ្នឹងនេះបើតាមគាត់និយាយ"។ តើលោកនៅរក្សាចម្លើយនេះដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ហ្នឹងបានរាយការណ៍ឲ្យលោកសហាចៅក្រមម្តងហើយ បញ្ជាក់ហើយបាទ។ សូមអស់។

**ស៖** នៅពេលលោកឡើងកាន់តំណែងជំនួសលោក ឡាំង លោកប្រើវិធីសាស្ត្រតាមលោក ឬក៏លោកនៅក្នុងការរាយការណ៍ទៅ ប៉ុល ពត ឬក៏លោកមានការណែនាំពីថ្នាក់លើអំពីការរាយការណ៍នេះ?

[០៩:៤៥:០៣]

**ឆ៖** បាទ ខ្ញុំ សំណួរហ្នឹង សូមអានម្តងទៀតបាទ សូមអានយឺតៗបន្តិច។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ថា វិធីសាស្ត្រ នៅពេលដែលលោកឡើងកាន់តំណែងជាលេខាតំបន់ ១០៥ លោកធ្វើការរាយការណ៍ទៅ ប៉ុល ពត តើលោកប្រើវិធីសាស្ត្រតាម តាឡាំង ឬក៏មានការណែនាំពីថ្នាក់លើឲ្យធ្វើការរាយការណ៍ទៅ ប៉ុល ពត?

**ឆ៖** បាទ ខ្ញុំឡើងមកកាន់តួនាទីជំនួស ឡាំង គឺខ្ញុំរាយការណ៍ទៅ ប៉ុល ពត បាទ។ ពីព្រោះគេក៏ណែនាំថា មានការងារអី គឺរាយការណ៍ទៅគាត់បាទ។

**ស៖** ខ្ញុំសូមសួរបន្តទៀត ទាក់ទងទៅនឹងសិទ្ធិ និងអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យទាំងមូលនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ តើសិទ្ធិ និងអំណាចរបស់បក្សនៅពេលនោះយ៉ាង

ម៉េចដែរ? លោកអាចជម្រាបជូនអង្គសវនាការបានឬទេ?

**ឆ៖** បាទ ខ្ញុំអត់យល់ទេ សិទ្ធិអំណាចត្រឹមណាៗ ខ្ញុំអត់យល់បាទ។ អាហ្នឹងជាការងាររបស់ខាងលើ ខ្ញុំអត់យល់បាទ។

[០៩:៤៦:៤០]

**ស៖** ចុះលោកមានដែល ពេលដែលលោកចុះទៅប្រជុំនៅភ្នំពេញកន្លងមក កាលពីក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើលោកមានបានដឹងថា តើបុគ្គលណាខ្លះ ជាបុគ្គលសំខាន់នៅក្នុងជួរបក្សដែរឬទេ? ជួរបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ខ្ញុំអត់ដឹងជនណាមានតួនាទីសំខាន់ជាងអ្នកណាទេ ខ្ញុំអត់យល់ទេបាទ។

**ស៖** ទាក់ទងទៅនឹងការទំនាក់ទំនងដោយផ្ទាល់ពីថ្នាក់លើ ឬគណៈអចិន្ត្រៃយ៍ ខ្ញុំសូមសួរលោកថា តើតំបន់១០៥នេះ បុគ្គលិក ឬក៏សមាជិកថ្នាក់ណាដែលមានសិទ្ធិទទួលការទំនាក់ទំនងដោយផ្ទាល់ពីគណៈអចិន្ត្រៃយ៍?

**ឆ៖** បាទ សូមអានបញ្ជាក់ម្តងទៀត អត់យល់ទេសំណួរនេះ។

**ស៖** ខ្ញុំសូមបញ្ជាក់សំណួរឡើងវិញ និងរៀបរយសំណួរឡើងវិញ។ ខ្ញុំសូមសួរថា តើសមាជិកថ្នាក់តំបន់នៅក្នុងខេត្តមណ្ឌលគិរីហ្នឹងដែលមានតួនាទីកម្រិតណា ទើបបានគណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍ធ្វើការទំនាក់ទំនងដោយផ្ទាល់?

**ឆ៖** ដូចអត់មានទេ មានទំនាក់ទំនងមានតែប្រធានតំបន់ តែប៉ុណ្ណឹងបាទ។

[០៩:៤៨:៥៧]

**ស៖** សូមអរគុណ។ ខ្ញុំសូមធ្វើការបន្តសំណួរ ទាក់ទងទៅនឹងសិទ្ធិនៅក្នុងការសម្រេចដក ឬក៏ជ្រើសតាំងចាប់ពីប្រធានតំបន់ ប្រធានកងពល កងពលទាំងវរសេនាតូច វរសេនាធំ តើនរណាជាអ្នកមានសិទ្ធិនៅក្នុងសម្រេចដក ឬក៏ជ្រើសតាំង?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ខ្ញុំអត់ដឹងទេ ដឹងពីណាមានសិទ្ធិចាត់តាំង អាហ្នឹងដឹងថាខាងលើ។ ដកហ្នឹង ខ្ញុំអត់យល់ មិនដឹងពីណា វាមិនឃើញដកពីណាហ្នឹង បាទ។

**ស៖** តើពាក្យខាងលើដែលលោកសំដៅលើហ្នឹង តើលោកសំដៅលើនរណាដែរ?

[០៩:៤៩:៥៧]

**ឆ៖** បាទ គឺសំដៅលើ ប៉ុល ពត ពីព្រោះគាត់ទទួលខុសត្រូវរួមទូទាំងប្រទេសបាទ។

**ស៖** ខ្ញុំសូមឈានដល់សំណួរការរៀបការដោយបង្ខំ។ ក្នុងសម័យ ឡាំង តើលោកមានបានដឹងអំពីការរៀបការរបស់ប្រជាជននៅក្នុងតំបន់ ឬក៏សហករណ៍នោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ! សំណួរច្រំដែល សំណួរហ្នឹង។ តំណាងសហព្រះរាជអាជ្ញាបានសួរសព្វគ្រប់ហើយ បញ្ហារៀបអាពាហ៍ពិពាហ៍។

**លោកស្រី ទី ស្រ៊ីនណា៖**

លោកប្រធាន កាលដែលសាក្សីឆ្លើយកាលពីលើកមុន គឺគាត់ឆ្លើយទាក់ទងនៅក្នុងដំណាក់កាលដែលគាត់កាន់កាប់។ ឯចំណែករបស់ខ្ញុំសុំសួរនៅក្នុងដំណាក់កាលដែល តាឡាំង កាន់កាប់ ហើយនិងមានសំណួរនេះ-- គ្រាន់តែជាការបញ្ជាក់ជាមុន ហើយយើងនឹងមានសំណួរបន្ទាប់ទៀត ដែលសំណួរនុំងមានកល្ខណៈខុសប្លែកពីសំណួររបស់ខាងសហព្រះរាជអាជ្ញា ហើយខ្លឹមសារក៏មានលក្ខណៈខុសគ្នាដែរ។ សូមអនុញ្ញាតលោកប្រធាន។

[០៩:៥១:០៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតទេ!

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំសូមធ្វើការបន្តសំណួរ កាលពីថ្ងៃទី០៦ ខែ៦ ឆ្នាំ២០១២ សប្ដាហ៍មុន លោកបានបញ្ជាក់ជូនលោកអគ្គសហព្រះរាជអាជ្ញា ថាបើមានការស្នើសុំពីសាមីខ្លួន មេពួក មេកង ត្រូវសួរបញ្ជាក់ទៅសាមីខ្លួនជាមុនថា តើយល់ព្រម ឬអត់? ក្រោយពីការបញ្ជាក់ហើយ បើយល់ព្រម ឬឯកភាព មេក្រុមមេកងរបស់គេ ត្រូវរាយការណ៍ទៅថ្នាក់លើរបស់គេ ហើយត្រូវជូនដំណឹងទៅឪពុកម្ដាយរបស់គេឲ្យមកចូលរួមពិធីការនោះបាន។ សំណួររបស់ខ្ញុំសួរថា តើលោកចាំឬទេ បើមានអ្នកមិនព្រមរៀបការ តើនឹងមានអ្វីកើតឡើងចំពោះអ្នកដែលប្រកែកមិនព្រមរៀបការនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនឆ្លើយទេ! ជាឧបមាណវិធីក្នុងការតាំងសំណួរ។ ការសួរដេញដោលនៅក្នុងអង្គជំនុំជម្រះមិនអាចប្រើពាក្យថា ប្រសិនបើ ឬក៏ជាឧបមាថា នោះបានទេ។ មិនអាចតាំងសំណួរឧបមាណវិធីទេ សូមលោកស្រីសួរសំណួរជាក់លាក់អំពីបញ្ហានេះ។

[០៩:៥២:៥០]

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** តើនៅក្នុងសម័យនោះ មានដែលមានអ្នកបដិសេធមិនព្រមរៀបអាពាហ៍ពិពាហ៍ ហើយនិងមានអ្វីកើតឡើងចំពោះបុគ្គលនោះបាទ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំបានបញ្ជាក់ជាមួយលោកសហចៅក្រម និងព្រះរាជអាជ្ញារួចហើយ។ យើងអត់មានសិទ្ធិទៅបង្ខំគេទេ។ សាមីខ្លួនគេស្រឡាញ់ អើ! សួរឯកភាពឪពុកម្ដាយគេហ្នឹង។ ដូចខ្ញុំបានជម្រាបហើយបាទ។

**ស៖** ខ្ញុំសូមសួរធ្វើការបកទៅរចនាសម្ព័ន្ធរបស់សហករណ៍។ កាលពីសប្ដាហ៍មុន លោកបានជម្រាបជូនសហព្រះរាជអាជ្ញាថា នៅសហករណ៍គេមានគណៈកម្មការរបស់គេទទួលខុសត្រូវរៀងៗខ្លួន ដូចជារៀបចំចាត់ចែងការងារផ្សេងៗ តើលោកអាចបញ្ជាក់ឲ្យកាន់តែច្បាស់ជាងនេះទេ ថាតើគណៈកម្មការដែលលោកថានោះ មានសមាសភាពអ្នកណាខ្លះ?

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ ដូចខ្ញុំជម្រាបព្រះរាជអាជ្ញារួចស្រេចហើយបាទ។

**ស៖** តើគេមានការធ្វើបែងចែកតួនាទីឬទេ?

[០៩:៥៤:៥៨]

**ឆ៖** បាទ មានការបែងចែកតួនាទី អ្នកខ្លះក្នុងគណៈសហករណ៍គេទទួលខាងសេដ្ឋកិច្ច អ្នកខ្លះទទួលខាង-- និងខាងអី ខាងរកម្ហូបអាហារអីគេ នៅក្នុងខាងសេដ្ឋកិច្ចនេះឯងបាទ។ មានបែងចែកអ៊ីចឹងបាទ។

**ស៖** កាលពីម្សិលមិញលោកបានឆ្លើយថា មានយោធាតំបន់ដែរនៅសម័យនោះ តើតំបន់១០៥ មានកងកម្លាំងយោធាចំនួនប៉ុន្មានប្រភេទទៅ?

**ឆ៖** បាទ សូមឆ្លើយ មានតែប្រភេទតែមួយ គេហៅថា “យោធាតំបន់” បាទ។

**ស៖** តើមានយោធាខាងមជ្ឈិមចុះទៅឈរជើងនៅទីនោះឬទេ?

**ឆ៖** បាទ មាន មួយកងពល។

**ស៖** តើទំនាក់ទំនងរវាងយោធាតំបន់ និងយោធាមជ្ឈិមដែលឈរជើងនោះយ៉ាងម៉េចដែរ?

[០៩:៥៧:០៧]

**ឆ៖** បាទ តាមការយល់របស់ខ្ញុំគឺគ្នាមកពីឆ្ងាយ អត់យល់ភូមិសាស្ត្រ គឺទំនាក់ទំនងខាងយោធាតំបន់ ពីព្រោះគេរស់នៅក្នុងមណ្ឌលគិរី ហើយគេដឹងភូមិសាស្ត្រទឹកត្រង់ណា អូរត្រង់ណា ត្រពាំងត្រង់ណា។ បើមិនទំនាក់ទំនងគ្នាអត់យល់ អ្នកមកពីឆ្ងាយ។ បាទ សូមអស់។

**ស៖** តើការរាយការណ៍របស់ខាងយោធានុំង គេធ្វើដូចម្តេច? គេរាយការណ៍ទៅតំបន់តែមួយ ឬក៏មានការរាយការណ៍ទៅថ្នាក់លើ?

**ឆ៖** បាទ ដូចខ្ញុំជម្រាប លោកព្រះរាជអាជ្ញាហើយ គឺរាយការណ៍វាតំបន់រាយការណ៍មកតំបន់ខាងកងពល គេរាយការណ៍ទៅខាងមជ្ឈិមបាទ។

**ស៖** ចុះលោកដែលធ្លាប់មានឮពាក្យថា "មេកងពល" ឬទេ? ហើយតើពាក្យ "មេកងពល" គេអាចហៅថាអ្វីខ្លះទៅ? ដូចជាឧទាហរណ៍ ដូចជាប្រធានកងពល លេខាកងពល ឬក៏គណៈកងពល តើមានពាក្យតែមួយ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ដូចជម្រាបហើយ គឺតែមួយទេ។

**ស៖** តើសមាសភាពដឹកនាំកងពលនោះ នីមួយៗហ្នឹងមាននរណាខ្លះទៅ?

[០៩:៥៨:៥២]

**ឆ៖** នេះ ខ្ញុំអត់យល់ទេ។ បាទ ខ្ញុំជម្រាបត្រង់អ៊ីចឹង អត់យល់ក្នុងកងពលគេ។

**ស៖** តើលោកឆ្លងកាត់តាមការពិសោធន៍របស់លោកដែលធ្លាប់រស់នៅតំបន់នោះ ខ្ញុំចង់សួរលោកថា តើកងពល មួយកងពលមានយោធាចំនួនប៉ុន្មាននាក់ដែរ? និងមានឋានានុក្រមយ៉ាងម៉េចទៅ? លោកអាចជម្រាបជូនសវនាការផងបាន?

**ឆ៖** បាទ ខ្ញុំអត់យល់ទេ ក្តាប់ចំនួនប៉ុន្មាន ខ្ញុំអត់យល់។

**លោកស្រី ទី ស្រ៊ុនណា៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធានធ្វើការបញ្ចាក់ទៅលើឯកសារដែលមានលេខ E3/367។

[១០:០០:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមានបំណងនិយាយត្រង់ណា? អីត្រង់ណា? ឲ្យច្បាស់លាស់ ឲ្យហើយមក អត្តសញ្ញាណឯកសារ លេខ ERN ហើយមានបំណងចង់ធ្វើអី ដើម្បីអង្គជំនុំជម្រះសម្រេចតែម្តង ឬចង់មួយម៉ាត់សម្រេចៗ គ្រាន់តែស្នើសុំសួរមួយសំណួរហ្នឹងត្រូវសម្រេចបីបួនដងទៅ ឬយ៉ាងម៉េច?

**លោកស្រី ទី ស្រ៊ុនណា៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធានធ្វើការបញ្ជាក់ទៅលើខ្លឹមសារមួយនៅក្នុងឯកសារ E3/367 ដែលមានលេខ ERN 00251440 ជាភាសាខ្មែរ និង 00278697 ជាភាសាអង់គ្លេស ហើយនិងភាសាបារាំង 00486012។

[១០:០១:១២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ!

**លោកស្រី ទី ស្រ៊ុនណា៖**

ខ្ញុំសូមលើកយកចំណុចតែម្តង។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** លោកបានឆ្លើយជាមួយនឹងសំណួរ "តើលោកស្គាល់អ្នកណាខ្លះទៀត?" នៅក្នុងនុំងសំណួរ-- ចម្លើយរបស់លោកមានការវែង ប៉ុន្តែខ្ញុំសូមចាប់យកចំណុចមួយដែលលោកឆ្លើយថា៖ "ក្នុងពេលសន្និបាតនោះ ប៉ុល ពត ក៏បានប្រកាសដែរថា ឲ្យកម្មាភិបាលទាំងយោធា ទាំងតំបន់-- អ៎! ទាំងយោធា ទាំងស៊ីវិល បញ្ឈប់ការសម្លាប់ និងចាប់ខ្លួន លុះត្រាតែមានដីកាកោះពីតុលាការមជ្ឈិមជាមុនសិន"។ សំណួររបស់ខ្ញុំចង់សួរថា តើនៅក្នុងសម័យនោះ តើមានហេតុការណ៍អ្វីកើតឡើងដែរបានជាប៉ុល ពត គាត់ធ្វើការប្រកាសទៅលើចំណុចនេះ?

**ឆ៖** បាទ ដូចខ្ញុំជម្រាបទៅព្រះរាជអាជ្ញារួចហើយ បញ្ជាក់រួចច្បាស់លាស់ហើយបាទ។

**ស៖** ខ្ញុំសូមលើកម្តងទៀតដើម្បីឲ្យលោកយល់នូវសំណួររបស់ខ្ញុំ ប្រហែលជាការសួរមិនមានលក្ខណៈសុក្រឹត។ ខ្ញុំសូមសួរលោកថា តើមានហេតុការណ៍អ្វីកើតឡើងមុន-- បានជា ប៉ុល ពត ធ្វើការប្រកាសឲ្យកម្មាភិបាល យោធា ទាំងស៊ីវិល បញ្ឈប់ការសម្លាប់ និងចាប់ខ្លួន លុះត្រាតែមានដីកាពីមជ្ឈិម? តើលោកអាច-- តើលោកធ្លាប់ដឹងពីហេតុការណ៍អីកើតឡើងពីជំនាន់ហ្នឹងដែរឬទេ?

[១០:០៣:២៣]

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។ ឮតែប្រកាសថា អត់ឲ្យមានចាប់ អត់ឲ្យមានចងប្រជាពលរដ្ឋអាហ្នឹង។ គាត់ប្រកាសច្បាស់ អាហ្នឹង ខ្ញុំឮច្បាស់។ ចាប់ចង ឬក៏ធ្វើយ៉ាងម៉េច មានការខុសត្រូវក្នុងប្រជាពលរដ្ឋគឺមានតែអប់រំ មិនឲ្យចាប់មិនចងដាច់ខាតបាទ។ អានេះ ខ្ញុំយល់អ៊ីចឹង។

**ស៖** ចុះនៅតំបន់ផ្សេងយ៉ាងម៉េចដែរលោក?

**ឆ៖** តំបន់ផ្សេង ខ្ញុំអត់យល់។

**ស៖** ខ្ញុំសូមធ្វើការបញ្ជាក់ទៅនឹងចំណុចបន្តទៀត ទាក់ទងទៅនឹងសំណួរសួរថា៖ "តើលោកដឹងអ្វីខ្លះការងារយោធា និងការគ្រប់គ្រងសន្តិសុខនៅក្នុងតំបន់? លោកឆ្លើយថា៖ គណៈតំបន់ជាអ្នកគ្រប់គ្រងលើយោធាតំបន់"។ សំណួររបស់ខ្ញុំសូមសួរថា តើគណៈតំបន់នេះមានន័យដូចម្ដេច?

**ឆ៖** បាទ ដូចបញ្ជាក់រួចហើយបញ្ហាហ្នឹង។

**ស៖** តើគណៈតំបន់សំដៅទៅលើបុគ្គលតែម្នាក់ ឬក៏ជាក្រុម? ឧទាហរណ៍ដូចជា ខាងលេខាតំបន់ ឬក៏ប្រធានតំបន់ គឺសំដៅទៅលើបុគ្គលតែម្នាក់ទេ ក៏ប៉ុន្តែពាក្យថា "គណៈ" នេះ តើលោកអាចជម្រាបជូនអង្គសវនាការ តើខុសគ្នា ឬក៏យ៉ាងម៉េច?

[១០:០៥:១៣]

**ឆ៖** បាទ ហៅថា "គណៈ" ហ្នឹងគឺវាមានបីនាក់បួននាក់ បានហៅ "គណៈ" បាន។ បាទសូមជម្រាបខ្លីប៉ុណ្ណឹងបាទ។

**ស៖** តើរចនាសម្ព័ន្ធ និងតួនាទីរបស់គណៈតំបន់ យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ គេបែងចែកអ្នកខ្លះក៏ទទួលខាងសេដ្ឋកិច្ច អ្នកខ្លះក៏ទទួលខាងសង្គមកិច្ច អ្នកខ្លះក៏ទទួលខាងយោធាបាទ បែងចែកអ៊ីចឹងបាទ។

**ស៖** សួរលោកបញ្ជាក់បន្ថែមនៅលើឯកសារដដែល ប៉ុន្តែលោកបានលើកចំពោះ-- ជាមួយសហព្រះរាជអាជ្ញាហើយ ទាក់ទងទៅនឹងការជជែកលេងជាមួយនឹងលោក ខៀវ សំផន។ លោកបានលើកឡើងថា លោកបានជជែកលេងរឿងការងារសេដ្ឋកិច្ចជាមួយនឹងលោក ខៀវ សំផន តើពេលដែលលោក ខៀវ សំផន ប្រាប់លោកអំពីបញ្ហាសេដ្ឋកិច្ចនុំង តើគាត់និយាយពីបញ្ហាសេដ្ឋកិច្ចនៅពេលនុំងយ៉ាងម៉េចដែរលោក?

[១០:០៦:៥០]

**ឆ៖** បាទ បានជជែកគ្នាបញ្ហាសេដ្ឋកិច្ចហ្នឹង គឺបញ្ហា គាត់ចង់និយាយសំដៅពីរឿងក្នុងតំបន់ទាំងមូល ការដាំដុះយ៉ាងម៉េច ការហូបចុកប្រជាពលរដ្ឋយ៉ាងម៉េច គ្រប់គ្រាន់ឬអត់។ តែប៉ុណ្ណឹងបាទ។

**ស៖** ចុះលោក-- អំ គាត់មាន-- ចុះលោកមានដែលឮ-- គាត់មានលើកអំពីបញ្ហាផែនការបួនឆ្នាំរបស់ៗ បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** បាទ អត់ឮទេបាទ។

**ស៖** ការពីម្សិលមិញខាងព្រះរាជអាជ្ញាធ្វើការបង្ហាញលោកនូវឯកសារ ដែលមានលេខ D89--អំ 189.1 ទាក់ទងទៅនឹងសេចក្ដីណែនាំរបស់គណៈមជ្ឈិមបក្សកម្មុយនីស្ដកម្ពុជា អំពីគោលនយោបាយរបស់បក្សចំពោះអ្នកភ័ន្តច្រឡំចូល សេ.អ៊ី.អា ឬចូល កា.ហ្សេ.បេ ប្រឆាំងបដិវត្តន៍ប្រជាជន និងកម្ពុជាប្រជាធិបតេយ្យ។ សំណួរខ្ញុំសួរថា ដោយម្សិលមិញលោកបានឆ្លើយច្រើនហើយ ខ្ញុំចង់សួរថា លោកក៏បានឆ្លើយផងដែរថា លោកធ្វើការផ្សព្វ-- ក្រោយពីបានទទួលការពន្យល់រួចហើយ លោកបានត្រឡប់ទៅវិញ ធ្វើការផ្សព្វផ្សាយចំនួនម្ដងដល់ខាងតំបន់របស់លោក។ សំណួររបស់ខ្ញុំចង់សួរថា តើលោកមានបានសង្កេតឬទេ នៅពេលដែលក្រោយការផ្សព្វផ្សាយរបស់លោកហើយ ខាងថ្នាក់មូលដ្ឋានគេអនុវត្តតាមគោលការណ៍នេះដែរឬទេ?

[១០:០៨:៥៣]

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបព្រះរាជអាជ្ញាម្សិលមិញហើយ។ គឺខាងមូលដ្ឋានយើងប្រកាសយ៉ាងម៉េច គឺគេអនុវត្តតាមអ៊ីចឹងបាទ។

**ស៖** ចុះដែលមានអ្នកដែលមិនអនុវត្តតាមដែរឬទេ? ហើយវាសនារបស់បុគ្គលនុ៎ងយ៉ាងម៉េចដែរ?

**ឆ៖** បាទ អត់ឃើញមានទេ។

**ស៖** ទាក់ទងទៅនឹងចម្លើយរបស់លោកដែលបានឆ្លើយជាមួយសហព្រះរាជអាជ្ញា ក៏ដូចជាបានឆ្លើយជាមួយនឹងខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ទាក់ទិនទៅនឹងការហៅលោកមកប្រជុំក្រោយពេលដែល ឡាំង គាត់ស្លាប់ ពេលនុ៎ង ប៉ុល ពត ហៅលោកមកប្រជុំដើម្បីឲ្យលោក-- ប្រាប់ឲ្យលោកហ្នឹងធ្វើការជំនួសលោក ឡាំង។ សំណួររបស់ខ្ញុំចង់សូមសួរថា តើពេលដែលលោកមកប្រជុំដំបូងនៅកន្លែង ប៉ុល ពត ធ្វើការហ្នឹង តើលោក ប៉ុល ពត មានបានធ្វើការប្រកាស ឬក៏លើកឧទ្ទេសនាមថាបុគ្គល-- ប្រាប់លោកអំពីបុគ្គលណាមួយ ដែលបានចូលរួមនៅក្នុងហ្នឹងដែរឬទេ? ហើយថាតើបុគ្គលនុ៎ងមានតួនាទីអី? គាត់បានឧទ្ទេសនាមប្រាប់លោកអំពីតួនាទីរបស់បុគ្គលហ្នឹង ហើយការងាររបស់បុគ្គលហ្នឹងដែលចូលរួមនៅក្នុងកិច្ចប្រជុំនុ៎ងដែរឬទេ?

[១០:១០:៣៩]

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបព្រះរាជអាជ្ញាម្សិលមិញអស់ហើយ។

**ស៖** តើពេលនុ៎ងលោកមានបានសង្កេតមើល ថាតើទំនាក់ទំនងរវាងបុគ្គលដែលចូលរួមហ្នឹង-- ខ្ញុំសូមលើកពីខាងដើមបន្តិចដើម្បីជាជំនួយ លោកបានលើកឡើងថា នៅក្នុងកិច្ចប្រជុំហ្នឹងមានវត្តមាន លោក សុន សេន, លោក នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ។ អ៊ីចឹងខ្ញុំសូមសួរថា នៅក្នុងកិច្ចប្រជុំហ្នឹងលោកមានបានសង្កេតដែរឬទេ ថាតើទំនាក់ទំនងរវាងពួកគាត់នៅក្នុងការនិយាយក្នុងអង្គប្រជុំនោះ យ៉ាងម៉េចដែរ?

[១០:១១:២៧]

**ឆ៖** បាទ ឃើញតែ ប៉ុល ពត គាត់ឧទ្ទេសនាម ក្រៅពីហ្នឹងគ្រាន់តែអង្គុយនៅក្នុងវេទិកាស្តាប់បាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមការកត់សម្គាល់សម្រាប់ប្រតិចារឹក ខ្ញុំគិតថាសហការីរបស់ខ្ញុំយល់ច្រឡំហើយ ពីព្រោះថា លោក ខៀវ សំផន មិនដែលមានការលើកឡើងដោយសាក្សីនេះនៅក្នុងកិច្ចប្រជុំនោះទេ។

[១០:១២:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំមានឯកសារជាការបង្ហាញជូនទាក់ទងទៅនឹងចម្លើយរបស់គាត់ដែលគាត់ឆ្លើយកន្លងមក។ ខ្ញុំសួរ ខ្ញុំលើកចំណុចនេះដោយមិនបង្ហាញឯកសារហ្នឹង គឺដោយសារតែខ្ញុំចង់ឲ្យមានការសន្សំពេលវេលា តែបើសិនជាខាងមេធាវីការពារក្តីចង់ឲ្យខ្ញុំធ្វើការបង្ហាញចំណុចនោះ ខ្ញុំនឹងបង្ហាញជូន។

**ប្រធានអង្គជំនុំ៖**

មានសំណួរអីទៀតទេ?

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** កាលពីសប្តាហ៍មុនលោកបានលើកឡើងជូន-- ជម្រាបជូនខាងសហព្រះរាជអាជ្ញាថា

"ហៅបាត់ៗ ម្នាក់ៗចេះតែភ័យព្រួយ" តើ-- ខ្ញុំចង់សួរថាតើនៅក្នុងអំឡុងពេលនោះ លោកឃើញស្ថានភាពបែបហ្នឹង តើលោកមានការភ័យព្រួយដែរឬទេ ចំពោះរូបលោកផ្ទាល់?

[១០:១៣:៤៧]

**លោក សៅ សារុន៖**

**ឆ៖** បាទ ព្រួយ។ មិនព្រួយម៉េច? គេហៅថាទៅរៀនបាត់ៗ នេះ។ ខ្ញុំលើកឧទាហរណ៍ដូចជាប្អូនថ្លៃខ្ញុំហៅថាទៅរៀន បាត់ទៅ រហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំក៏ព្រួយបារម្ភ។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណចំពោះការឆ្លើយរបស់លោក ហើយនិងសូមផ្ទេរវេទិកានេះជូនទៅខាងមេធាវីអន្តរជាតិ ដើម្បីធ្វើការតាំងសំណួរបន្ត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

[១០:១៤:៣៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ សហភាគីទាំងអស់ជាទីគោរព ជម្រាបសួរលោកសាក្សី។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំមានសំណួរតែពីរបីតែប៉ុណ្ណោះ ដែលជាការបន្ត និងមានផ្នែកពិសេសមួយចំនួនដែលខ្ញុំចង់លើកឡើង ហើយដោយសង្ឃឹមថា ខ្ញុំមានពេលវេលាគ្រប់គ្រាន់ដើម្បីចោទសំណួរនេះ។

សំណួរទីមួយរបស់ខ្ញុំលោកសាក្សី គឺទាក់ទងនឹង-- ទាក់ទងនឹងការជម្លៀសមនុស្ស លោកបានជម្រាបទៅលោកសហព្រះរាជអាជ្ញានៅថ្ងៃទី០៦ មិថុនា ថា នៅកន្លែងដែលលោករស់នៅនោះ លោកពុំដែលបានឃើញមនុស្សត្រូវបានគេជម្លៀសពីតំបន់ផ្សេងទៀត មកតំបន់លោកនោះទេ កន្លែងដែលលោករស់នៅនោះទេ។ ខ្ញុំចង់ដឹងថាតើក្នុងឋានៈជាសមាជិកតំបន់ ឬ ក៏លេខាស្រុក លោកបានឮគេនិយាយថាមានមនុស្សដែលមកពីតំបន់ផ្សេងទៀត មកនៅតំបន់១០៥។ តើលោកធ្លាប់បានឮទេ?

**ឆ៖** បាទ អត់ឮទេ ហើយក៏អត់ឃើញមនុស្សអីជម្លៀសមកពីតំបន់ផ្សេងៗមក១០៥ ក៏អត់ឃើញបាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណ។ លោកប្រធានខ្ញុំសូមអនុញ្ញាតប្រើខ្លឹមសារនៃឯកសារមួយ គឺឯកសារលេខ D22/2736 គឺជាឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងបញ្ជីឯកសាររបស់យើង ដែលយើងបានបញ្ចូលទៅក្នុង *អ៊ីនធីហ្វាស* ពីរបីថ្ងៃមុននេះ។ ខ្ញុំគិតថាឯកសារនេះ ដែលខ្ញុំចង់អានសម្រង់មួយ គឺអាចរំឭកដល់ការចងចាំរបស់សាក្សីបាន។ ខ្ញុំគ្រាន់តែចង់អានសម្រង់មួយ ក៏ប៉ុន្តែបើសិនជាអង្គជំនុំជម្រះតម្រូវ យើងអាចបញ្ចាំងបាន។ ERN ជាភាសាបារាំង គឺ 00811449, ជាភាសាខ្មែរ 0057959 ពុំមានការបកប្រែជាភាសាអង់គ្លេសទេ ទោះបីយើងសុំឱ្យបកប្រែក៏ដោយ ក៏ប៉ុន្តែមិនទាន់បក ប្រែបាននោះទេ។ តើខ្ញុំអាចអានសម្រង់នេះបានដែរឬទេ? តើលោកប្រធានចង់ឱ្យខ្ញុំចាក់បញ្ចាំងសម្រង់នេះឬក៏យ៉ាងណា?

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៨:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែអានតែផ្នែកខ្លី សង្ខេបបានហើយ។

ហើយនិងអនុញ្ញាតឱ្យដាក់បង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ផង។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីនេះមានអាយុ១៤ឆ្នាំ នៅឆ្នាំ១៩៧៥ ហើយទាក់ទងនឹងការជម្លៀសមនុស្សនោះគាត់និយាយដូចតទៅនេះ៖ "នៅរបបខ្មែរក្រហម ខ្ញុំនៅខេត្តកំពង់ស្ពឺ បន្ទាប់មកទៀត ខ្ញុំត្រូវបានគេជម្លៀសទៅខេត្តមណ្ឌលគិរី នៅស្រុកកោះញែក ហើយមួយឆ្នាំក្រោយមកគេបានបណ្តេញខ្ញុំចេញទៅព្រំប្រទល់ខ្មែរ-វៀតណាម ខ្ញុំជាសាក្សីផ្ទាល់នៃការសម្លាប់មនុស្សនៅភ្នំក្រោល"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

**ស៖** លោកសាក្សី តើលោកបានធ្វើ-- តើសម្រង់បានធ្វើឱ្យលោកនឹកឃើញអំពីការជម្លៀសមនុស្សដែរឬទេ?

**ឆ៖** បាទ អត់ដឹងទេ បញ្ហាហ្នឹងខ្ញុំអត់ដឹង អត់យល់សោះ បាទ ហើយក៏អត់ឃើញមនុស្ស

ជម្លៀសមក មកនៅមណ្ឌលគិរីផងបាទ។

[១០:២០:០០]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីសហករណ៍ ហើយនិងការដ្ឋានការងារ។ លោកបាននិយាយទៅសហព្រះរាជអាជ្ញាជាតិថ្ងៃទី០៥ មិថុនា ថាមានថ្នាំគ្រប់គ្រាន់ ហើយនិងគ្រឿងបរិក្ខាពេទ្យគ្រប់គ្រាន់នៅក្នុងតំបន់របស់លោក ហើយលោកក៏ជាសមាជិកតំបន់ ដែលទទួលបន្ទុកខាងសុខភាព។ លោកសាក្សី តើមានការព្យាបាលសមរម្យ គឺថាមានពេទ្យដែលទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ ហើយនិងមន្ទីរពេទ្យដែលមានស្ថានភាពល្អដែរឬទេ នៅក្នុងតំបន់លោកនោះ?

**ឆ៖** បាទ សូមឆ្លើយ។ ក្នុងហ្នឹងគឺដូចខ្ញុំជម្រាបព្រះរាជអាជ្ញា គឺមានថ្នាំគ្រប់គ្រាន់ មានជំនាញខាងកម្ចាត់គ្រុនចាញ់ មានជំនាញខាងឆ្លប មានជំនាញខាងជំងឺទូទៅបាទ មានជំនាញខាងវះកាត់អីផ្សេងៗបាទ។

**ស៖** សូមអរគុណ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំចង់ប្រើខ្លឹមសារនៃឯកសារមួយទៀត គឺឯកសារ D22/2260 គឺជា-- ក៏ជាឯកសារដែលមាននៅក្នុងបញ្ជីយើងដែរ ហើយយើងបានបញ្ចូលទៅក្នុង*អ៊ីនធឺហ្វាស* ហើយ គឺជាសេចក្តីប្រកាសរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅទំព័រទី៦ និងទី៧ ជាភាសាបារាំង និងជាភាសាខ្មែរ គឺលេខ ERN 00556228 យើងពុំទាន់មានការបកប្រែជាភាសាអង់គ្លេសទេ។ តើខ្ញុំសូមចាក់បញ្ចាំងសម្រង់នេះ ហើយនិងខ្ញុំសូមអានសម្រង់នេះផងដែរ។ សូមការអនុញ្ញាតពីលោកប្រធាន។

[១០:២២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ដើមបណ្តឹងរដ្ឋប្បវេណីមានអាយុ៣៤ឆ្នាំ នៅពេលកើតអង្គហេតុ គឺនៅ៧តំបន់១០៥ គាត់បាននិយាយយ៉ាងដូច្នេះ “នៅឆ្នាំ១៩៧៧ នៅរដូវភ្លៀង ឪពុកខ្ញុំត្រូវបានគេចាប់ទៅឲ្យកាប់ឫស្សីធ្វើ-- បិតឫស្សីដើម្បីធ្វើចម្រូងការពារខ្មាំងនៅក្នុងព្រៃ ហើយគាត់ត្រូវភ្ញាក់ឡើងពីព្រលឹម ហើយធ្វើការរហូតដល់ព្រលប់ មុននឹងត្រឡប់មកផ្ទះវិញ ដោយធ្វើការដោយពុំមានម្ហូបអាហារបរិភោគ ហើយនិងដើរឆ្ងាយ

រាល់ថ្ងៃ។ គាត់ស្គមពីមួយថ្ងៃៗ រហូតដល់ពេលគាត់ធ្លាក់ខ្លួនឈឺ ហើយក្រោយមកគាត់ហើមពេញខ្លួន គេបាននាំគាត់ទៅដាក់នៅកន្លែងរោងអ្នកជំងឺ ដោយពុំមានពេទ្យ និងថ្នាំព្យាបាល ហើយដែលកន្លែងនោះខ្មែរក្រហមនិយាយប្រាប់ថា បើអ្នកឯងឈឺអ្នកឯងមិនមានសិទ្ធិស៊ីចំណីអាហារទេ ហើយគេបង្អត់ចំណីគាត់ដល់ស្លាប់"។ បាទសូមបញ្ចប់ការដកសម្រង់ត្រង់នេះ។ តើសម្រង់នេះធ្វើឲ្យលោកនឹកឃើញអំពីលក្ខខណ្ឌនៅក្នុងតំបន់លោកនៅទេ លក្ខខណ្ឌសុខភាព?

**លោក សៅ សារុន៖**

**ឆ៖** បាទ បញ្ហាហ្នឹងគឺខ្ញុំអត់ដឹងទេ។ ខាងតំបន់ ខ្ញុំអត់ដឹង។ ខ្ញុំកាលហ្នឹង គឺខ្ញុំនៅតែការងារក្នុងស្រុកខ្ញុំបាទ។ អត់ដឹង ហើយអត់ឮថាមនុស្សស្លាប់អត់មានអាហ្នឹងម្ហូប អត់បាទ។

**ស៖** សូមអរគុណ។ ហើយទាក់ទងនឹងលក្ខខណ្ឌជីវិតនៅ-- ជីវភាពនៅក្នុងសហករណ៍ លោកសាក្សី តើស្ត្រីមានផ្ទៃពោះទទួលការព្យាបាលពិសេសដោយយោងទៅលើភាពផុយស្រួយរបស់គាត់ ឬហើយតើបុគ្គលវ័យចំណាស់ដែលផុយស្រួយដែរនោះ គាត់ទទួលបានការព្យាបាលពិសេសណាទេនៅក្នុងសហករណ៍លោកនោះ?

[១០:២៥:០០]

**ឆ៖** បាទ អាហ្នឹង គឺខ្ញុំសូមឆ្លើយ ស្ត្រីណាដែលមានផ្ទៃពោះ គឺគេមិនឲ្យធ្វើការធ្ងន់ទេបាទ ឬក៏ឆ្លងទន្លេរួចនេះក្នុងរយៈបីខែ ទៅបួនខែ គេមិនឲ្យធ្វើការធ្ងន់ទេ។ គេឲ្យធ្វើការតែក្នុងជុំវិញផ្ទះរបស់គាត់បាទ។ ចប់។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើ-- ប្រើខ្លឹមសារនៃឯកសារពីរទៀត ឯកសារទីមួយ គឺថា D22/1175 គឺជាពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយខ្ញុំសូមដកយកសម្រង់មួយ ដែលមាននៅទំព័រ៤ និងទំព័រ៥ ERN ជាភាសាខ្មែរគឺ 00521307។

លោកប្រធាន តើខ្ញុំអាចបញ្ចាំងបានទេ លោកប្រធាន ហើយនិងសូមអានសម្រង់ផង?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ដើមបណ្ដឹងរដ្ឋប្បវេណីនេះ កាលណោះមានអាយុ២០ឆ្នាំ នៅឆ្នាំ១៩៧៥ ហើយគាត់បានលើក

ឡើងយ៉ាងដូច្នេះ “នៅឆ្នាំ១៩៧៥ដដែល ខ្ញុំត្រូវបានគេបង្ខំឲ្យយកគ្រួសារ ហើយក្រោយមកទៀត ខ្ញុំមានទម្ងន់កូនទីមួយ ហើយមួយអាទិត្យក្រោយមក ពេលដែលសម្រាលកូន ខ្ញុំត្រូវបានគេបង្ខំឲ្យទៅស្ទូងស្រូវ ទោះបីជាខ្ញុំមិនទាន់មានកម្លាំងគ្រប់គ្រាន់ក្នុងការធ្វើការងារនេះក៏ដោយ”។ ខ្ញុំសូមបញ្ចប់ការដកស្រង់ត្រង់នេះ។

ហើយបួនបន្ទាត់ក្រោយមកទៀត “ខ្ញុំទទួលរបបអាហារមិនគ្រប់គ្រាន់ គឺថាមួយ-- អង្ករមួយកំប៉ុងសម្រាប់មនុស្សបួននាក់។ ហើយខ្ញុំអស់កម្លាំងហេវហត់មែនទែន ដែលធ្វើឲ្យពេលខ្លះនុ៎ង ខ្ញុំគេងនៅលើភ្លឺស្រែក៏មានដែរ”។

[១០:២៧:២៦]

ហើយពីរបីបន្ទាត់មកក្រោយទៀត នៅទំព័រទី៥ ជាភាសាបារាំង គាត់និយាយថា “ម្ដាយខ្ញុំចាស់ខ្លាំង ហើយគេឲ្យគាត់ធ្វើ-- គាត់ធ្វើការនៅរោងបាយរហូតដល់អស់កម្លាំងរហិតរហៃ។ នៅពេលដែលគាត់ឈឺគាត់មិនមាន-- ពេលគាត់ឈឺ គឺថាខ្ញុំពុំមានសិទ្ធិសុំទៅសួរសុខទុក្ខគាត់នោះទេ”។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** តើលោកមានធ្លាប់ជួបប្រទះនឹងហេតុការណ៍បែបនេះទេ លោកសាក្សី?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំអត់យល់ទេ អំឡុង៧៥ គឺអត់យល់។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណ។ ខ្ញុំសូមដកស្រង់ឯកសារដ៏ខ្លីមួយទៀត គឺឯកសារ D22/1434-- 33 គឺជាពាក្យបណ្ដឹងដើមបណ្ដឹងរដ្ឋប្បវេណី ជាភាសាបារាំង គឺនៅទំព័រទី៧ ជាភាសាខ្មែរគឺលេខ ERN 00528426 ហើយៗទៅដល់ 27។ លោកប្រធានខ្ញុំសូមអនុញ្ញាតអានសម្រង់នេះ!

[១០:២៩:00]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ដើមបណ្ដឹងរដ្ឋប្បវេណី ជាបុរសមួយដែលមានអាយុ១៦ឆ្នាំ នៅឆ្នាំ១៩៧៧ ហើយគាត់និយាយដូចតទៅនេះ “រីឯឪពុកខ្ញុំវិញ គាត់ចាស់ហើយ គេឲ្យសុំគាត់រកដំឡូងមី ដំឡូងឈើ ដើម្បីមើល ដើម្បី

ផ្គត់ផ្គង់ដល់សហករណ៍ ហើយនិងឲ្យគាត់រកផ្តៅ ហើយរបបម្ហូបរបស់គាត់មិនគ្រប់គ្រាន់ គាត់ធ្វើការដោយអស់កម្លាំងរហិតរហៃ ដោយពុំមានពេលវេលាសម្រាប់សម្រាកនោះទេ។ គាត់ដូចស្ថិតនៅក្នុងធ្លាក់ដុនដាបស្គមស្គាំង។ អ្វីដែលធ្វើឲ្យគាត់ធ្លាក់ខ្លួនឈឺ ហើយនៅពេលនោះ ខ្ញុំបានទៅសុំថ្នាំទៅលោកច្រៃ ដែលលោកមេឃុំ ហើយគាត់ជេរខ្ញុំ ហើយគាត់និយាយថា ចាស់ៗមិនចាំបាច់ព្យាបាលគេទេ ទុកឲ្យគេងាប់ទៅ ព្រោះថាមានក្មេងៗដែលអាចធ្វើការជំនួសបាន។

[១០:៣០:១១]

ហើយនៅពេលដែលខ្ញុំឮយ៉ាងដូច្នេះ ខ្ញុំហូរទឹកភ្នែកច្រោកៗ ហើយខ្ញុំស្រណោះឪពុកខ្ញុំ ដែលថាខ្ញុំស្រលាញ់គាត់ខ្លាំង ក៏-- ហើយគេមើលងាយគាត់យ៉ាងដូច្នេះ ហើយប្រាំថ្ងៃក្រោយមកគាត់ក៏ស្លាប់ទៅដោយតែពុំមានថ្នាំព្យាបាល”។ លោកសាក្សី តើលោកនឹកឃើញដល់អ្វីដែលលោកទំនងជាអាចឃើញ ឬក៏គេធ្លាប់និយាយប្រាប់លោកទេ នៅសម័យនោះ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។ អំឡុង៧៧ ហ្នឹង គឺខ្ញុំនៅស្រុកនៅឡើយទេ។ ក្នុងតំបន់ ខ្ញុំអត់ដឹងកិច្ចការគេ បាទ។ សូមអស់។

**ស៖** សូមអរគុណ។ នៅក្នុងសហករណ៍ តើកុមារដែលជាប្រជាជនទន់ខ្សោយ ទទួលបានការព្យាបាលពិសេស ឬក៏ការគាំពារពិសេសណាទេ?

[១០:៣១:២៣]

**លោក សុន អរុណ៖**

សូម-- ខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញ មេធាវីការពារក្តីលោក នួន ជា!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវយកសំណួរ-- ការសួរឆ្លើយរវាងអ្នកដទៃមកសួរផ្ទុញ់ជាមួយនឹងសាក្សីដែលគាត់មានកាន់កាប់តំបន់មួយ ដែលគាត់មិនដឹងសោះនោះទេ។ សូមៗប្រឆាំង។ អរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

[១០:៣២:១៤]

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំត្រូវតែជំទាស់នៅពេលនេះ ទោះបីជាខ្ញុំមិនចង់លើកឡើងថា ទាំងអស់នេះគឺជាចម្លើយមួយដែលៗយើងមិនគួរតែសួរទេ។ អង្គជំនុំជម្រះដឹងទៅលើចំណុចនេះហើយ។ យើងមានសេចក្ដីសម្រេចនៅចំពោះមុខអង្គជំនុំជម្រះ ដែលថាសេចក្ដីសម្រេចនេះនៅមិនទាន់បានធ្វើឡើងដោះស្រាយនៅឡើយ។ ដូច្នេះ យើងមិនប្រាកដថា តើសាក្សីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះគាត់ត្រូវសួរសំណួរពាក់ព័ន្ធយ៉ាងណានោះទេ។ យើងមានការព្រួយបារម្ភដោយសារតែនៅពេលនេះយើងយកចម្លើយមួយដែលៗយើងមិនអនុញ្ញាត ហើយសាក្សីនោះមិនមកផ្ដល់សក្ខីកម្ម។ ដូច្នេះហើយគឺយើងមិនអាចធ្វើការសួរភស្តុតាងចំណុចនេះនោះទេ។ ដូច្នេះយើងមិនអាចយកចម្លើយនេះធ្វើការតទល់សួរទៅកាន់សាក្សីនោះទេ។ ចម្លើយដែលបានលើកឡើងនេះ គឺមិនមែនជាចម្លើយផ្ដល់នៅចំពោះមុខចៅក្រមស៊ើបអង្កេតនោះទេ។ ដូច្នេះចម្លើយបែបនេះមិនមានទម្ងន់ណាមួយនោះទេ តាមអ្វីដែលខ្ញុំដឹង។ សូមអរគុណ។

[១០:៣៣:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក មេធាវី។ សូមអញ្ជើញលោកមេធាវីតំណាង-- មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំយល់ប្រតិកម្មភាគីការពារក្ដីក្នុងការដែលឮសួរអ្វីដែលខ្ញុំនិយាយនេះ។ ក៏ប៉ុន្តែខ្ញុំមានការភ្ញាក់ផ្អើលដែលឮគេនិយាយថា យើងមានសិទ្ធិតែបង្ហាញឯកសារ ដែលៗជារបស់សាក្សី។ សហព្រះរាជអាជ្ញា គាត់ប្រើសក្ខីកម្មរបស់មនុស្សច្រើនប្រភេទ ហើយខាងការពារក្ដីក៏ធ្វើអ៊ីចឹង ដូច្នេះយ៉ាងហោចណាស់ក្រុមការពារក្ដីរបស់ នួន ជា ផងដែរ។ អ៊ីចឹង ខ្ញុំគិតថាយើងអាចប្រើឯកសារផ្សេងទៀតបាន ហើយបុគ្គលដែលខ្ញុំលើកឯកសារមកនេះ រស់នៅតំបន់១០៥។ ហើយលោក កាណាវាស ខ្ញុំសូមជម្រាបលោកថា អង្គជំនុំជម្រះនឹងវាយតម្លៃលើតម្លៃភស្តុតាងនៅពេលសមស្រប។ ហើយខ្ញុំសូមអភ័យទោស ខ្ញុំភ្លេចបញ្ជាក់ថា អ្វីដែលខ្ញុំលើកឡើងនៅថ្ងៃនេះ គឺជាពាក្យពេចន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលយើងមិនបានស្នើឡើងដើម្បីឲ្យអង្គជំនុំជម្រះស្ដាប់នោះទេ។ ដូច្នេះ ហើយខ្ញុំក៏សូមបញ្ជាក់ទៀតដែរ

ថា សក្ខីកម្មរបស់ពួកគាត់សំខាន់ណាស់ ទោះបីជាពុំមានការស្បថក៏ដោយ ទោះបីសក្ខីកម្មរបស់សាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ហើយយើងមានសិទ្ធិប្រើឯកសារផ្សេងៗ។ ដូច្នេះ ខ្ញុំគិតថា ក្នុងការប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ជាការសមស្រប។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៦:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមមេធាវីអង្គុយចុះ!

បាទ ឥឡូវនេះដល់-- ដោយមានសេចក្តីជំទាស់តវ៉ាគ្នា ហើយបញ្ហានេះគួរតែត្រូវបានដោះស្រាយឲ្យបានជាក់ច្បាស់ផង ដើម្បីផ្គូផ្គងជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានធ្វើកន្លងមក ហើយនិងកិច្ចការផ្សេងៗពាក់ព័ន្ធនឹងឯកសារនេះ នាពេលអនាគតដោយមានការប្រុងប្រយ័ត្នខ្ពស់ផង។ ហើយដល់ពេលសមល្មមនឹងសម្រាកហើយដែរ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់ទីកន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងមេធាវីប្រឹក្សាសាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ៣៧:៥៥ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:២៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ខាងណាមុនឥឡូវ? សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាមុន!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ធ្វើការកែប្រែទៅលើកំណត់ត្រា ដែលព្រះរាជ-- ដែលខាងមេធាវីបាននិយាយ។ គឺខាងមេធាវីបាននិយាយថា ពាក្យសុំរបស់ខាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ដោយមិនមានការស្បថ។ ដូច្នេះខ្ញុំស្នើសុំធ្វើការកែប្រែទៅតាមការយល់ឃើញរបស់ខ្ញុំ។

[១១:០២:៣៩]

តាមពិតទៅពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺនៅពេលដែលមានការចុះហត្ថលេខាហ្នឹង គឺគេបានបញ្ជាក់យ៉ាងច្បាស់ថា តាមដែលខ្ញុំ ហើយនិងតាមដែលខ្ញុំជឿជាក់គឺថា ព័ត៌មានដែលខ្ញុំផ្តល់ឲ្យ គឺនៅក្នុងផ្នែក (យ) ហ្នឹងគឺជាព័ត៌មានដែលត្រឹមត្រូវ ប្រសិនបើមិនដូច្នេះទេ ខ្ញុំនឹងទទួលខុសត្រូវចំពោះមុខច្បាប់។ ខ្ញុំគិតថា នេះជាទម្រង់នៃការស្បថមួយដែរហើយ ដូច្នេះពាក្យសុំហ្នឹងគឺផ្តល់ដោយមានការសម្បថ។ ដូច្នេះខ្ញុំគាំទ្រដល់ខាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានប្រើប្រាស់នូវចម្លើយបែបនេះ ដែលយើងអាចយកមកប្រើប្រាស់បាននៅក្នុងសវនាការ។ ដូច្នេះហើយខ្ញុំគិតថា ទោះបីថាដើមបណ្តឹងរដ្ឋប្បវេណីនឹងបង្ហាញមុខនៅក្នុងសវនាការ ដើម្បីផ្តល់សក្ខីកម្ម ឬក៏អត់នោះ គឺយើងអាចប្រើប្រាស់ចម្លើយបាន។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំគិតថាប្រហែលជាសាក្សីទាំង៤.០០០រូប យើងហ្នឹង មិនអាចមកបង្ហាញបានទាំងអស់នោះទេ។

[១១:០៣:៤៥]

ចំពោះករណីដែលមានអ្នកណាម្នាក់ ដែលមកបង្ហាញ ផ្តល់សក្ខីកម្ម ហើយនិងអំពីការរៀបការដោយបង្ខំ ឬក៏កង្វះខាតនូវឱសថ ឬក៏កង្វះខាតនូវថ្នាំទេព្យក៏ដោយ។ ដូច្នេះហើយខ្ញុំគិតថា ក្នុងឱកាសនេះនៅពេលដែលមានសាក្សីមកពីខាងខេត្តមណ្ឌលគិរី ឬក៏តំបន់១០៥ហ្នឹង គឺជាការត្រឹមត្រូវ ដែលអាចឲ្យគាត់មកប្រឈមជាមួយនឹងចម្លើយដែលទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ។ សូមអរគុណលោកប្រធាន។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ជាដំបូងខ្ញុំសូមឆ្លើយតបទៅនឹងចម្លើយរបស់ខាងព្រះរាជអាជ្ញា។ ព័ត៌មាននេះមិនមែនផ្តល់ដោយមានសម្បថនោះទេ។ គឺថាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ វាគ្រាន់-- ឬក៏យើងអាចហៅថាជាចម្លើយសង្ខេប ដែលផ្តល់ដោយមន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺជា

ចម្លើយដែលមានការស្បថ។ ដូច្នេះ អ្វីដែលគាត់ធ្វើ គឺថាគាត់មានផ្តិតមេដៃ ឬក៏ចុះហត្ថលេខា គឺជាធ្វើឡើងដោយស្បថ ប៉ុន្តែចំពោះដើមបណ្តឹងរដ្ឋប្បវេណី គឺជារឿងមួយផ្សេង អត់មាននោះទេ។

[១១:០៥:០២]

ការជំទាស់ គឺជាគោលការណ៍មួយដែលថា ប្រសិនបើយើងប្រើប្រាស់នូវចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងក្នុងគោលដៅដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺថាគោលដៅសំខាន់គឺដើម្បីតាំងរដ្ឋប្បវេណីនោះទេ។ មិនមែនប្រាកដថាជាការដែលបង្ហាញនូវភាពស្មោះត្រង់ ឬក៏ដែលអាចយកមកប្រឈមមុខបាននោះទេ។ ចម្លើយរបស់ដើមណ្តឹងរដ្ឋប្បវេណីមិនអាចយកមកដើម្បីផ្ទុញទៅលើសាក្សី ឬក៏អ្នកណាមួយរូប។ ហើយចំពោះឯកសារ D22/2736 ទំព័រ៥ ជាភាសាខ្មែរ គឺជាការឆ្លើយដាក់បន្ទុក ឆ្លើយដាក់ទៅលើសាក្សីដោយផ្ទាល់ គឺមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រើប្រាស់នូវចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឆ្លើយដាក់ទៅលើសាក្សី ហើយចាត់ទុកសាក្សីថាជាជនជាប់ចោទទៅវិញ។

[១១:០៦:០៦]

ហើយលោកប្រធានបានជម្រាបមកអង្គជំនុំ-- មកសវនាការរួចហើយថា យើងមិនត្រូវចាត់ទុកសាក្សីថាជាជនជាប់ចោទនោះទេ ដូច្នេះនេះជារឿងមួយផ្សេង។ តាមជំហររបស់យើងគឺ យើងសូមបញ្ជាក់ដូចតទៅ៖ យើងចង់ឲ្យមានគោលការណ៍ណែនាំ ឬក៏វិធានដែលយើងត្រូវគោរពទាំងអស់គ្នា។ ខ្ញុំគិតថា ចម្លើយបែបនេះមិនគួរយកមកប្រើប្រាស់ឡើយ ព្រោះថា ដើមបណ្តឹងរដ្ឋប្បវេណីគាត់នឹងត្រូវមកផ្តល់សក្ខីកម្ម។ យើងនឹងស្តាប់នូវចម្លើយ យើងស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីហើយខ្ញុំមិនជំទាស់នោះទេ។ ហើយជំហររបស់ខ្ញុំបានបញ្ជាក់យ៉ាងច្បាស់រួចមកហើយ យើងនឹងផ្តល់ទម្ងន់តែនៅក្នុងករណីដែលគាត់មកបង្ហាញខ្លួនតែប៉ុណ្ណោះ។ នេះគឺជាគោលជំហរយ៉ាងច្បាស់របស់យើង។

នៅពេលដែលយើងនិយាយថា បុគ្គលម្នាក់មានបទពិសោធន៍ ឬក៏គាត់ធ្លាប់ដឹង ឬក៏គាត់ធ្លាប់រស់នៅក្នុងតំបន់ ឬក៏ភូមិភាគណាមួយគឺជារឿងមិនគ្រប់គ្រាន់នោះទេ លុះត្រាតែយើងបានស្តាប់នូវភស្តុតាងដែលគាំទ្រទៅលើការអះអាងបែបនេះ។ ដូច្នេះ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីវាគ្រាន់តែជាការបំពេញបន្ថែម ឬក៏ជាព័ត៌មានបន្ថែមប៉ុណ្ណោះ មិនមែនជាភស្តុតាងនោះឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក អាកឡូវ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយដោយសង្ខេប ដើម្បីផ្តល់ជាឧទាហរណ៍ដល់អ្វីដែលសហការីរបស់ខ្ញុំលើកឡើង។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរដែលមេធាវី ហ្វូត បានលើកឡើងនេះ គឺជាបុគ្គលដែលប្តឹងប្រឆាំងនឹងសាក្សីនេះ។ ហើយដូច្នេះវាចោទជាបញ្ហា ហើយខ្ញុំគិតថា ដូច្នេះយើងត្រូវតែដោះស្រាយបញ្ហានេះ ដោយហេតុថាសហការីយើងបាននិយាយថា សាក្សី-- ដើមបណ្តឹងរដ្ឋប្បវេណីនេះមិនមាននៅក្នុងបញ្ជីដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងមកបង្ហាញខ្លួននៅទីនេះនោះទេ។

[១១:០៨:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយកម្រិតអត់ឲ្យវិលជុំវិញទេ។ កម្រិតលោកត្រឹមតែឆ្លើយតបតែប៉ុណ្ណោះ ពីព្រោះវាចម្លែកដែរ។ អង្គជំនុំជម្រះបានដកថយទៅពិចារណាសម្រេចពីបញ្ហានេះហើយ ពេលដែលអង្គជំនុំជម្រះវិលចូលមកវិញស្រាប់តែភាគីបន្តបញ្ហានេះដដែល។ ប៉ុន្តែយើងអនុញ្ញាត ដោយសារមូលហេតុយើងក៏ចង់ស្តាប់ភាគីពាក់ព័ន្ធផងដែរលើបញ្ហានេះដើម្បីចេញជាសេចក្តីណែនាំអនុវត្តមួយឲ្យបានជាក់ច្បាស់តែម្តង។ ហើយគួរឲ្យស្តាយដែរភាគីដែលពាក់ព័ន្ធមិនបានតវ៉ា ជំទាស់មុនពេលដាក់ឯកសារនេះដេញដោលទេ។ យើងធ្វើសុទ្ធតែបញ្ច្រាសទៅវិញ។

[១១:០៩:២០]

អង្គជំនុំជម្រះបានរំឭកហើយថា ភាគីណាដែលមានបំណងក្នុងការជំទាស់ទៅនឹងការដាក់ឯកសារណាមួយចំពោះមុខអង្គជំនុំជម្រះ ត្រូវបង្ហាញភ្លាមៗនូវជំហររបស់ខ្លួន និងសំអាងហេតុ សំអាងច្បាប់សំអាងសេចក្តីណែនាំអនុវត្ត ដើម្បីដោះស្រាយ ពិភាក្សា ដោះស្រាយសម្រេចជាមុន។ ហើយភាគីដែលជំទាស់ហ្នឹង គឺភាគីម្ខាងហ្នឹងជំទាស់បានតែម្តងទេ មិនមែនអង្គជំនុំជម្រះ-- ទីមួយវាមិនអាចសម្រេចជំទាស់ទៅលើសេចក្តីឆ្លើយតបទេ។

[១១:១០:០០]

ទីពីរ ការសម្រេចរួចហើយ មិនអាចលើកបញ្ហាដដែលនេះទៀតទេ លើកលែងតែកាលៈទេសៈផ្សេងទៀតប៉ុណ្ណោះ។ ដូច្នេះ សូមលោកយល់ ចៀសវាងច្របូកច្របល់នៅក្នុងដំណើរការនីតិវិធី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល ហើយនិងសាធារណជន។ ខ្ញុំបាទដើបឈរនេះ មានបំណងឆ្លើយតបចំពោះអ្វីដែលលើកឡើងដោយមេធាវីខាងការពារក្តីទាំងពីររូបដែលបានលើកឡើង ជាពិសេសពាក់ព័ន្ធនឹងលោក កាណាវាស ដែលនិយាយថាដើមបណ្តឹងរដ្ឋប្បវេណីគ្មានការស្បថ ហើយចម្លើយនេះដែលមានការធ្វើនៅចំពោះមុខមន្ត្រីរបស់អង្គភាពការិយាល័យសហចៅក្រមស៊ើបអង្កេត។ ចំណុច-- ពាក់ព័ន្ធនឹងចំណុចនេះ ដើមបណ្តឹងរដ្ឋប្បវេណីគ្មានកាតព្វកិច្ចនៅក្នុងការស្បថ ហើយក៏គាត់មិនត្រូវការស្បថដែរ។

[១១:១១:១៣]

ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចនៅក្នុងវិធាន២៣ នៃវិធានផ្ទៃក្នុងបានលើកហើយ គឺគាំទ្រទៅដល់ការចោទប្រកាន់ នេះជាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ព័ត៌មានរបស់គាត់ក៏អាចមានតម្លៃជាភស្តុតាងសម្រាប់អង្គជំនុំជម្រះនៅក្នុងការពិចារណាដែរ។ ដូច្នេះ គ្មានអ្វីដែលថាកំណត់ថា ប្រសិនបើថាគាត់មិនបានស្បថ ឬក៏មិនបានយកព័ត៌មានដោយមន្ត្រី សហចៅក្រមស៊ើបអង្កេត ហើយនិងបានស្បថចំពោះមុខសហចៅក្រមនោះ ព័ត៌មាននោះមិនបាន-- មិនអាចយកធ្វើជាព័ត៌មានដើម្បីយកមក លើកយកមកធ្វើសវនាការឡើយ។

[១១:១១:៥៧]

ចំណុចទីពីរ ដែលបានលើកនោះគឺថា ដើមបណ្តឹងរដ្ឋប្បវេណីគាត់បានលើកព័ត៌មាននៅក្នុងទម្រង់បែបបទព័ត៌មានរបស់គាត់ ដែលយើងហៅកាត់ថា វី.អាយ.អេហ្វ នេះ គឺមិនមែនចោទប្រកាន់ទៅលើសាក្សីដែលគាត់មានវត្តមាននៅទីនេះទេ។ គោលបំណងនៃការលើកអំពីព័ត៌មានជាសង្ខេប ជា--សម្រាប់តែជាព័ត៌មាន អំ! ជាបច្ចេកទេសនៅក្នុងការសួរយកព័ត៌មានពីសាក្សីតែប៉ុណ្ណោះ។ នេះគឺជាវិធីសាស្ត្រនៅក្នុងការសួរយកព័ត៌មានរបស់ភាគីនីមួយៗ។

ដូចគ្នាដែរ នៅក្នុងទម្រង់បែបបទព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំ គឺមិនត្រឹមតែសុំធ្វើខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺសុំឲ្យមានការកាត់ក្តីរកយុត្តិធម៌ជូនគាត់ផងដែរ។ ដូច្នេះ គាត់មិនបានចោទប្រកាន់ទៅលើសាក្សីនេះទេ ហើយអ្នកដែលបាន-- ដែលគាត់ មានបំណងចោទប្រកាន់ដើម្បីឲ្យមានការកាត់ក្តី គឺមាននិយាយនៅក្នុងទម្រង់បែបបទរបស់គាត់រួចហើយ។ អ៊ីចឹង សូមអរគុណលោកប្រធាន។

[១១:១៣:០៨]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះអង្គជំនុំជម្រះបានស្តាប់នូវមតិយោបល់របស់ភាគីនៅជុំវិញបញ្ហាឯកសារដែលដកស្រង់ពីពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះហើយ ហើយអង្គជំនុំជម្រះទុកបញ្ហានេះមួយអន្លើសិនដើម្បីពិចារណាសម្រេចកាន់តែជាក់ច្បាស់ថែមទៀតជាពេលក្រោយ។ ហើយជាកិច្ចបន្តអង្គជំនុំជម្រះសូមជម្រាបជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មជាច្រើនមកហើយអំពីការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ហើយអង្គជំនុំជម្រះយល់ឃើញថា វាសមល្មមហើយ។

ម្យ៉ាងទៀត ការតាំងសំណួរបែបនេះទៅសាក្សី នឹងធ្វើឲ្យកិច្ចដំណើរការនេះកាន់តែអូសបន្លាយពេលវេលា។ សំណួរដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរទៅកាន់សាក្សីចុងក្រោយ មានការពាក់ព័ន្ធតិចតួចណាស់ចំពោះអង្គហេតុនានាដែលបានចោទប្រកាន់។ ដូច្នេះ សាក្សីមិនចាំបាច់ឆ្លើយទៅនឹងសំណួរចុងក្រោយរបស់សហមេធាវីនាំមុខទេ។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបន្តទៅសំណួរថ្មី ផ្សេងៗទៀតប្រសិនបើមាន ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន ឬក៏មន្ទីរសន្តិសុខភ្នំក្រោល។

[១១:១៤:៣៤]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសាក្សីនេះត្រូវបានចោទសួរទៅអង្គហេតុទាំងមូលនៃសំណុំរឿង០០២ តែម្តង ហើយសហព្រះរាជអាជ្ញាបានចោទសួរទៅលើអង្គហេតុទាំងមូលនៃសំណុំរឿង០០២ ដូច្នេះ ខ្ញុំៗ ក៏ចង់សួរទៅទាំងមូលនៃសំណុំរឿង០០២ ដែរ។ ខ្ញុំបានលើកឡើងអំពីការជម្លៀសសហករណ៍ ហើយខ្ញុំក៏ចង់លើកឡើងអំពីការសម្លាប់មនុស្ស ពីមន្ទីរសន្តិសុខ ជាពិសេស គឺការធ្វើទុក្ខបុកម្នេញ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ខ្ញុំមានពេលខ្លីណាស់ ដូច្នេះខ្ញុំសង្ឃឹមថា ខ្ញុំអាចអនុវត្តការងារខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមលទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន។ តើខ្ញុំអាចធ្វើទៅបានទេលោកប្រធាន?

[១១:១៥:២៦]

**ប្រធានអង្គជំនុំ៖**

យើងបានជម្រាបហើយ ថាការសួរសាក្សីរូបនេះ គឺក្នុងវិសាលភាពនៃសំណុំរឿង០០២ ព្រឹកមិញ ដូចយើងបាននិយាយម្តងហើយ ក្នុងនាមជាមេធាវីគួរតែចងចាំហើយភាសា ០០២ និង០០២/០១ ខុសគ្នាឆ្ងាយណាស់។ ប៉ុន្តែយើងជម្រាបថា អង្គហេតុពាក់ព័ន្ធនឹងសហករណ៍នៅក្នុងតំបន់មណ្ឌលគិរី ឬតំបន់១០៥ មិនមានការបង្ហាញលាតត្រដាងចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយទេ។ អង្គហេតុសហករណ៍មានតែត្រាំកក់ នៅក្នុងតំបន់-- នៅក្នុងភូមិភាគពាយ័ព្យ បច្ចុប្បន្នះនៅក្នុងខេត្តតាកែវមួយគត់។ ប្រសិនបើមានការពាក់ព័ន្ធនឹងអង្គហេតុសហករណ៍ គឺលោកអាច លោកស្រីអាចសួរគាត់បានពាក់ព័ន្ធទៅនឹងអង្គហេតុសហករណ៍ស្រុកត្រាំកក់ ខេត្តតាកែវបច្ចុប្បន្ន។ ប្រសិនបើមានការចោទប្រកាន់នៅក្នុងអង្គហេតុនៃតំបន់មណ្ឌលគិរី ឬតំបន់១០៥ អំពីសហករណ៍ សូមលោកស្រីបង្ហាញនូវកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយ ឲ្យយើងបានដឹងផង។

[១១:១៧:០៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងចោទសំណួរពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល ហើយខ្ញុំគិតថា វាស្ថិតនៅក្នុងដែនកំណត់នៃសំណុំរឿង០០២ នេះហើយ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ពាក់ព័ន្ធទៅនឹងការបាត់ខ្លួន លោកសាក្សី លោកបានឆ្លើយជូនទៅសហព្រះរាជអាជ្ញា គេបានបង្ហាញបញ្ជីអ្នកទោស នៅស-២១ ដែលនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ៧៧ លោកឆ្លើយថា លោកមិនដឹងអំពីការបញ្ជូនមនុស្សទៅមន្ទីរស-២១ទេ។ តើលោកធ្លាប់ឃើញ ឬក៏ធ្លាប់ឮអំពីការចាប់ខ្លួនមនុស្ស ហើយបណ្តើរ ឬក៏ដឹកតាមឡានទៅកន្លែងណាមួយដែលលោកមិនស្គាល់ដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺអត់ដឹងទេ បញ្ហាហ្នឹង។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត អាននូវសម្រង់នៃឯកសារ D22/2796 ជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនិយាយអំពីការចេញខ្លួន-- ចេញពីតំបន់១០៥ ទៅកាន់មន្ទីរស-២១។ ទំព័រជាភាសាបារាំង គឺទំព័រ 678, ជាភាសាខ្មែរគឺ ERN 00556543 រហូតទៅដល់ 00556544។

លោកប្រធាន តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវសម្រង់នេះទេ?

[១១:១៩:០២]

**ប្រធានអង្គជំនុំ៖**

ចំណាងជើងឯកសារស្អីទៅ? ប្រាប់ចំណាងជើងឯកសារឲ្យបានច្បាស់។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ឯកសារនេះ គឺជាសេចក្ដីប្រកាសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី លោកប្រធាន។

[១១:២០:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២០:៤០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ដោយសារមូលហេតុបញ្ហានេះ មានការជំទាស់តវ៉ាតឹងតែងអម្បាញ់មិញនេះ ប៉ុន្តែយើងនឹងលើកបញ្ហានេះទៅពិនិត្យពិចារណានៅពេលក្រោយ។ ឥឡូវនេះជាបញ្ហាបន្ទាន់ គឺយើងអនុញ្ញាត ប៉ុន្តែអង្គជំនុំជម្រះសូមជម្រាបជូនដល់ទៅ ក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជ្រាបថា ប្រភេទឯកសារដែលលោកស្រីមានបំណងក្នុងការលើកឡើងយកមកបង្ហាញនេះ គឺវាមានតម្លៃជាភស្តុតាងតិចតួចណាស់ ហើយអង្គជំនុំជម្រះធ្លាប់បានជម្រាបជូនញឹកញាប់ហើយលើបញ្ហានេះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ដូច្នេះខ្ញុំអាន-- សូមអាននូវសម្រង់ដែលខ្ញុំបានផ្ដល់លេខយោងជាភាសាបារាំង និងជាភាសាខ្មែររួចមកហើយ។ ខ្ញុំមិនមានការបកប្រែជាភាសាអង់គ្លេសនោះទេ ទោះបីជាមានការស្នើសុំក៏ដោយ។

[១១:២១:៤៤]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា៖ "នៅចុងឆ្នាំ៧៥ ខ្ញុំដឹកមនុស្សមួយឡានពេញមានស្រី មានប្រុស ដែលចោទថាជាខ្មាំង ហើយដឹកទៅកាន់ខេត្តក្រចេះ។ នៅពេលដែលយើងទៅដល់ឃុំថ្មក្រាល ស្រុកក្រចេះ ខេត្តក្រចេះ មានកាណូតរង់ចាំពួកគេ ហើយដឹកបន្តទៅទៀត។ ខ្ញុំមិនដឹងថា គេដឹកយកទៅណាទេ គ្រាន់តែឮថាយកទៅរៀនសូត្រ ហើយបាត់ខ្លួនរហូតមិនដែលឃើញត្រឡប់មកវិញទេ"។

នៅទំព័របន្ទាប់មកទៀត សាក្សីរូបនេះបាននិយាយថា៖ "ដើមឆ្នាំ៧៨ ខ្ញុំត្រូវបានបញ្ជូនឲ្យធ្វើជាអ្នកបើកឡានដូចកាលមុនដែរ។ សួន ដែលជាប្រធានមន្ទីរពាណិជ្ជកម្មបានប្រាប់ខ្ញុំថា មិត្តមិនចាំបាច់ធ្វើអីទេ គឺត្រៀមចាំតែជួសជុលឡាន ធ្វើយ៉ាងណាកុំឲ្យខូច។ ពេលនោះមានឡានពីរគ្រឿងដែលផលិតនៅប្រទេសចិន ទុកសម្រាប់ដឹកមនុស្ស ដែលពួក ប៉ុល ពត ចាត់ទុកថាជាមនុស្សក្បត់ ហើយត្រូវដឹកយកទៅសម្លាប់ចោលនៅម្ដុំភ្នំក្រោល មានចម្ងាយប្រហែលប្រាំគីឡូម៉ែត្រពីទីរួមស្រុកកោះញែក។

ជារៀងរាល់ថ្ងៃ គឺនៅពេលព្រលឹមមានឡានពីរគ្រឿងត្រូវចេញដំណើរ ដែលមួយឡានដឹកមនុស្សប្រហែលពី១០នាក់ ឬច្រើនជាងនេះយកទៅបាត់ ប្រហែលជាមួយម៉ោងទើបយើងឃើញមកវិញ"។ សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកមាននឹកឃើញអ្វីខ្លះទេ ពាក់ព័ន្ធនឹងសម្រង់នេះ?

[១១:២៣:៣៣]

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ គឺអត់ដឹងទេ។ ក្នុងអំឡុង៧៥ អត់ដឹង អត់ឮ អត់ឃើញតែម្ដងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរមួយទៀត ពាក់ព័ន្ធទៅនឹងភ្នំក្រោម-- ភ្នំក្រោល សូមទោស។ បន្ទាប់មកខ្ញុំនឹងសួរអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ។ ខ្ញុំគិតថា វាស្ថិតនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២។ ពាក់ព័ន្ធទៅនឹងភ្នំក្រោល ខ្ញុំចង់លើកឡើងនូវកិច្ចសម្ភាសន៍ចុងក្រោយរបស់សាក្សីដែលមានលេខ E3/404 នៅទំព័រប្រាំ ជាភាសាបារាំង, ERN ជាភាសាខ្មែរ 00398484, ERN ជាភាសាអង់គ្លេស 00403027។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះ និងបញ្ចាំងនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

[១១:២៥:០៩]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកបានឆ្លើយទៅនឹងសំណួរ "នៅពេលលោកកាន់កាប់មន្ទីរតំបន់១០៥ តើមន្ទីរសន្តិសុខ

ភ្នំក្រោលនៅមានដំណើរការទេ?” លោកសាក្សី លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “នៅដំណើរការធម្មតា” ហើយលោកបានបន្ថែមទៀតថា៖ “ប៉ុន្តែអត់មានចាប់អ្នកនេះ អ្នកនោះទេ”។ លោកសាក្សី ខ្ញុំសូមសួរលោកថា តើមានន័យថាម៉េចមន្ទីរសន្តិសុខដែលដំណើរការធម្មតានេះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំបានឆ្លើយដូចព្រះរាជអាជ្ញាជ្រាបហើយ។ ធម្មតាហ្នឹង គឺវាអត់មានចាប់ អត់មានចង។ អាហ្នឹងបានគេហៅថា ពាក្យធម្មតាបាន។ សូមអស់។

**ស៖** សូមអរគុណលោកសាក្សី។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ D22/452 ដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានលេខ ERN ជាភាសាបារាំង 0050-- សូមទោស 00811451, ជាភាសាខ្មែរ 00580977។ ខ្ញុំសូមអាននូវព័ត៌មានបន្ថែម ហើយនិងលើកឡើងនូវចម្លើយសាក្សីនេះពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺជាស្ត្រីដែលមានអាយុ២៤ឆ្នាំ នៅឆ្នាំ៧៥ ហើយគាត់បានឆ្លើយថា៖ “ប្ដីនាងខ្ញុំ ត្រូវបានបញ្ជូនទៅឲ្យធ្វើការនៅមន្ទីរ ក-១៧ ស្ថិតនៅភ្នំក្រោល។ មន្ទីរ ក-១៧ មានព្រំប្រទល់ជាប់ជាមួយគុកភ្នំក្រោល។ មន្ទីរនេះស្ថិតនៅក្រោមតំបន់”។ ខ្ញុំសូមរំលងមួយកថាខណ្ឌ។ “នៅជាប់មន្ទីរ ក-១៧ មានមន្ទីរ ក-១១ ដែលជាកន្លែងកម្លាំងស្រួចសម្រាប់ធ្វើការងារខ្លាំងៗ ដូចជាការលើកទំនប់ជាដើម។ ពេលខ្លះនាងខ្ញុំត្រូវគេបញ្ជូនទៅធ្វើការជាមួយអ្នកនៅក-១១ផងដែរ។ នៅទីនោះខ្ញុំធ្លាប់បានឃើញគេចាប់ខ្លួនមនុស្សទាំងខ្សែៗ ដោយមានចងក្រពាត់ដៃទៅក្រោយ”។

**ស៖** លោកសាក្សី តើលោកមាននឹកឃើញអ្វីខ្លះទេ ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល ដែលនៅជិតមន្ទីរតំបន់១០៥ ដែរនោះ?

[១១:២៨:៣១]

**លោក សៅ សារុន៖**

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបអំមិញហើយ អត់ឃើញ អត់ដឹង អត់ឮថាចាប់មនុស្សទាំងខ្សែៗទៅដាក់ក្នុងសន្តិសុខ អត់ឃើញទេ បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរចុងក្រោយមួយពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាសំណួរបន្តពីសហព្រះរាជអាជ្ញា ហើយនិងជាសំណួររបស់សហភាតាររបស់ខ្ញុំកាលពីព្រឹកមិញនេះ។ ជាច្រើនលើក ច្រើនសា លោកបានឆ្លើយថា ត្រូវតែមានការយល់ព្រមពីឪពុកម្តាយនិងពីសាមីខ្លួនប្តីប្រពន្ធ ដើម្បីអាចរៀបការបាន ហើយលោកក៏បានឆ្លើយបែបនេះដែរនៅពេលព្រឹកមិញនេះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារចុងក្រោយ ដែលជាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអាច ខ្ញុំសង្ឃឹមថា អាចឲ្យសាក្សីនេះនឹកឃើញពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺឯកសារលេខ D22/1433, ជាភាសាបារាំង ERN 00811424 ជាភាសាខ្មែរ ERN 00585681។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារនេះជាចុងក្រោយលោកប្រធាន។

[១១:៣០:១៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១១:៣០:០០]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

នេះគឺជាចម្លើយរបស់បុរសម្នាក់ដែលមានអាយុ១៦ឆ្នាំ នៅឆ្នាំ១៩៧៥។ គាត់បានឆ្លើយថា “តាមពិតទៅនៅឆ្នាំ១៩៧៨ ពេលគេបញ្ជូនឲ្យធ្វើការនៅភ្នំក្រោលដើម្បីកាប់ឈើ នៅក្នុងពេលនោះប្រធានអារឈើឈ្មោះ រិន បានបង្ខំឲ្យខ្ញុំរៀបការជាមួយនារីឈ្មោះ អ៊ី ដែលជាជនជាតិព្នងដែរ។ ពេលនោះ ខ្ញុំខ្លាចមិនហ៊ានប្រកែកអ្វី តវ៉ាអ្វីទាំងអស់ ព្រោះថាអ្នកដែលហ៊ានប្រកែកតវ៉ា នឹងត្រូវគេចាប់ចងមិនខាន។ ពេលរៀបអាពាហ៍ពិពាហ៍នោះមាន ១៨គូៗ ដោយប្រពន្ធនៅខាងមុខ ហើយប្តីនៅជួរខាងក្រោយ។ បន្ទាប់មក គេឲ្យប្តេជ្ញាយកគ្នាជាប្តីប្រពន្ធ”។

**ស៖** លោកសាក្សី តើលោកមាននឹកឃើញអ្វីខ្លះទេ ពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំនៅក្នុង

តំបន់របស់លោក?

[១១:៣១:៤៦]

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ។ ក្នុង៧៥ គឺខ្ញុំនៅស្រុកនៅឡើយទេ។ តាមខ្ញុំនឹកឃើញ អារឿងថា ចាប់បង្ខំរៀបអាពាហ៍ពិពាហ៍អត់មានទេ។ បាទ សូមអស់។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសោកស្ដាយណាស់ដែលមិនអាចធ្វើឱ្យលោកចងចាំបាន ពាក់ព័ន្ធទៅនឹងចំណុចសំខាន់ៗមួយចំនួន។ ខ្ញុំសូមបញ្ជាក់ថា ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលខ្ញុំប្រើប្រាស់ថ្ងៃនេះៗ គឺជាអ្នកដែលរស់នៅក្នុងតំបន់១០៥ ហើយទោះបីជាខ្ញុំជ្រើសរើសមួយចំនួនក៏-- ក្នុងចំណោមនោះក៏ដោយ គឺថាវាមានពាក់ព័ន្ធទៅនឹងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ។ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ចប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាកិច្ចបន្ត តើអស់លោក លោកស្រីចៅក្រម មានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[១១:៣៣:០២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ជម្រាបសួរលោកសាក្សី! ជាបឋម ខ្ញុំគិតថា ដើម្បីឱ្យកុំឱ្យមានការភ័ន្តច្រឡំចំពោះឈ្មោះលោកនោះ តើឈ្មោះលោកអានថា សៅ សារុន ឬក៏ សូ សារុន? សូមបញ្ជាក់ឱ្យបានច្បាស់ពីឈ្មោះរបស់លោក។

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺឈ្មោះខ្ញុំ គឺ សៅ សារុន។

**ស៖** លោកសាក្សី លោកបាននិយាយច្រើនរួចមកហើយ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួននៅតំបន់

១០៥ ជាពិសេសនៅក្នុងកងពល៩២០។ មុននឹងចោទសំណួរទៅកាន់លោក ខ្ញុំគិតថាវាជាការសំខាន់ក្នុងការកត់សម្គាល់នៅចំណុចមួយចំនួន។ ខ្ញុំសូមយោងទៅលើឯកសារ D288 ឬក៏ឯកសារ D81 *អាន់ណិច* អា (Annex A) ឯកសារនេះគឺជាបញ្ជីអ្នកទោសដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១។ ប្រសិនបើយើងបូកសរុបចំនួនមនុស្សដែលត្រូវបានចាប់ខ្លួនមកពីតំបន់១០៥ ឬក៏កងពល៩២០ នោះយើងឃើញថាមានចំនួនសរុបនោះគឺ ៣១៨ គឺមានអ្នកទោសចំនួន៣១៨នាក់ ដែលមកពីតំបន់១០៥។ ហើយមានឯកសារមួយផ្សេងទៀត ដែលបញ្ជាក់អំពីការចាប់អ្នកទោសនេះដែរនោះ គឺជាបញ្ជីអ្នកទោសដែលមកដល់មន្ទីរស-២១ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ហើយអ្នកទោសនោះ គឺមកពីមន្ទីរ-- មកពីកងពល៩២០ ឬតំបន់១០៥។ ហើយសម្រាប់តែថ្ងៃ២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ តែមួយនោះមានអ្នកទោសចំនួន១៥១នាក់។

នេះគឺឯកសារ D175/3.31។ នេះ គឺជាតួលេខដែលពាក់ព័ន្ធទៅនឹងស-២១ ហើយវាមិនពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខដែលមាននៅក្នុងតំបន់១០៥ នោះទេ។ ជាដំបូង ខ្ញុំសូមចោទសំណួរពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់មន្ទីរ តំបន់១០៥។ យើងបាននិយាយអំពីឈ្មោះ ឡាំង ដែលជាលេខាតំបន់១០៥។ តើលោកអាចបញ្ជាក់បានទេថា តើ ឡាំង នេះមានឈ្មោះអ្វីផ្សេងទៀតទេ ឬក៏មានតែ ឡាំង ទេ?

**ឆ៖** បាទ តាមខ្ញុំយល់ គេហៅគឺឈ្មោះតែ ឡាំង១ តែមួយហ្នឹង ក្រៅពីហ្នឹងខ្ញុំអត់ដឹង។

[១១:៣៦:២៥]

**ស៖** ប្រសិនបើខ្ញុំប្រាប់លោកថា គាត់ប្រហែលជាអាចមានឈ្មោះថា ហាំ ឬក៏មានឈ្មោះថា ឆាន តើឈ្មោះ ហាំ ហើយនិង ឆាន នេះលោកមាននឹកឃើញទេ? លោកមានដឹងថាឈ្មោះអ្នកណាទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

**ស៖** លោកបានឆ្លើយថា លោកស្ថិតនៅក្នុងគណៈកម្មាធិការទទួលបន្ទុកខាងផ្នែកពេទ្យនៅក្នុងតំបន់។ តើលោកអាចបញ្ជាក់បានទេ ថាក្នុងឋានៈលោកធ្លាប់មានការប្រជុំជាមួយ ឡាំង ឬក៏មានការសមាជិកផ្សេងទៀតនៃតំបន់១០៥ ដែរឬទេ?

**ឆ៖** បាទ យើងខ្ញុំជាខាងមន្ទីរពេទ្យ-- អ៎ ពេទ្យតំបន់ហ្នឹងមែន បាទ។ ការប្រជុំហ្នឹងគឺបានទំនាក់ទំនងទៅគាត់ ជំរុញតែខាងរឿងធ្វើមន្ទីរពេទ្យ ជំរុញពេទ្យធ្វើយ៉ាងម៉េចឲ្យមើលអ្នក-- ពេលមានអ្នកឈឺអ្នកគ្រុនមក សម្រាកនៅមន្ទីរពេទ្យ ធ្វើយ៉ាងម៉េចឲ្យយកចិត្តទុកដាក់ព្យាបាលគេ។ បាទ ខ្ញុំ តួនាទីខ្ញុំមាន

តែប៉ុណ្ណឹងបាទ។

[១១:៣៨:១៩]

**ស៖** លោកសាក្សីលោកបានឆ្លើយថា ឡាំង បានចេញដំណើរទៅជាមួយ ខាំ ភួន នៅចុងឆ្នាំ ១៩៧៧ ទៅកាន់ទីក្រុងភ្នំពេញ។ តើលោកអាចបញ្ជាក់បានទេថា បន្ទាប់ពីការបាត់ខ្លួន ឡាំង តើមានអ្នកណាម្នាក់ផ្សេងទៀតទេមកជំនួសប្រធានតំបន់១០៥ នេះ មុននឹងគេតែងតាំងលោកឲ្យទៅចូលជាលេខាតំបន់១០៥នេះ? ឬមួយក៏អាចនិយាយបានទៀតថា នៅចន្លោះលោក ហើយនិង ឡាំង នោះ តើមានអ្នកណាម្នាក់ជាប្រធានតំបន់១០៥ ទេ? ហើយប្រសិនជាមានតើអ្នកណា?

**ឆ៖** បាទ អត់មានទេ គឺចន្លោះហ្នឹងគឺអត់មានទេបាទ។

**ស៖** តើនៅពេលណាដែលលោកទទួលបន្ទុកជាលេខាតំបន់១០៥នោះ? នៅឆ្នាំដែរ? តើនៅពេលដែលលោកត្រឡប់មកពីទស្សនកិច្ចនៅភ្នំពេញ ឬក៏ក្រោយការស្លាប់របស់ ឡាំង ឬក៏នៅពេលក្រោយទៀត?

[១១:៣៩:៥៣]

**ឆ៖** បាទ គឺខ្ញុំបានទទួលក្រោយ ឡាំង សម្លាប់-- អ៎! ស្លាប់ បាទ គឺឆ្នាំ-- អ៎ខែ៩ ឆ្នាំ១៩៧៨ បានគេតែងតាំងឲ្យខ្ញុំធ្វើជាប្រធានតំបន់បាទ។

**ស៖** អ៊ីចឹង តើនៅពេលនុ៎ងអ្នកណាជាអ្នកប្រធានមន្ទីរតំបន់១០៥ហ្នឹង គឺនៅពេលដើមឆ្នាំ៧៨ រហូតទៅដល់ខែកញ្ញា ៧៨ ហ្នឹង តើអ្នកណាដែរជាប្រធានមុនលោកនោះ?

**ឆ៖** អត់ដឹង អត់យល់ទេបញ្ហាហ្នឹង។

**ស៖** លោកសាក្សី តើលោកអាចជម្រាបបានទេថា តើគេមានស្នើឲ្យលោកផ្ញើទូរលេខជាញឹកញាប់ ឬក៏ជាទៀងទាត់ទៅកាន់មន្ទីរមជ្ឈិម ឬមន្ទីរ៨៧០ ទៅបងធំលេខ២ ឬក៏អ្នកណាផ្សេងទៀតនៅពេលដែលគេឲ្យលោកទទួលបន្ទុកផ្ញើទូរលេខនោះ តើលោកត្រូវផ្ញើទូរលេខ ហើយនិងទទួលទូរលេខនោះ?

[១១:៤១:៣២]

**ឆ៖** បាទ គឺមានការរាយការណ៍ទៅ គឺខ្ញុំផ្ញើទៅ ប៉ុល ពត តែម្តងបាទ។

**ស៖** ពាក់ព័ន្ធទៅនឹងរបាយការណ៍ និងការផ្ញើលិខិតឆ្លងឆ្លើយនោះ នៅក្នុងសំណុំរឿងយើងមានទូរលេខជាច្រើន។ ជាដំបូង គឺខ្ញុំសូមលើកឡើងនូវទូរលេខដែលបានផ្ញើទៅវិញទៅមករវាង ឡាំង និង

ភ្នំពេញ។ ឧទាហរណ៍យើងមានទូរលេខបីដែលផ្ញើជូនបងៗជាទីស្នេហា និងរឮក ចុះថ្ងៃទី១២ ខែតុលា នេះគឺជាទូរលេខដែលចម្លងជូន បង នួន, មន្ទីរ, ឯកសារ។ គឺឯកសារលេខ E3/1189។ ទូរលេខ 00 ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ៧៦ ផ្ញើជូនសមមិត្ត ឌឿន ជាទីស្នេហា និងរឮក។ ទូរលេខនេះចម្លងជូនបង នួន, មន្ទីរ និងឯកសារ។ គឺឯកសារ E3/1191 ហើយនៅក្នុងទូរលេខនេះដែរ ឡាំង បានប្រកាសថា គាត់ផ្លាស់ឈ្មោះថ្មីទៀត ហើយចាប់ពីពេលហ្នឹងទៅត្រូវហៅគាត់ថាឈ្មោះ ឆាន។ ទូរលេខ៣ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ៧៦ ផ្ញើជូនសមមិត្ត ឌឿន ជាទីស្នេហា និងរឮក។ ចម្លងជូន បងនួន, មន្ទីរ និង ឯកសារ។ ទូរលេខនេះ គឺឯកសារ D366/7.1.780។

[១១:៤៣:៣១]

ទូរលេខ១០ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦ ផ្ញើជូនបងជាទីស្នេហា និងរឮក។ ទូរលេខនេះផ្ញើ-- ចម្លងជូនបង នួន, មន្ទីរ និងឯកសារ។ គឺឯកសារលេខ D248/5.1.12។ ទូរលេខ៣ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ផ្ញើជូន បងនួន គឺឯកសារលេខ D252.22។ ទូរលេខ២២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ផ្ញើជូនសមមិត្ត ប៉ង់ ជាទីស្នេហា និងរឮក។ ទូរលេខនេះ ចម្លងជូន បងនួន, មន្ទីរ និងឯកសារ។ គឺឯកសារលេខ D366/7.1.785។

ទូរលេខ៣៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ផ្ញើជូនមន្ទីរ ៨៧០ ជាទីស្នេហា និងរឮក ចម្លងជូនបង នួន, បងខៀវ, មន្ទីរ និងឯកសារ។ ហើយជាចុងក្រោយគឺទូរលេខ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ៧៧ ផ្ញើជូនមន្ទីរ ៨៧០ ជាទីស្នេហា និងជាទីនឹករឮក គឺឯកសារលេខ IS21.17។ នៅក្នុងឯកសារនេះ គឺទូរលេខនេះ គឺមានប្រកាសអំពីការចាប់ខ្លួននៅក្នុងកងពល៩២០ ហើយក្នុងហ្នឹងក៏មានហៅ អាសោម និង អាឈិន ហើយក៏មានបង្ហាញអំពីការរាយការណ៍ជូនសមមិត្ត សាន ផងដែរ។

លោកសាក្សី! នៅពេលដែលលោកជួប ឡាំង ឬក៏ ឆាន តើមានទំនាក់ទំនងជាមួយនឹង បងនួន ឬក៏មានជាមួយអ្នកណាផ្សេងទៀតនៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ។ កាល តាឡាំង គាត់កាន់កាប់ហ្នឹង គឺគាត់ជូនសារទៅណាៗ ខ្ញុំអត់ដឹងទាំងអស់ ពីព្រោះខ្ញុំឡើងកាន់តួនាទី ឆ្នាំ១៩៧៨ តែប៉ុណ្ណឹងទេ។ មុនហ្នឹង គឺខ្ញុំអត់យល់ អត់ដឹងសោះ អត់ដឹង។

[១១:៤៦:២២]

**ស៖** សម្រាប់ជាប្រតិចារឹកនោះ ខ្ញុំគិតថា ខ្ញុំភ្លេចផ្តល់លេខ នៃទូរលេខ៣៣ ចុះថ្ងៃទី២៦ ខែ

វិច្ឆិកា ឆ្នាំ១៩៧៦ ផ្ញើជូនមន្ទីរ៨៧០ ជាទីស្នេហា និងរឮក។ ឯកសារហ្នឹងគឺឯកសារលេខ D366/7.1.786។ លោក សៅ សារុន តើលោកធ្លាប់ឮឈ្មោះ សោ គឹមអាន ហៅ ម៉ី, ចាំ, ប៉ាក់ ហើយនិងលោក ដែលជាសមាជិកនៃមន្ទីរតំបន់១០៥។ លោកធ្លាប់ឮឈ្មោះទាំងអស់នេះទេ? លោកធ្លាប់ឮឈ្មោះអស់ហ្នឹងទេ?

**ឆ៖** បាទ អាហ្នឹង ខ្ញុំធ្លាប់ឮឈ្មោះបាទ។

**ស៖** តើលោកដឹងទេ ថាមានអីកើតឡើងចំពោះអ្នកទាំងអស់នេះ?

**ឆ៖** រឿងហ្នឹង ខ្ញុំអត់ដឹង កើតមានរឿងអី ខ្ញុំអត់ដឹងបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅសំណួរមួយចំនួនទៀត ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធា ជាពិសេសពាក់ព័ន្ធទៅនឹងកងពល៩២០។ តើលោកមាននៅនឹកឃើញលេខាកងពល៩២០ មុនឈ្មោះ សាន ទេ? លោកដឹងទេ ថាអ្នកណាជាប្រធានកងពល៩២០ មុន សាន នោះ?

**ឆ៖** បាទ គឺខ្ញុំអត់ដឹងទេ ពីព្រោះខ្ញុំការងារខ្ញុំនៅស្រុក ខ្ញុំអត់ដឹងបាទ។

[១១:៤៨:៣៣]

**ស៖** លោកទទួលបន្ទុកលើស្រុកពេជ្រាដា ប្រសិនបើខ្ញុំមិនច្រឡំទេ គឺថាលោកមានទាហានជាច្រើនមកពីកងពល៩២០ ដែលមកប្រចាំការនៅស្រុកពេជ្រាដា តើត្រឹមត្រូវដែរឬទេ លោកសាក្សី?

**ឆ៖** បាទ អាហ្នឹងគឺ ខ្ញុំអត់-- ដូចបានរាយការណ៍ជូនសហចៅក្រមរួចហើយ មាន។

**ស៖** តើលោកមានស្គាល់ឈ្មោះ ម៉ែន ម៉េង ហៅ ឈិន ដែរឬទេ?

**ឆ៖** បាទ អត់ស្គាល់ទេ។

**ស៖** តើលោកដឹងទេថា អ្នកណាជាប្រធានកងពល៩២០ មុនពេល សាន ឡើងកាន់តំណែងនេះ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។

[១១:៤៩:៥៤]

**ស៖** តើលោកធ្លាប់ឮឈ្មោះ អៀង ជី ហៅ ស្វយ ហៅ សយ ឬក៏ហៅ សោម ដែរឬទេ? តើឈ្មោះនេះអាចជាអនុលេខាកងពល៩២០ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់យល់ទេ។ ក្នុង ខាងយោធា ខ្ញុំអត់យល់ទេបាទ។

**ស៖** តើលោកអាចនិយាយអំពី សាន បានទេ? គឺជាអ្នកដែលលោកធ្លាប់ជួបហើយ ឈ្មោះ សាន នេះ។

**ផ៖** បាទ អាហ្នឹងខ្ញុំយល់។ សាន គឺជាប្រធានកងពល។

**ស៖** តើ សាន នៅរស់ដែរឬទេ?

[១១:៥១:១៧]

**ផ៖** អត់ទេ ស្លាប់ហើយ។

**ស៖** តើ សាន ហ្នឹងមានទំនាក់ទំនងជាមួយ ញ៉ែម សាន ដែលយើងបានឃើញនៅពេលកាត់ទោស ប៉ុល ពត នៅខែសីហា ឆ្នាំ១៩៧៧ (ស៊ីក) នោះ មានការកាត់ទោស ប៉ុល ពត ផង ហើយនិងមានអ្នកផ្សេងមួយចំនួនទៀត ដែលត្រូវខ្មែរក្រហមកាត់ទោស។ តើជាឈ្មោះ-- តើជា ញ៉ែម សាន ហ្នឹងមែនទេ?

**ផ៖** បាទ ខ្ញុំ ពេលគេថាកាត់ទោស ប៉ុល ពត ខ្ញុំអត់យល់ អត់ដឹងបាទ។

**ស៖** តើលោកធ្លាប់ឮឈ្មោះ វៀង ដែរទេ?

**អ្នកបកប្រែ៖** សូមកែប្រែ លោកធ្លាប់នៅអន្លង់វែងដែរទេ?

**ផ៖** បាទ ខ្ញុំនៅអន្លង់វែង។

**ស៖** តើលោកមិនដែលឮគេនិយាយអំពីការកាត់ទោស ប៉ុល ពត ទេឬ?

**ផ៖** បាទ អត់ឮទេបាទ។

**ស៖** សូមអរគុណ។ នៅក្នុងសំណុំរឿងយើងមានឯកសារមួយចំនួន ពាក់ព័ន្ធទៅនឹងលិខិតឆ្លើយឆ្លងរវាងសេនាធិការ ហើយនិងកងពល៩២០ ឬក៏មានជាទូរលេខដែលបានផ្ញើទៅវិញទៅមក រវាងកងពល៩២០ និងមនុស្សមួយចំនួន។ ឯកសារទីមួយនោះ គឺពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងសេនាធិការ និងកងពល៩២០ គឺឯកសារ IS13.40 គឺកំណត់ហេតុនៃការប្រជុំកងពល៩២០ សមមិត្ត សយ និង រ៉េន ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦។

[១១:៥២:៤១]

នៅក្នុងឯកសារនោះមានបង្ហាញអំពីមតិណែនាំរបស់ បង៨៩ អំពីខ្លាំង។ គឺៗនេះគឺជាទូរលេខណែនាំ-- យើងមានទូរលេខណែនាំរបស់ បងខៀវ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦ ផ្ញើជូនសមមិត្តឈិន ដែលបានចម្លងជូន បង៨១, បងសោម, បងណាត, បងរ៉េន និងឯកសារ។ ឯកសារទូរលេខនេះគឺឯកសារ D248/5.1.11។ ទូរលេខ០២ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ដែលឈ្មោះ ឈិន ផ្ញើជូន បង៨៩ ចម្លងជូន បង៨៩, បង៨១, បងសោម, បងណាត, បងរ៉េន និងឯកសារ។ គឺឯកសារលេខ

D248/5.1.8។ ទូរលេខ១១ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៧ ដែលឈ្មោះ សាន ផ្ញើជូន បង៨៩ ជាទីគោរពស្នេហា ចម្លងជូន បង៨៩, បង៨១, មន្ទីរ និងឯកសារ។ គឺឯកសារលេខ D366/7.1.791។

[១១:៥៥:២២]

នៅក្នុងឯកសារនេះ គឺយើងមានឃើញចំណារសរសេរដៃពីរ។ មួយគឺសរសេរថា "ជូនអង្គការជាព័ត៌មាន" និងចំណារសរសេរដៃមួយទៀតសរសេរថា "ឲ្យចាប់មក"។ ទូរលេខ០៥ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៧៧ ដែលឈ្មោះសាន ផ្ញើជូនបង៨៩ ជាទីស្នេហា សុន សេន, ចម្លងជូន បង៨៩ មន្ទីរ និងឯកសារ គឺឯកសារលេខ D248/5.1.1។

ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងលោក និង សាន លោកសាក្សី ប្រសិនបើខ្ញុំមិនច្រឡំទេ លោកបានឆ្លើយថា លោកធ្លាប់បានប្រជុំជាមួយ សាន ហើយលោកបានឆ្លើយថា នៅក្នុងពេលប្រជុំជាមួយ សាន នោះ សាន បានកាន់បញ្ជីឈ្មោះមនុស្សមក គឺជាបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួន។ តើលោកអាចពន្យល់បន្ថែមអំពីអ្វីដែល សាន ធ្វើបន្ថែមទៀតបានដែរឬទេ?

**ឆ៖** បាទ គឺខ្ញុំដូចដែលបញ្ជាថា ធ្វើសារ ធ្វើអីហ្នឹង អាហ្នឹងខ្ញុំអត់យល់ទេ កិច្ចការខាងកងពលគេ ខ្ញុំអត់យល់។ អង្កាល់ហ្នឹងគឺខ្ញុំនៅក្នុងក្របខ័ណ្ឌស្រុក ខ្ញុំអត់យល់ខាងការងារខាងយោធាខាងកងពលទេបាទ។ សូមជម្រាបអ៊ីចឹងបាទ។

[១១:៥៧:២០]

**ស៖** លោកសាក្សី ខ្ញុំមិននិយាយអំពីសារទេ។ ខ្ញុំនិយាយអំពីកិច្ចប្រជុំ ដែលក្នុងពេលនោះ លោកបានជួបជាមួយ សាន ហើយនៅក្នុងពេលប្រជុំនោះ សាន ទំនងជានាំមកជាមួយនូវបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួន។ តើលោកចងចាំទេ ថាលោកបានធ្លាប់ចូលរួមកិច្ចប្រជុំជាមួយ សាន? ហើយលោកចាំទេថា តើ សាន មានបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួននោះ?

**ឆ៖** បាទ គឺប្រជុំហ្នឹងប្រជុំ ប៉ុន្តែបញ្ជីថាចាប់ខ្លួនចំនួនប៉ុណ្ណោះ ឈ្មោះនេះ ឈ្មោះនោះ គឺអត់ដឹងអត់ឃើញបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីមន្ទីរសន្តិសុខម្តង។ ខ្ញុំមានសំណួរខ្លីៗទេ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ។ លោកបាននិយាយអំពីឈ្មោះ សុភា ជាច្រើនដងមកហើយ។ តើជាការត្រឹមត្រូវដែរឬទេ ដែលថា សុភា ជាប្រធានមន្ទីរសន្តិសុខសម្រាប់តំបន់១០៥ ដែលគាត់ទទួលបន្ទុក ក-១១ ហើយនិង ក-១៧ ឬក៏មន្ទីរផ្សេងទៀត។ តើអ៊ីចឹងមែនទេលោកសាក្សី?

**ធ៖** បាទ អាហ្នឹងគឺមែន គឺដូចខ្ញុំជម្រាបលោកសហចៅក្រមរួចហើយបាទ។

[១១:៥៩:២៦]

**ស៖** តើ សុភា គាត់មានអនុមួយដែលឈ្មោះ វៀង ហៅ ខាំ ជាអនុប្រធានគាត់ដែរឬទេ?

**ធ៖** អត់មែនទេ។ វៀង គឺខាងយោធាទេ។ អាហ្នឹងប្រធានវរៈ។

**ស៖** តើលោកអាចនិយាយអំពីឈ្មោះ សៅ ចាំពី ហៅ ម៉ុង ដែរឬទេ? តើអ្នកណាជា សៅ ចាំពី ហៅម៉ុងហ្នឹង?

**ធ៖** បាទ សៅ ចាំពី ហៅ ម៉ុង ហ្នឹងគឺតែមួយទេបាទ។

**ស៖** តើ សៅ ចាំពី ហ្នឹងជាអ្នកណាដែរ បើធៀបជាមួយលោក គាត់ត្រូវជាអ្វីហ្នឹងលោក?

**ធ៖** បាទ គាត់ជាប្អូន។

**ស៖** តើលោកមានទំនាក់ទំនងអីជាមួយគាត់ទេពេលនុ៎ង?

**ធ៖** បាទ ទំនាក់ទំនងធម្មតាជាបងប្អូន។

[១២:០១:១២]

**ស៖** តើ សៅ ចាំពី មានមុខងារអីដែរ?

**ធ៖** បាទ គាត់ជាសមាជិកនៅក្នុងវរៈ តាវៀង ហ្នឹងបាទ។

**ស៖** ខ្ញុំនឹងអានទូវសម្រង់នៃឯកសារ D125/155 ឯកសារនេះមាននៅក្នុងសំណុំរឿងហើយ ហើយបានដេញដោលហើយ ដែលមានលេខ E3/506។ ERN ជាភាសាខ្មែរ 00239941 ទៅដល់ 00239947, ERN ជាភាសាអង់គ្លេស 00244488 ទៅដល់ 00244493, ERN ជាភាសាបារាំង 00289937 ទៅដល់ 00289942។

នេះគឺជាចម្លើយរបស់ប្អូនរបស់លោកពាក់ព័ន្ធទៅនឹងមុខងាររបស់គាត់៖ "នៅចន្លោះឆ្នាំ៧៥ ទៅដល់ឆ្នាំ៧៩ ខ្ញុំជាប្រធាននៃកងវរសេនាតូច ហើយប្រធានហ្នឹងគឺឈ្មោះ ឡាំង។ ឡាំង គាត់ដឹកនាំកងអនុសេនាតូច ហើយនៅឆ្នាំ៧៩នោះ គាត់ជាអនុប្រធានអនុសេនាតូច។ យើងជាអ្នកទទួលបន្ទុកការពារព្រំដែន។ វៀង គាត់នៅប៊ូស្រា នៅស្រុកចិន្តា ហើយខ្ញុំ ខ្ញុំប្រចាំការនៅអូររាំង។ ការងារប្រចាំថ្ងៃរបស់ពួកខ្ញុំ ពេលខ្លះក៏មានមកប្រជុំនៅតំបន់ក្នុងស្រុកកោះញែកជាមួយ ឡេង, សុភា, ឡាំង។ ហើយក្រោយមក បានមកប្រជុំជាមួយ សារុន, តាលក, តាអនស៊ី ដែរ។ ហើយការងារប្រជុំនោះ គេនិយាយអំពីខ្មាំងវៀតណាម ការការពារព្រំដែនកុំឲ្យវៀតណាមយកទឹកដី"។ លោកសាក្សី តើនេះជាការពិត

ត្រឹមត្រូវដែរឬទេ?

[១២:០៤:០៣]

**ឆ៖** បាទ ជាការត្រឹមត្រូវ រឿងប្រជុំជាមួយ តាឡាំង ហ្នឹងខ្ញុំអត់យល់ទេ។ អង្គាល់ប្រជុំ ដែលខ្ញុំចូលរួមអីហ្នឹង ការពិត អាហ្នឹងគឺការពារព្រំដែន ធ្វើយ៉ាងម៉េចកុំឲ្យវៀតណាមចូលមក បាទ។

**សៈ** ក្រោយទៀត គេបានសួរសំណួរថា តើលោកបានដឹងអ្វីខ្លះអំពីគុកនៅភ្នំក្រោល? ហើយគាត់ឆ្លើយថា៖ "ឡឿង ជាអ្នកកាន់កាប់ផ្នែកគុក។ ខ្ញុំមិនស្គាល់អ្នកណាខ្លះនៅពីក្រោម តាឡឿង ដែលកាន់កាប់គុកផ្ទាល់នោះទេ។ តាឡឿង ជាអ្នកមកពីខេត្តរតនគិរី។ ខ្ញុំសង្កេតឃើញថា តាមបញ្ជាពី សុភា និងតាមការរាយការណ៍មកពីមូលដ្ឋាន តាឡឿង ឲ្យកូនទាហានរបស់គាត់ទៅចាប់មនុស្ស។ តើ សុភា អាចមកប្រាប់តា ឡឿង ផ្ទាល់ អាចបញ្ជាតាមសំបុត្រ ឬក៏តាមនីរសារ។ ខ្ញុំមិនស្គាល់នីរសាររបស់តា សុភា ទេ។ ខ្ញុំមិនបានដែលបានទទួលបញ្ជាឲ្យទៅចាប់ ឬក៏ទៅទទួលអ្នកទោសទេ។ គុកដែលអនុសេនាធំរបស់ តាឡឿង កាន់កាប់នោះមានចម្ងាយប្រហែលមួយគីឡូម៉ែត្រ ខាងកើតភ្នំក្រោល។ គុកនេះសង់ផ្ទាល់ដី ហើយប្រក់ស្បូវ។ ខ្ញុំមិនចាំថាមានចំនួនប៉ុន្មានល្វែង ឬមានប៉ុន្មានខ្នងនោះទេ ខ្ញុំចាំថាមានរបងឈើព័ទ្ធជុំវិញ។ ខ្ញុំមិនដែលចូលទៅក្នុងរបងគុកនោះទេ។ ខ្ញុំធ្លាប់ឃើញអ្នកទោសងូតទឹក ធ្វើពលកម្មជម្រះស្មៅ អារឈើ ដោយពុំមានចំណងទេ។ អ្នកទោសស្លៀកពាក់ ធម្មតា មានស្រីមានប្រុស មិនឃើញមានកូនក្មេងទេ។ ហើយនៅក្នុងគុក អ្នកទោសប្រហែលជាត្រូវដាក់ខ្នោះ។ ខ្ញុំមិនស្គាល់ប្រភេទអ្នកទោសទេ តែអ្នកដែលត្រូវចាប់មកនោះ គឺសុទ្ធតែជាអ្នកដែលបានប្រព្រឹត្តកំហុសហើយ។ រាល់ពេលប្រជុំ ប្រហែលមួយខែម្តងជាមួយ ឡឿង, សុភា, ឡាំង ដែលជាលេខាតំបន់១០៥ និង សារុន ពួកគាត់តែងតែនិយាយអំពីគោលការណ៍កុំឲ្យទាក់ទងជាមួយវៀតណាម ឬកុំឲ្យសេរីពេក។ ដូចជា ឧទាហរណ៍ មិនសូវធ្វើការងារជាដើម ពីព្រោះថាអ្នកធ្វើដូច្នេះ គឺសុទ្ធតែជាខ្មាំង។ ដូច្នេះ ខ្ញុំសង្កេតឃើញថា អ្នកទោសទាំងនោះប្រហែលជាធ្វើខុសដូចប្រការទាំងនេះហើយ"។

តើអ្វីដែលខ្ញុំអាននេះ ស្របតាមអ្វីដែលលោកនឹកឃើញទេ?

[១២:០៧:១៩]

**ឆ៖** បាទ ខ្ញុំ បញ្ហាហ្នឹងខ្ញុំអត់យល់ទេ។ បាទ ខ្ញុំ រឿងគេប្រជុំ រឿងគុក រឿងចំនួនអ្នកទោសអី ខ្ញុំអត់ដឹង ពីព្រោះខ្ញុំការងារនៅក្នុងស្រុក ខ្ញុំអត់ដឹងអ្វីទាំងអស់ រឿងការងារក្នុងតំបន់បាទ។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម នៅមានសំណួរអីច្រើនទៀតទេ? ទំនងនៅប៉ុន្មានសំណួរទៀតក្នុងការតាំងសំណួរចំពោះសាក្សីនេះ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំមានសំណួរមួយទៀតសម្រាប់ចោទសួរសាក្សីនេះ។ ដូច្នេះ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបញ្ចប់តែម្តងទៅ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** នេះគឺជាសំណួរដេញដៀបទៅនឹងទូរលេខ ដែលថាលោកជាអ្នកសរសេរ ហើយគេបានសួរច្រើនពាក់ព័ន្ធនឹងទូរលេខនេះ គឺទូរលេខ ៥៤ និង៥៥ គឺឯកសារលេខ E3/941 និង E3/488។ ខ្ញុំគត់សម្គាល់ឃើញថា ទូរលេខទាំងអស់នេះត្រូវបានចម្លងជូន អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, មន្ទីរ និងឯកសារ។

សំណួរខ្ញុំគឺសាមញ្ញទេ តើលោកដឹងទេ នៅពេលដែលលោកផ្ញើទូរលេខទៅជូនបងជាទីស្នេហានីករលើកនោះ គឺថាផ្ញើជូនទៅមនុស្សសំខាន់មួយចំនួន ដូចជាបងធំលេខ២, អៀង សារី, បងវ៉ាន់, វន វ៉េត, ហើយនិងមន្ទីរឯកសារ? តើលោកដឹងពីចំណុចនេះទេ?

[១២:០៩:២៥]

**លោក សៅ សារុន៖**

**ឆ៖** បាទ ដូចខ្ញុំជម្រាបលោកសហចៅក្រមស៊ើបអង្កេតហ្នឹង គឺបានសរសេរមែន ប៉ុន្តែ វន វ៉េត, វន អីៗ ខ្ញុំ-- អាហ្នឹង ខ្ញុំមិនបានដាក់ឈ្មោះទេ។ គឺសរសេរ គឺថា ជូនតែ ប៉ុល ពត តែមួយទេបាទ។ អាហ្នឹងបានសរសេរមែន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ រៀងលើសម៉ោងបន្តិចផង។ មុននឹងសម្រាកអង្គជំនុំជម្រះសូមសួរទៅលោកសាក្សី លោក សៅ សារុន តាម

ការស្នានទូវសុខភាពរបស់លោក តើនៅរសៀលនេះលោកអាចបន្តផ្តល់សក្ខីកម្មបានដែរឬទេ?

**លោក សៅ សារុន៖**

បាទ អាចបន្តបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ អង្គ-- ដល់ពេល-- សូមអញ្ជើញលោកមេធាវី!

[១២:១០:៥១]

**លោក ហ្សាស្តើ ប៉ោ៖**

កូនក្តីរបស់ខ្ញុំ នួន ជា ចង់តាមដាននីតិវិធីសវនាការពីបន្ទប់រង់ចាំខាងក្រោម។ ដូច្នេះ យើងខ្ញុំរៀបចំលិខិតបោះបង់សិទ្ធិរួចជាស្រេចដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ពីពេលនេះទៅរហូតដល់ម៉ោងមួយសាមនាទីរសៀលសឹមអញ្ជើញចូលវិញ។ ហើយមន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកនៅក្នុងអំឡុងពេលពិសាអាហារថ្ងៃត្រង់ ហើយចំពោះសាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងកំណត់ខាងលើ គឺម៉ោងមួយ និងសាមសិបនាទីរសៀលនេះ។

[១២:១១:៣៧]

ហើយអង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ស្នើសុំតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការដោយក្រុមមេធាវីការពារក្តីបានសន្យាថា ខ្លួននឹងប្រគល់មកអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលថ្ងៃនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទាប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះ

បង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

[១២:១២:៤០]

ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយក្រោមសាលសវនាការនេះក្នុងរយៈពេលនៃដំណើរសវនាការសម្រាប់ពេញមួយរសៀលថ្ងៃនេះ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះទុកឱ្យលោក នួន ជា នៅក្នុងបន្ទប់ដែលមានរៀបចំជាស្រេចនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ហើយដោយឡែកលោក ខៀវ សំផន ឱ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៩]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។

[១៣:៣២:៤៧]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** លោក សៅ សារុន សូមជម្រាបសួរ! ខ្ញុំ ហ្សាស្តើ ប៉ៅ ជាមេធាវីអន្តរជាតិ ការពារក្តីឲ្យលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោកនៅល្ងាចនេះ។ ហើយខ្ញុំចង់និយាយជាមួយលោកជាបឋមអំពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥។ ដូចដែលការិយាល័យសហព្រះរាជអាជ្ញា និងខាងដើមបណ្តឹងរដ្ឋប្បវេណីសួរនោះដែរ លោកបានប្រាប់យើងថា ពីសប្តាហ៍មុននោះថា នៅពេលនោះមានការទម្លាក់គ្រាប់បែកពីអាមេរិកាំង។ ហើយខ្ញុំក៏សួរសំណួរលោកបន្ថែមអំពីប្រធានបទ នៃការទម្លាក់គ្រាប់បែកនេះ។ សំណួរទីមួយរបស់ខ្ញុំទៅលោកនោះគឺថា តើលោកខ្លួនឯង បានឃើញផ្ទាល់នៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅខេត្តមណ្ឌលគិរីដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងឃើញផ្ទាល់ហើយ។ ផ្ទះសម្បែងនៅទីរួមខេត្តហ្នឹង គឺខ្ទេចខ្ទាំ អាហ្នឹងឃើញនឹងភ្នែកបាទ។

**ស៖** លោក សៅ សារុន តើលោកអាចធ្វើការប៉ាន់ប្រមាណបានទេ ថាតើការទម្លាក់គ្រាប់បែកនេះបន្តរហូតដល់ប៉ុន្មានឆ្នាំ បើគិតជារយៈពេលនៃការទម្លាក់ហ្នឹង?

[១៣:៣៤:៣៤]

**ឆ៖** បាទ ទម្លាក់តាំងពី៧០ រហូតដល់មក៧៥ មាន បេ-៥២ ផង តាមព្រំប្រទល់បាទ។

**ស៖** លោកនិយាយថា ការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនោះធ្លាប់ចំទៅលើផ្ទះ ហើយពីអាទិត្យមុនលោកនិយាយអំពីការទម្លាក់គ្រាប់បែកចំទីវត្តអារាមផងដែរ តើលោកនៅចាំទេថាលោកនិយាយអ៊ីចឹងពីអាទិត្យមុន?

**ឆ៖** បាទ នៅចាំ ដូចជាវត្តជីមៀតហ្នឹង នៅឃុំជីមៀតហ្នឹង គឺខ្ទេចអស់ អត់មានសល់ទេ។ នៅខេត្តក៏អ៊ីចឹង។

**ស៖** តើអាមេរិកាំងក៏ទម្លាក់គ្រាប់បែកលើវាលស្រែ ឬក៏ស្រូវដែលនៅក្នុងស្រែដែរឬទេ?

**ផ៖** បាទ កន្លែងខ្លះតាមព្រំដែន ប៉ះចំលើចម្ការក៏មាន កន្លែងខ្លះក៏ចំ-- អាហ្នឹងកៀនចម្ការ គឺនៅក្នុងក្រុមគ្រួសារខ្ញុំអស់ ១១នាក់ ត្រូវគ្រាប់បែក។

[១៣:៣៦:៣១]

**ស៖** តើប្រជាជនស្លាប់ដោយសារការទម្លាក់គ្រាប់បែក របស់អាមេរិកនៅមណ្ឌលគិរីនោះដែរឬទេ?

**ផ៖** បាទ មាន។ តាមព្រំដែនហ្នឹងតាមភូមិខ្លះមានសល់តែពីរបីនាក់ គឺត្រូវគ្រាប់បែក ប-៥២ របស់អាមេរិកបាទ។

**ស៖** ដើម្បីឲ្យខ្ញុំយល់លោកឲ្យបានច្បាស់ គឺថាប្រជាជនដែលត្រូវគ្រាប់បែក របស់សហរដ្ឋអាមេរិកហ្នឹងគឺស្លាប់ទាំងអស់ ឬមានអ្នកត្រូវហើយរបួសនៅរស់ដែរ?

**ផ៖** បាទ ស្លាប់ខ្លះ អាចរបួសហ្នឹងមួយចំនួនដែរ។ ស្លាប់ហ្នឹងគឺវាច្រើនជាងរបួសបាទ។

**ស៖** តើលោកដឹងដែរឬទេថា តើសាកសពដែលស្លាប់ហ្នឹង ដែលស្លាប់ពីការទម្លាក់គ្រាប់បែកអាមេរិកហ្នឹង គេយកទៅធ្វើអ្វី ឬក៏យ៉ាងម៉េចដែរ?

**ផ៖** បាទ ហ្នឹងខ្ញុំក៏បានសួរអ្នកដែលនៅរស់ហ្នឹង ថាគេយកទៅកប់អីស្រួលបួលដែរបាទ។

**ស៖** តើលោកដឹងដែរឬទេ អ្នកដែលរងរបួសនោះក្រោយមកពួកគាត់នោះយ៉ាងម៉េចដែរបាទ?

**ផ៖** បាទ អត់យល់ទេ។ ក្រោយមក គឺអាហ្នឹងពួក-- គេវ៉ៃបុកមក ដើម្បីយក-- ដណ្ដើមយកខេត្តវិញ គេកៀរប្រជាជនទាំងអស់តាមព្រំដែនហ្នឹងទៅស្រុកយួនទាំងអស់។

[១៣:៣៩:០៤]

**ស៖** តាមដែលខ្ញុំយល់នោះថា តើលោក សៅ សារុន ដែលថាមានមនុស្សច្រើនត្រូវបានគេជម្លៀសដែល-- ដើម្បីគេចពីគ្រាប់បែក ឬក៏យ៉ាងដូចម្ដេច? អ៊ីចឹងសូមលោកឆ្លើយដោយសង្ខេបឡើងវិញបាទ?

**ផ៖** បាទ អាហ្នឹងអត់មានជម្លៀសទេ ដូចនៅខេត្តមណ្ឌលគិរី គឺរត់តែម្ដង។ ទម្លាប់គ្រាប់បែកច្រើនគឺគេរត់តែម្ដង អត់មានថាជម្លៀសទៅអីចេះអីចុះ គឺគេរត់រកលាក់រកពួនតាមជនបទបាទ។

**ស៖** នៅក្នុងការឆ្លើយតប ទៅនឹងតុលាការពីសប្ដាហ៍មុននោះ លោកនិយាយថា មានការទម្លាក់គ្រាប់បែកពាសពេញដី ដូចជាថាការគ្រាប់បែកគ្រប់ទីកន្លែង ដូចគេក្រាលព្រំនោះ តើលោកមានន័យដូចម្ដេច?

**ឆ៖** បាទ អាហ្នឹង គឺពិតប្រាកដតែម្តង ទម្លាក់ហ្នឹង។ បេ-៥២ ហ្នឹង មកម្តងបីគ្រឿង ទម្លាក់គ្រាប់បែកអស់ហើយ មកអាហ្នឹងវិលវិញ ទៅវិញ បីគ្រឿងមកទៀត ទម្លាក់រហូត ទាំងពេលយប់ទាំងថ្ងៃ បាទ។

**ស៖** លោកនិយាយអំពីបេ-៥២ គឺជាយន្តហោះទម្លាក់គ្រាប់បែក តើលោកបានឃើញយន្តហោះឧទ្ធម្ភាគចក្រ ហៅថា អេលីកុបទ័រ របស់អាមេរិកាំង មកបាញ់ ឬក៏មកទម្លាក់ទេ នៅមណ្ឌលគិរី បាទ?

**ឆ៖** បាទ មានទាំងឧទ្ធម្ភាគចក្រ ទាំងអី អាលឿនៗហ្នឹង គេហៅថា-- អីទេ ខ្ញុំអត់ស្គាល់ទេ លឿនណាស់ ទម្លាក់កាត់ផ្លូវ កាត់ស្ពាន ខ្ទេចខ្ទាំអស់ហើយ អត់មានសល់ទេ។

[១៣:៤១:៣៤]

**ស៖** លោកបានឃើញយន្តហោះទម្លាក់គ្រាប់បែកអាមេរិកាំង ហើយឃើញអេលីកុបទ័រ ឬក៏ហៅថា ឧទ្ធម្ភាគចក្រ ថាតើមានឃើញយន្តហោះប្រភេទបែបនោះ ទម្លាក់គ្រាប់បែកនៅតាមខេត្តដែរឬទេ? បាទ ហើយឃើញពួកទាហានអាមេរិកាំងផងដែរឬទេ?

**ឆ៖** បាទ ឃើញប្រភេទយន្តហោះហ្នឹង មកទម្លាក់មែន។ ទាហានអាមេរិកាំងហ្នឹង ពួកវាបុកមកពីវៀតណាមខាងត្បូងហ្នឹង ជិតដល់ឃុំក្រង់តេះ នៅក្នុងស្រុកពេជ្រចិន្តា ខាងខេត្តវាបុកមកបីមុខ ព្រួញបាទ ខាងខេត្តហ្នឹង ហួសខេត្តមក ខាងកែវសីមាហ្នឹង ក៏ជិតដល់ព្រំប្រទល់ខេត្តក្រចេះ បាទ។

**ស៖** លោក សៅ សារុន តើលោកស្គាល់ ឬដឹងពីមូលហេតុថា ហេតុអីបានជាអាមេរិកាំងទម្លាក់គ្រាប់បែកនៅមណ្ឌលគិរីនោះ ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយ! ចាំស្តាប់អង្គជំនុំជម្រះសម្រេចពីលើសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

[១៣:៤៣:១៥]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

យើងជំទាស់នឹងសំណួរនេះ គឺថាសុំសាក្សីគាត់ធ្វើសន្និដ្ឋាន លើកលែងតែមេធាវីការពារក្តីសួរថា តើគាត់ដឹងដោយផ្ទាល់ខ្លួន ទាក់ទងទៅនឹងការឃើញ ឬក៏ការបានប្រទះនឹងហេតុការណ៍ហ្នឹង។

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំអស់លោកប្រធាន ខ្ញុំនឹងសួរសំណួរនេះ រៀបឃ្លាឡើងវិញ។

[១៣:៤៣:៤៣]

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោក សៅ សារុន នៅពេលនោះ គឺនៅក្នុងឆ្នាំ១៩៧០ រហូតដល់១៩៧៥ តើអ្នកណានិយាយ ឬក៏គេគិតថា គេដឹងពីមូលហេតុនៃការទម្លាក់គ្រាប់បែករបស់អាមេរិកាំងហ្នឹងឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ សំណួរនេះ សូមលើកម្តងទៀត បាទ ខ្ញុំមិនទាន់យល់ច្បាស់ទេ។

**ស៖** លោក សៅ សារុន ខ្ញុំយល់ហើយ គឺថាលោកមិនយល់សំណួរច្បាស់ទេ។

**លោក ហ្សាស្តេី ប៉ោ៖**

សូមការអនុញ្ញាតពីតុលាការ ពីលោកប្រធាន ខ្ញុំសូមឲ្យលោកបំភ្លឺឲ្យច្បាស់ គឺថាសូមបង្ហាញឯកសារមួយជូនលោក គឺឯកសារ D222/1.19។ គឺជាកំណត់ហេតុរបស់ ឌី.ស៊ី.ខេម ដែលគេបោះពុម្ពផ្សាយដែលនិយាយអំពីមណ្ឌលគិរី នៅក្នុងឆ្នាំ១៩៧០។ វាមានព័ត៌មានដែលជាចម្លើយរបស់មនុស្សដែលមកពីមណ្ឌលគិរី ដែលបាននៅទីនោះក្នុងសម័យនោះ។ ហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារនៅលើអេក្រង់គឺថា ចំណងជើងគឺថា "ការបោសសម្អាតខ្មែរក្រហមនៅខេត្តមណ្ឌលគិរី"។ សេចក្តីដកស្រង់ដែលចង់បង្ហាញនោះ គឺERN 00397610។

[១៣:៤៥:៣១]

**ប្រធានអង្គជំនុំ៖**

ជាបឋមលោកត្រូវបង្ហាញថាតើឯកសារនេះមាននៅក្នុងបញ្ជីឯកសារ ដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះហើយឬនៅ? ហើយបើដាក់ ៗពីអង្កាល់? ហើយនៅក្នុងបញ្ជីណាមួយនៃឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ?

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ដូចលោកជ្រាបហើយ គឺថាយើងគប្បីតែអាចប្រើឯកសារណាមួយ ដើម្បីសួរផ្ទាល់សាក្សី ដូចជាឯកសារមាននៅក្នុង ឌី.ស៊ី.ខេម។

[១៣:៤៦:១១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះដែលបានណែនាំភាគីដែលពាក់ព័ន្ធនឹងរឿងក្តីរួចហើយ អំពីឯកសារសម្រាប់សួរផ្តុញសាក្សី ដូចមាននៅក្នុងសេចក្តីណែនាំរបស់អង្គជំនុំជម្រះចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២។

ឯកសារណាមួយដែលភាគីមានបំណងប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះ ហើយឯកសារនោះពុំទាន់ទទួលបានចំណាត់ថ្នាក់ជាឯកសារ E3 ដែលត្រូវបានប្រើប្រាស់សម្រាប់ឯកសារនានា ដែលត្រូវបានដាក់ ឬត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬមិនត្រូវបានលើកឡើងនៅក្នុងបញ្ជីឯកសារណាមួយ ដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការដាក់ឯកសារថ្មី។

ដូច្នេះសូមលោកពិនិត្យលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ បើសិនជាមិនអនុវត្តតាមលក្ខខណ្ឌដែលអង្គជំនុំជម្រះសម្រេចនេះទេ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកលើកឯកសារមកដេញដោលស្រេចតែចិត្តនោះទេ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ដើម្បីកំណត់ត្រារបស់តុលាការ គឺជាការបំពានសិទ្ធិកូនក្តីរបស់ខ្ញុំ ប្រសិនបើខ្ញុំមិនបានសួរសំណួរនេះទេ បើសិនជាឯកសារនេះគឺស្ថិតនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា គឺឯកសារនោះគឺ E109/4.19 បាទ។ ហើយបើសិនជាព័ត៌មាននេះ ច្រំដែល យើងនឹងនិយាយពីឯកសារណាដែលវាមិនជាន់គ្នានោះបាទ។

[១៣:៤៨:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា នេះជាឯកសារដែលយើងបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ។ ហើយយើងខ្ញុំមិនជំទាស់ទេក្នុងចំណុចនេះ។ ការជំទាស់នោះគឺអាចទាក់ទងទៅនឹងកម្រិតនេះ គឺថាសំណួរសូមសួរទាក់ទងតែការដឹងរបស់សាក្សី ហើយមិនត្រូវប្រើសំណួរដើម្បីឲ្យគាត់ធ្វើសេចក្តីសន្និដ្ឋាន ឬក៏ឧបមាណវិធីទេបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះចង់ដឹងត្រឹមហ្នឹង។ ជាបឋមប្រសិនបើឯកសារដែលមិនមានលេខ E3 ទេ លោកត្រូវបង្ហាញអំពីភាពពាក់ព័ន្ធនៃឯកសារ ដែលនៅក្នុងបញ្ជីឯកសារដែលភាគីបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ទោះបីជាឯកសារផ្ទាល់ ឬឯកសារជាឧបសម្ព័ន្ធក៏ដោយ។ អង្គជំនុំជម្រះអនុញ្ញាត ប្រសិនបើនៅក្នុងលក្ខខណ្ឌនេះ។ ប៉ុន្តែលោកត្រូវចងចាំថា គប្បីធ្វើការបញ្ជាក់លើចំណុចនេះជាមុនសិន មុននឹងឲ្យអង្គជំនុំជម្រះពិនិត្យពិចារណាសម្រេចជាមុនសិន មុននឹងលោកលើកយកបញ្ហានៅក្នុងឯកសារទាំងនោះទៅដេញដោលចំពោះសាក្សី។

អង្គជំនុំជម្រះអនុញ្ញាត!

[១៣:៤៩:៤៣]

**លោក ហ្វាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំ ខ្ញុំនឹងប្រើឯកសារនេះដើម្បីបន្ត។ តើខ្ញុំត្រូវផ្តល់មូលហេតុដែលថា ឯកសារហ្នឹងសហព្រះរាជអាជ្ញាមិនជំទាស់ តើខ្ញុំចង់ដាក់ត្រូវសំណើដើម្បីប្រើឯកសារនេះជាឯកសារថ្មី ដែលខុសពីសហព្រះរាជអាជ្ញា ឬក៏លោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តសំណួរផ្អែកតែទៅលើសំណើរបស់ខ្ញុំនៅពេលនេះបាទ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតឲ្យលោកសួរដេញដោលតាមសំណើ ពីព្រោះសហព្រះរាជអាជ្ញាបានកត់សម្គាល់ហើយថាឯកសារនេះមាននៅក្នុងឯកសារឧបសម្ព័ន្ធ ដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ គ្រាន់តែកំហិតត្រឹមតែបញ្ហាណាដែលពាក់ព័ន្ធនឹងការដឹងដោយផ្ទាល់របស់សាក្សីរូបនេះបានហើយ។

[១៣:៥០:៤៩]

**លោក ហ្វាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ហើយដោយការអនុញ្ញាត ខ្ញុំនឹងប្រើឯកសារដូចដែលបង្ហាញនៅលើអេក្រង់នេះ គឺ ERN 003976 និង 10។ ហើយខ្ញុំនឹងអានផ្នែកពាក់ព័ន្ធ ដកស្រង់ជូនសាក្សីស្តាប់ដោយសារគាត់មិនអាចអានបាន។ ខ្ញុំសូមដកស្រង់ នេះគឺជាសេចក្តីប្រកាសរបស់ពួកពួង កុលសម្ព័ន្ធពួងនៅក្នុងខេត្តមណ្ឌលគិរីនៅក្នុងពេលនោះ។ សូមដកស្រង់សម្តីនេះ "ការទម្លាក់គ្រប់បែក ចាប់ផ្តើមដំបូង

គឺនៅចុងឆ្នាំ១៩៦០ អាមេរិកាំងចាប់ផ្ដើមសកម្មភាពនៅកម្ពុជា គឺប្រឆាំងវៀតណាម វៀតកុង គឺមិនមែនប្រជាជននៅកម្ពុជាទេ ពីព្រោះថា ជាប្រជាជនកម្ពុជា ពីព្រោះកម្ពុជាមិនមែនប្រឆាំងនឹងអាមេរិកាំងទេ។ លន់ នល់ បានធ្វើសំណើដើម្បីជំទាស់ សីហនុ។ ពេលនោះគ្រាប់បែកធ្លាក់រៀងរាល់ថ្ងៃ ហើយមេឃក្លាយទៅជាខ្មៅ ដោយអេលីកុបទ័រ ជាច្រើន ហើយមានកាំភ្លើងបាញ់ពីយន្តហោះខ្ទម្ភាគចក្រ បេ-៥២ ហើយមានទម្លាក់ផងដែរ និងបាញ់ផងដែរនៅអូរប៉ុល, ដាក់ដាំ ស្រុកដាក់ដាំ ហើយនិងនៅទួលស្វាយ, ហ្វូលី-- ហ្វូលូ, ពួនរុន, ឡាប់មិច ហើយនិងលំផាត់ ផងដែរ"។ ហើយនៅក្នុងទំព័រដដែលគឺបន្តទៅទៀតថា ហើយខ្ញុំនឹងអាន៖ "នៅពេលមួយកូនរបស់ខ្ញុំ និងប្រពន្ធរបស់ខ្ញុំបានរត់គេចពីយន្តហោះខ្ទម្ភាគចក្រដែលបាញ់ ហើយគេ ពេលដែលពួកយើងកំពុងកិនស្រូវ។ ពេលនោះ ខ្ញុំឃើញទាហានអាមេរិកាំង ដែលមកក្នុងភូមិរបស់យើង ហើយយន្តហោះនោះក៏បានទម្លាក់ជារៀងរាល់ថ្ងៃ នៅក្នុងចំពោះមុខអាមេរិកាំង ហើយពួក លន់ នល់ នោះ គឺយើងខ្លាចទាំងអស់។ នៅពេលនោះ វៀតកុង នៅជាមួយខាងសម្ដេចសីហនុ ហើយ លន់ នល់ នៅខាងអាមេរិកាំង។ លន់ នល់ បានសុំឲ្យអាមេរិកាំងទម្លាក់គ្រាប់បែកនៅកន្លែងជាច្រើននៅក្នុងកម្ពុជា។

[១៣:៥៣:១០]

ខ្ញុំខឹងចំពោះអ្នកណាដែលឲ្យមានការទម្លាក់គ្រាប់បែកបែបនេះ។ ហើយពួកគេបានទម្លាក់ទៅចំផ្ទះសម្បែងគោក្របី និងមាន់ទារបស់យើង"។ ចប់សេចក្ដីដកស្រង់។

**សួរដោយលោក ហ្វាស្តើ ប៉ោ៖**

**ស៖** សំណួរខ្ញុំសួរទៅលោក លោក សៅ សារុន។ នៅពេលនោះ នៅពេលដែលអាមេរិកាំងទម្លាក់គ្រាប់បែក តើលោកបានឮថា លន់ នល់ បានធ្វើសំណើសុំឲ្យគេទម្លាក់គ្រាប់បែកនៅមណ្ឌលគិរីដូចដែលសេចក្ដីថ្លែងការណ៍មួយអំមិញនេះដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ អត់ដឹងទេ ឃើញតែយន្តហោះមកទម្លាក់គ្រាប់បែកហ្នឹង ពាសពេញនៅក្នុងខេត្តមណ្ឌលគិរីហ្នឹង។ គេសុំសំណើអីអ៊ីចេះ អ៊ីចុះ យើងអត់ដឹងទេរឿងហ្នឹង ឃើញតែគ្រាប់បែកហ្នឹង ទម្លាក់រាល់យប់ រាល់ថ្ងៃ។ គាត់ ប្រជាពលរដ្ឋហ្នឹង លាក់ពួនក្នុងព្រៃ ព្រៃចាស់ ក៏ពួនមិនបាន កន្លែងព្រៃចាស់កាន់តែទម្លាក់ច្រើនទៀត។ ទម្លាក់-- លាក់ពួនទៅតាមព្រៃ ឬល្បោះល្បាស់បន្តិចបន្តួច ជីកត្រង់សេនៅ។ ពេលយប់ក៏ទម្លាក់ ពេលថ្ងៃក៏ទម្លាក់។ ពេលយប់ហ្នឹង ឲ្យតែឃើញភ្លើង គឺទម្លាក់ហើយ ឬក៏បាញ់ បាទ។

សូមអស់។

[១៣:៥៤:៥៦]

**ស៖** តើលោកឮប្រជាជននិយាយពីរឿងហ្នឹងទេ ទាក់ទងទៅនឹងហេតុផលដែលថា ពីមូលហេតុដែលអាមេរិកាំងទម្លាក់គ្រាប់បែកនោះបាទ លោកឮគេនិយាយទេ?

**ឆ៖** បាទ អត់ឮទេ ឃើញតែទម្លាក់អ៊ីចឹង។

**ស៖** សូមអរគុណលោក សៅ សារុន ហើយខ្ញុំនឹងចូលទៅប្រធានបទមួយផ្សេងទៀត។ នៅក្នុងនេះគឺយើងនិយាយអំពីការប្រជុំ ដែលលោកបានជួបនៅភ្នំពេញ។ ប្រហែលជា១០ថ្ងៃបន្ទាប់ពីការរំដោះទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥។ តើលោកនៅចាំដែរឬទេ ថាលោកបានឆ្លើយសំណួរដែលទាក់ទងទៅនឹងការប្រជុំទាំងអស់នោះនៅដើមអាទិត្យនេះ ហើយនិងអាទិត្យមុននោះ?

**ឆ៖** បាទ ដូចខ្ញុំបានរាយការណ៍ជូនលោកសហចៅក្រមរួចហើយ ច្បាស់លាស់ហើយ ហើយព្រះរាជអាជ្ញាក៏បាន ខ្ញុំក៏បានបញ្ជាក់រួចហើយបាទ។

**ស៖** បាទ លោក សៅ សារុន នោះគឺ នោះហើយជាចំណុចដែលខ្ញុំចង់សួរលោក។ តើលោកនៅចាំទេ ថាការប្រជុំទាំងនោះ ដែលបានកើតឡើងប្រហែលជា១០ថ្ងៃ ក្រោយពីការរំដោះទីក្រុងភ្នំពេញឆ្នាំ១៩៧៥ ខែមេសា នោះ?

**ឆ៖** បាទ អាហ្នឹងខ្ញុំបានចាំ។ ក្រោយរំដោះ៧៥ ហើយក៏បានមកប្រជុំ អាហ្នឹងខ្ញុំដូចខ្ញុំបានជម្រាបព្រះរាជអាជ្ញាហើយ រួចហើយ។

**ស៖** តើលោកនៅចាំទេ លោក សារុន ថាតើអ្នកណាជាអ្នកនិយាយ ជាអ្នកឧទ្ទេសនាមក្នុងអង្គប្រជុំនោះ?

[១៣:៥៧:៣៨]

**ឆ៖** បាទ គឺ ប៉ុល ពត។

**ស៖** តើមានអ្នកណាផ្សេងជាអ្នកធ្វើឧទ្ទេសនាមទេ ក្រៅពី ប៉ុល ពត តាមដែលលោកចាំនោះ?

**ឆ៖** បាទ តាមខ្ញុំចាំអត់មានទេ មានតែលោក ប៉ុល ពត ហ្នឹង។

**ស៖** កាលពីសប្តាហ៍មុន នៅពេលដែលការិយាល័យសហព្រះរាជអាជ្ញាសួរលោកអំពីបញ្ហានេះ អំពីការប្រជុំនេះ លោកនិយាយដូចខាងក្រោមនេះ ហើយខ្ញុំនឹងដកស្រង់ចេញពីប្រតិចារឹកនៅក្នុងទំព័រ ៣២ នៅក្នុងភាសាអង់គ្លេស សេចក្តីព្រាង ហើយនិងទំព័រ២៧ ជាអត្ថបទប្រតិចារឹកភាសាខ្មែរ នៅថ្ងៃទី

៧០ នៃសវនាការ។ ខ្ញុំសូមដកស្រង់ អ្វីដែលលោកនិយាយគឺក្នុងពេលនោះ នៅក្នុងវគ្គនោះ សហព្រះរាជ-អាជ្ញាបានសួរលោកថា ខ្ញុំដកស្រង់៖

"សូមលោកប្រាប់យើង ថាតើនរណាជាអ្នកធ្វើឧទ្ទេសនាមនៅក្នុងអង្គប្រជុំនេះ?" លោកបានឆ្លើយថា "ខ្ញុំបានឃើញ ប៉ុល ពត គឺជាអ្នកឧទ្ទេសនាមឯកសារ"។ សហព្រះរាជអាជ្ញាសួរ "ក្រៅពី ប៉ុល ពត តើមានអ្នកណាដែលនិយាយនៅក្នុងអង្គប្រជុំនោះ?" លោកឆ្លើយថា "អត់ឃើញទេ ឃើញតែគាត់ជាអ្នកឧទ្ទេសនាម មិនមានអ្នកផ្សេងទេ"។

សំណួរ តើលោកប្រកាន់យកចម្លើយពីររបស់លោកនេះថាត្រឹមត្រូវដែរឬទេ?

[១៣:៥៩:៣៩]

**ឆ៖** បាទ គឺជាត្រឹម-- គឺជាការត្រឹមត្រូវបាទ។

**ស៖** សូមអរគុណលោក សៅ សារុន។ ឥឡូវនេះខ្ញុំសូមសួរសំណួរមួយចំនួនអំពីការប្រជុំមួយផ្សេងទៀត ដែលលោកបានចូលរួមនៅក្នុងភ្នំពេញ។ ប្រជុំនោះគឺបានកើតឡើងពីរបីខែបន្ទាប់ពី ឡាំង គាត់ស្លាប់ទៅនោះ។ ហើយលោកបានឆ្លើយប្រាប់តុលាការនៅសហចៅក្រមស៊ើបអង្កេតថា សូមការអនុញ្ញាតពីលោកប្រធាន ហើយខ្ញុំសូមអនុញ្ញាតអានសេចក្ដីឆ្លើយតបរបស់គាត់នៅក្នុងឯកសារ E3/367 ERN 00278696 ហើយនិង ERN ជាភាសាអង់គ្លេស 00251439។ ខ្ញុំសូមអនុញ្ញាត ដើម្បីអានខ្លឹមសារដកស្រង់ចេញពីឯកសារនេះលោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ក្នុងឯកសារនេះ នៅក្នុងចម្លើយរបស់លោកនោះ លោកបាននិយាយថា "ប្រហែលពីរបីខែក្រោយពី ឡាំង និង ខាំ ភូន ស្លាប់ ខ្ញុំបានទទួលទូរលេខមកពី ប៉ុល ពត ថាឲ្យទៅប្រជុំក្នុងនោះខ្លឹមសារគឺហៅខ្ញុំ តារៀង, តាលក, តាគីម, តាឡាន់ និងតាសុភា ទាំងប្រាំមួយនាក់ទៅប្រជុំនៅភ្នំពេញ"។ ចប់សេចក្ដីដកស្រង់។ តើលោកនៅចាំទេ ថាលោកបានទៅចូលរួមប្រជុំនោះ នៅភ្នំពេញលោក សៅ សារុន?

[១៤:០១:៣៤]

**ឆ៖** បាទ បានចាំ គឺហៅទៅប្រជុំមែន។

**ស៖** លោក សារុន តើលោកចាំដែរឬទេថា តើមានអ្នកណាខ្លះដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** បាទ ច្រើន គ្រប់ខេត្ត គ្រប់កងពលគឺមកប្រជុំ អាហ្នឹងហើយគឺ២០០៨ ហើយអាហ្នឹង អ៎! ១៩៧៨ ប្រជុំសន្និបាតអាហ្នឹង។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ ដែលថាយើងនិយាយអំពីកិច្ចប្រជុំដូចគ្នានុ៎ង ថាតើកិច្ចប្រជុំហ្នឹងគឺកិច្ចប្រជុំ ដែលកើតឡើងប្រហែលជាពីរបីខែក្រោយពេល តាឡាំង ហើយនិង ខាំ ភួន ស្លាប់តើមែនទេ?

**ឆ៖** បាទ មែនដូចខ្ញុំបញ្ជាក់លោកសហាចៅក្រមនោះហើយ។

[១៤:០៣:០៥]

**ស៖** តើលោកចងចាំដែរឬទេ? តើមេដឹកនាំណាខ្លះដែលបានចូលរួម នៅក្នុងមហាសន្និបាតនោះ?

**ឆ៖** បាទ ខ្ញុំយល់គណៈចាត់តាំង គេហៅឡើងវេទិកាប៉ុណ្ណឹងទេ បានខ្ញុំដឹងបាទ។

**ស៖** តើលោកចាំឈ្មោះរបស់មេដឹកនាំនានា ដែលមានវត្តមាន ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំដឹងគឺគណៈចាត់តាំងគេហៅឈ្មោះនេះ ឈ្មោះនោះឡើងវេទិកា។ ខ្ញុំដឹងតែប៉ុណ្ណឹងបាទ។

**ស៖** តើលោកចាំឈ្មោះមេដឹកនាំ ដែលមានវត្តមាននៅទីនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំដឹងឈ្មោះ គឺតាមគណៈចាត់តាំងទេបាទ។

[១៤:០៤:៣៩]

**ស៖** តើក្នុងពេលនេះ លោកអាចចាំឈ្មោះមេដឹកនាំនោះបានដែរឬទេ? លោកអាចចាំឈ្មោះពួកគាត់នោះដែរឬទេ?

**ឆ៖** បាទ ចាំ មាន ប៉ុល ពត, មានលោក នួន ជា, លោក អៀង សារី ដែលគណៈចាត់តាំងគេហៅឈ្មោះឡើងវេទិកា បាទ។

**ស៖** ខ្ញុំគិតថា ប្រហែលជាមានការច្រឡំបន្តិចបន្តួច ទាក់ទងទៅនឹងកិច្ចប្រជុំ ដែលលោកកំពុងតែនិយាយ។ ដូច្នេះ ខ្ញុំសូមលើកយកបញ្ហានេះ ទៅទុកនៅពេលក្រោយបន្តិចទៀតសិន។ ដូច្នេះ ឥឡូវនេះ យើងផ្អាកទៅលើបញ្ហានេះបន្តិច។ ប្រធានបទមួយទៀត ដែលខ្ញុំចង់លើកយកមកពិភាក្សាគឺថា ខាង

ព្រះរាជអាជ្ញា និងខាងដើមបណ្ដឹងរដ្ឋប្បវេណី បាននិយាយអំពីទូរលេខ គឺទូរលេខដែលបានបញ្ជូន ដោយលោកទៅខាងមជ្ឈិមនៅភ្នំពេញ។ តើលោកនៅចងចាំដែរឬទេថា លោកបានឆ្លើយទៅនឹងសំណួរទាក់ទងទៅនឹងទូរលេខហ្នឹងកាលពីសប្ដាហ៍មុន? តើលោកមានបានចងចាំដែរឬទេ?

[១៤:០៦:២៥]

**ឆ៖** បាទ ដូចខ្ញុំជម្រាប លោកព្រះរាជអាជ្ញានោះរួចហើយតើ! រួចហើយ។

**ស៖** ដូច្នេះ តើលោកមានចងចាំ ថាតើខាងមជ្ឈិមហ្នឹង លោកទទួលទូរលេខខាងមជ្ឈិមហ្នឹង គឺអ្នកណា ដែលលោកទទួលទូរលេខមកពីខាងមជ្ឈិមនោះ?

**ឆ៖** បាទ ទទួលតាម អាហ្នឹងគឺមកពី ប៉ុល ពត បាទ។

**ស៖** នៅក្នុងសក្ខីកម្មរបស់លោក ដែលបានផ្ដល់ពីកាលម្សិល-- កាលពីសប្ដាហ៍មុនគឺថ្ងៃទី៧១នៃសវនាការ។ ខ្ញុំសូមដកស្រង់ពីប្រតិចារឹក ហើយប្រតិចារឹកគឺទំព័រ២០ ជាភាសាអង់គ្លេស និងទំព័រ១៧ ជាភាសាខ្មែរ។ ហើយខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោកដែលសួរដោយខាងព្រះរាជអាជ្ញា។ ខាងព្រះរាជអាជ្ញាបានសួរលោកថា "នៅពេលដែលលោកទទួលបានចម្លើយតប ដោយមានសេចក្ដីណែនាំ ថាតើអ្នកណាជាអ្នកបញ្ជូននូវចម្លើយតបនោះមកលោក?" ហើយចម្លើយតបលោក គឺថា "ការណែនាំត្រូវបានផ្ដល់ឲ្យតាមរយៈទូរលេខ។" ហើយខាងព្រះរាជអាជ្ញាបានសួរទៀតថា តើលោកចាំដែរឬទេ តើអ្នកណាជាអ្នកបញ្ជូននូវទូរលេខ ឬក៏បញ្ជូននូវការណែនាំ ដែលជាការឆ្លើយតបទៅនឹងទូរលេខរបស់លោក។ តើអ្នកណាដែរ ដែលជាអ្នកផ្ញើមកវិញ?" ចម្លើយ "បាទ អ្នកហ្នឹង ខ្ញុំអត់ស្គាល់ទេ។ ដឹងពីណាៗ គេសម្គាល់តែអ្នកគេខាងទូរលេខទេបាទ។" តើលោកអាចបញ្ជាក់បានទេថា ចម្លើយនេះជាចម្លើយដែលត្រឹមត្រូវ គឺជាចម្លើយដែលត្រឹមត្រូវ ដែលលោកបានផ្ដល់កាលពីសប្ដាហ៍មុន?

[១៤:០៨:៤០]

**ឆ៖** បាទចម្លើយហ្នឹងគឺជាការត្រឹមត្រូវ ដូចខ្ញុំបញ្ជាក់លោកព្រះរាជអាជ្ញាហ្នឹងហើយ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងបន្តទៅប្រធានបទថ្មីមួយទៀត។ លោក សារុន ព្រះរាជអាជ្ញាបានចោទសួរលោកថា "តើលោកមានការស្ទាក់ស្ទើរ ឬទេនៅក្នុងការផ្ដល់សក្ខីកម្មប្រឆាំងនឹងជនជាប់ចោទ?" ហើយលោកបានបញ្ជាក់ថា លោកមិនមានការលាក់លៀម មិនមានការលាក់លៀមនោះទេក្នុងការធ្វើសក្ខីកម្មប្រឆាំងនឹងជនជាប់ចោទ។ លោក សារុន ថាតើលោកមានការលាក់លៀមដែរឬទេក្នុងការផ្ដល់សក្ខីកម្ម ទាក់ទងទៅនឹងតួនាទីរបស់លោក នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ផ៖** បាទ ខ្ញុំអត់មានស្ទាក់ស្ទើរអីទេ គឺខ្ញុំយល់ ខ្ញុំដឹងប៉ុណ្ណឹង គឺខ្ញុំរាយការណ៍ជូនព្រះរាជអាជ្ញាប៉ុណ្ណឹងបាទ។

[១៤:១០:១៧]

**លោក ហ្សាស្តេ ប៉ោះ**

ខ្ញុំចង់ដកស្រង់នូវឯកសារ គឺឯកសារដដែល ដែលយើងបានពិភាក្សាកាលពីមុននេះ គឺជាឯកសារបោះពុម្ពផ្សាយរបស់កម្ពុជា-- របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារដែលមានលេខ D222/1.19 មានលេខ ERN 00397654 ហើយខ្ញុំសូមបង្ហាញនៅលើអេក្រង់ ហើយនិងទូរទស្សន៍ ហើយខ្ញុំនឹងបន្តការសាកសួរទៅលើសាក្សី។ គឺឯកសារដែលមានចំណងជើងថា "ការបោសសម្អាតដោយខ្មែរក្រហមនៅខេត្តមណ្ឌលគិរី"។

[១៤:១១:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១២:៣៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា តើឯកសារ D222/1.19 នេះមានជាភាសាខ្មែរឬក៏ភាសាបារាំងដែរឬទេ?

**លោក ហ្សាស្តេ ប៉ោះ**

លោកប្រធាន ខ្ញុំគិតថាប្រហែលជាមិនមានបញ្ហាទេ ព្រោះខ្ញុំអាចអានឲ្យសាក្សីស្តាប់ ហើយខ្ញុំអានដោយយឺតៗ ហើយគេអាចបកប្រែបានយ៉ាងស្រួលទៅជាភាសាដទៃទៀត។ ដូច្នេះ ឯកសារដែលខ្ញុំពឹងផ្អែកគឺខ្ញុំបានប្រើកាលពី ២០នាទីមុនហើយ។ ហើយខាងសហព្រះរាជអាជ្ញាក៏អត់មានជំទាស់ដែរ។ ហើយឯកសារមួយនេះគឺនិយាយអំពីតួនាទីផ្ទាល់របស់លោក សៅ សារុន។ ហើយខ្ញុំគិតថា ឯកសារដែលមិនមានការបកប្រែគ្រប់ភាសាហ្នឹង គឺខាងដើមរដ្ឋប្បវេណីក៏ប្រើប្រាស់ផងដែរ។ ដូច្នេះ ខ្ញុំគិតថាខ្ញុំអាចបន្តទៅមុខបាន ហើយខ្ញុំអាចនឹងសង្ខេបឯកសារហ្នឹង។ ហើយខ្ញុំគិតថាខ្ញុំអាចអាននូវឯកសារហ្នឹង ហើយបន្ទាប់មកខ្ញុំសួរសំណួរដោយផ្អែកទៅលើឯកសារនេះបាន។ ខ្ញុំគិតថាវាមិនមែនជារឿងដែលមានការខ្វែងគំនិត ឬក៏មានការជំទាស់អ្វីនោះឡើយ។

**ប្រធានអង្គជំនុំ៖**

ទំនងអត់ស្តាប់សំណួរយើងបានទេ។ យើងសួរលោកថា តើមាន-- ឯកសារហ្នឹងមានបកប្រែជាភាសាខ្មែរ ឬភាសាបារាំង ដែរឬទេ? នេះជាសំណួររបស់យើង។ យើងមិនឲ្យលោកមេធាវីពន្យល់យើងអំពីបញ្ហានេះទេ។

[១៤:១៤:១៦]

លោកស្តាប់សំណួរយើងបានទេ? សំណួរឡើងវិញ សួរថា តើឯកសារ D222/1.19 ដែលលោកកំពុងតែដាក់ដេញដោលចំពោះសាក្សីនេះ តើមានការបកប្រែជាភាសាខ្មែរ-- ឯកសារជាភាសាខ្មែរ ឬជាភាសាបារាំងដែរឬទេ? នេះជាសំណួររបស់យើង។

**លោក ហ្សាស្តេ ប៉ោះ៖**

ខ្ញុំគិតថា ខ្ញុំអាចឆ្លើយបានតាមដែលខ្ញុំដឹង គឺអត់មានបកប្រែជាភាសាខ្មែរ និងជាភាសាបារាំងនោះទេ។ ហើយមិនមាននៅក្នុងសំណុំរឿងនោះឡើង ប៉ុន្តែជាថ្មីម្តងទៀត គឺខាងព្រះរាជអាជ្ញាបានដាក់សំណើ-- បានដាក់ឯកសារនេះឲ្យចូលទៅ-- សូមឲ្យអង្គជំនុំជម្រះធ្វើការពិចារណា។ ដូច្នេះ ខ្ញុំសង្ឃឹមថាឯកសារនេះ មិនមានបញ្ហា។

[១៤:១៥:០៨]

**ប្រធានអង្គជំនុំ៖**

បាទ នេះជាករណីពិសេស ហើយយើងអនុញ្ញាត ប៉ុន្តែត្រូវឆ្លើយតបនឹងសំណួររបស់យើងជាមុន។ យើងអនុញ្ញាត។ ហើយសូមឲ្យដកស្រង់នូវផ្នែកសង្ខេបខ្លីៗ ដកស្រង់ខ្លីៗ ដើម្បីងាយបកប្រែ ហើយដើម្បីសាក្សីនេះ ងាយយល់អំពីខ្លឹមសារនៃឯកសារដែលលោកដកស្រង់មកសួរដេញដោលគាត់។ តែប៉ុណ្ណឹងទេបញ្ហា។

**លោក ហ្សាស្តេ ប៉ោះ៖**

សូមអរគុណលោកប្រធាន ចំពោះការពន្យល់បង្ហាញនេះ។ ហើយខ្ញុំសូមអភ័យទោសដែលខ្ញុំមិនមានទំនុកចិត្តគ្រប់គ្រាន់ទៅលើបញ្ហានេះ។ ដូច្នេះ ខ្ញុំសូមបន្តដោយសង្ខេប ដោយធ្វើការដកស្រង់នូវឯកសារនេះ ហើយខ្ញុំសូមបញ្ជាក់នូវលេខ ERN គឺ 00397654 ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។

[១៤:១៦:២២]

គឺយើងចាប់ផ្ដើមនៅទំព័រទី៨0 គឺ7653 ហើយឯកសារនេះ ចាប់ផ្ដើមដោយខ្ញុំដកស្រង់ដូចតទៅ លោក សៅ សារុន សូមលោកស្ដាប់នូវអ្វីដែលខ្ញុំអាន ហើយខ្ញុំនឹងចោទសំណួរ។ ខ្ញុំសូមដកស្រង់ដូចតទៅ៖ "នៅពេល-- ដោយៗ ហម គាត់ស្ដាប់ លោក សារុន ដែលជាជនជាតិភាគតិច ជនជាតិឡាវ បានក្លាយជាលេខាតំបន់១០៥។ ជម្លោះ វរាង ខាំ ភូន ហើយនិង ហម ហើយនិងការតែងតាំងលោក សារុន ជាមេដឹក-- ជាអ្នកដឹកនាំតំបន់ នាំដោយមានការរឹតបន្តឹងនូវវិធានយ៉ាងធ្ងន់ធ្ងរនៅក្នុងតំបន់ ហើយស្រប ជាមួយនឹងរយៈពេលនៃការសម្លាប់មនុស្សយ៉ាងច្រើន ការសម្លាប់យ៉ាងរង្គាល។ អ្នកផ្ដល់ព័ត៌មានជាច្រើនបានបង្ហាញអំពីការចាប់ផ្ដើមនៃការផ្លាស់ប្ដូរយ៉ាងខ្លាំងក្លាបំផុត នៅក្នុងខេត្តមណ្ឌលគិរី នៅចុង៧៧ និង៧៨ នៅពេលដែលលោក សារុន ឡើងកាន់អំណាច"។ ហើយចំណុចបន្ទាប់ដែលខ្ញុំអានជូនលោកគឺនៅក្រោយនេះ ហើយចំណុចនេះ គឺដកស្រង់ចេញពីសាក្សីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា "បន្ទាប់ពីលោក សារុន ក្លាយជាលេខាតំបន់ ពួកគេចាប់ប្រជាជនជារៀងរាល់ថ្ងៃ ប្រហែលជាបួនទៅប្រាំនាក់ជារៀងរាល់ថ្ងៃ។ ប្រធានសហករណ៍ព្យាយាមបង្ខិតបង្ខំប្រជាជនធ្វើការកាន់តែធ្ងន់ធ្ងរឡើង ហើយដោយប្រាប់ពួកគេថា លោក សារុន នឹងសម្លាប់ប្រជាជនដែលខ្ជិលច្រអូស"។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** សំណួររបស់ខ្ញុំដែលចង់សួរលោកគឺថា តើលោកអាចបញ្ជាក់បានដែរឬទេ ថាអ្វីដែលនិយាយនៅក្នុងឯកសារនេះ គឺនៅពេលដែលលោកមានតួនាទីជាលេខាតំបន់ គឺវាជួនគ្នានឹងពេលដែលមានការសម្លាប់យ៉ាងរង្គាល តើវាត្រឹមត្រូវដែរឬទេ?

[១៤:១៨:៣៥]

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ បញ្ហាហ្នឹងគឺអត់មែន-- អត់ត្រឹមត្រូវទេ។ អ្នករាយការណ៍ហ្នឹង គឺជាអ្នករាយការណ៍មួលបង្កាច់ ដើម្បីសម្លាប់ខ្ញុំទេ។ ខ្ញុំមិនដែលឃើញ មិនដែលដឹងរឿងចាប់រង្គាល សម្លាប់ប្រជាពលរដ្ឋនេះ អត់ៗដឹង។ បញ្ហានេះ គឺខ្ញុំសូមបដិសេធ។

**ស៖** លោក សារុន ការដកស្រង់នេះ គឺនាំឲ្យខ្ញុំចោទសួរលោកថា ថាតើលោកមានតួនាទីខ្លាំងក្លាសកម្មជាងមុន មុនពេលដែល-- គឺធៀបជាមួយនឹងអតីតមេ គឺ តាឡាំង ហ្នឹង ក្នុងការសម្លាប់មនុស្សដែរឬទេ?

**ឆ៖** បាទ អត់ទេ។ ខ្ញុំឡើងកាន់តួនាទី តែពីរខែទេ។ ខែ១០ ខែ១១ ខែ១២ ខែ១ គឺចប់ប៉ុណ្ណឹង។ អត់ដែលថា ខ្ញុំវាខ្លាំងក្លា ចាប់ប្រជាពលរដ្ឋរាប់សិប រាប់រយ អត់មាន អាហ្នឹងគឺ ដូចខ្ញុំអំមិញ និយាយមិញ គឺសូមបដិសេធ។ អាហ្នឹងគេរាយការណ៍មួលបង្កាច់ខ្ញុំទេ។

[១៤:១៩:៥៨]

**ស៖** សូមអរគុណលោក សារុន។ មានអ្នកចេះដឹងមួយរូបទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ គឺលោក ស្ទីវ ហេដឌ័រ បានសរសេរនូវអត្ថបទមួយ ដែលនិយាយអំពីតួនាទីរបស់កម្មាភិបាលថ្នាក់ទាប និងថ្នាក់កណ្តាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយនៅក្នុងអត្ថបទរបស់គាត់នេះ គាត់បានបញ្ជាក់ថា ហើយខ្ញុំសូមដកស្រង់៖"នៅក្នុងការអនុវត្តជាក់ស្តែង កម្រិតដែលសំខាន់បំផុតនៅក្នុងការបញ្ជា ហើយនិងនៅក្នុងឋានានុក្រមនៃអំណាចនៅក្នុង គឺជាទូទៅ គឺជាឋានៈស្រុក នៅឋានៈស្រុក គឺជាលេខាបក្សស្រុក គឺមានតួនាទីយ៉ាងសំខាន់នៅក្នុងសម្លាប់នៅទូទាំងប្រទេស"។

សំណួររបស់ខ្ញុំ ដែលចង់ចោទសួរ គឺថាលោក សារុន ផ្អែកទៅលើការស្រាវជ្រាវរបស់លោក ស្ទីវ ហេដឌ័រ គាត់បានសន្និដ្ឋានថា លេខាស្រុក គឺជាតួនាទីដ៏សំខាន់នៅក្នុងការសម្លាប់នៅទូទាំងប្រទេស។ ព្រោះថាពួកគាត់មានសិទ្ធិអំណាចជាឯកច្ឆន្ទ គឺសិទ្ធិអំណាចផ្ទាល់ខ្លួន។ ថាតើលោកអាចប្រាប់ទេ ថាតើលេខាស្រុកហ្នឹង តើលោកយល់ស្របដែរឬទេ ជាមួយនឹងការរកឃើញ ជាមួយនឹងការស្រាវជ្រាវឃើញរបស់លោក ស្ទីវ ហេដឌ័រនេះ។ តើលោកសាក្សីយល់ស្របជាមួយនឹងការយល់ឃើញនេះដែរឬទេ?

[១៤:២១:៤៦]

**ឆ៖** បាទ ខ្ញុំអត់យល់ នៅទូទាំងប្រទេស ខ្ញុំអត់យល់ទេ។ ខ្ញុំអត់យល់ស្របទេ ពីព្រោះស្រុកគេផ្សេង ស្រុកខ្ញុំផ្សេង ខេត្តគេផ្សេង ខេត្តខ្ញុំផ្សេង ខ្ញុំអត់យល់ស្របទេ។

**ស៖** សូមអរគុណ។ លោក ហេដឌ័រ នៅក្នុងអត្ថបទដូចគ្នាក៏បាននិយាយថា អ្នកទោសភាគច្រើនត្រូវគេសម្លាប់ មិនយូរក៏ឆាប់នៅក្នុងនៃសិទ្ធិអំណាចរបស់ខាងផ្នែកស្រុក។ បើតាមបទពិសោធន៍របស់លោក នៅក្នុងស្រុករបស់លោកផ្ទាល់ហ្នឹង តើអ្នកទោសហ្នឹងត្រូវបានគេសម្លាប់ដោយសេចក្តីសម្រេចដោយសិទ្ធិសម្រេចរបស់ថ្នាក់ស្រុក តើមែនឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ក្នុងស្រុករបស់យើងខ្ញុំ មិនដែលចាប់ជនណាម្នាក់មកធ្វើជាអ្នកទោសទេបាទ។

**ស៖** លោក សារុន តើលោកមានរាយការណ៍ទៅមេដឹកនាំនៅទីក្រុងភ្នំពេញអំពីការសម្លាប់ដែលកើតឡើងនៅក្នុងស្រុករបស់លោកដែរឬទេ នៅពេលដែលលោកជាលេខាស្រុកនោះ?

**ឆ៖** បាទ អត់មានទេ។ ខ្ញុំក៏មិនបានរាយការណ៍ពីរឿងចាប់ រឿងសម្លាប់ប្រជាពលរដ្ឋទេបាទ អត់។

[១៤:២៣:៣៩]

**ស៖** លោក សារុន តើលោកមានរាយការណ៍ទៅមេដឹកនាំនៅក្រុងភ្នំពេញអំពីការសម្លាប់ដែលកើតឡើងនៅក្នុងតំបន់របស់លោកដែរឬទេ នៅពេលដែលលោកជាលេខាតំបន់ គឺជាមេតំបន់នោះ?

**ឆ៖** បាទ តាំងពីខ្ញុំមកកាន់តំណែងជាលេខាតំបន់ពីរខែ ខ្ញុំមិនដែលរាយការណ៍ថា រឿងចាប់ រឿងសម្លាប់ប្រជាពលរដ្ឋទេបាទ។

**ស៖** សូមអរគុណ។

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមសាកសួរអំពីអត្ថបទមួយចំនួនទៀតទាក់ទងទៅលើបញ្ហានេះ ប៉ុន្តែខ្ញុំសូមអនុញ្ញាតដល់អង្គជំនុំជម្រះ ដើម្បីចោទសួរសាក្សីទាក់ទងទៅនឹងចម្លើយរបស់សាក្សី306-- 307 សូមអភ័យទោស គឺចម្លើយរបស់សាក្សី307 ដែលនិយាយពាក់ព័ន្ធទៅនឹងបញ្ហាដែលលោក សៅ សារុន កំពុងតែនិយាយនេះ គឺចម្លើយពាក់ព័ន្ធទៅនឹងការយល់ដឹងរបស់សាក្សីដែលៗ ថាបង្ហាញថាសាក្សីហ្នឹង គាត់មានការនិយាយកុហក។ ហើយខ្ញុំសូមលើកយកឯកសារនេះ ដើម្បីដេញដោលជាមួយនឹងលោក សៅ សារុន។

[១៤:២៥:២០]

កាលពីសប្តាហ៍មុន ខាងព្រះរាជអាជ្ញាក៏បានប្រើប្រាស់នូវចម្លើយរបស់សាក្សីមួយចំនួនផងដែរ។ ប៉ុន្តែខ្ញុំគិតថា ការចោទសួរបែបនេះ គឺវាអាចនាំទៅដល់ការទទួលបានព័ត៌មានយ៉ាងល្អ ដែលថាលោក សារុន គាត់អាចជំទាស់ ឬក៏អាចប្រឈមមុខឆ្លើយតទល់ជាមួយនឹងសំណួរទាំងអស់នេះ។ ហើយបន្ទាប់មក យើងសុំអនុញ្ញាតថា នឹងប្រើប្រាស់ឯកសារនេះ ហើយខ្ញុំនឹងនិយាយយោងទៅលើឯកសារនេះ ដែលប្រើប្រាស់ឈ្មោះរហស្សនាមរបស់សាក្សីនោះទេ។ ហេតុដូច្នេះហើយ ខ្ញុំគិតថា យើងមិនប្រាកដថា តើយើងអាចនឹង-- នៅពេលដែលសាក្សីហ្នឹង គាត់បង្ហាញមុខឡើង តើគាត់អាចនឹងប្រឈមជាមួយនឹងលោក សៅ សារុន បានឬអត់នោះទេ។ ដូច្នេះខ្ញុំគិតថា ឯកសារនេះជាការសំខាន់ ដែលខ្ញុំត្រូវលើកយកមកដើម្បីសួរដេញដោលជាមួយលោក សៅ សារុន ហើយខ្ញុំសូមលោក សូមអង្គជំនុំជម្រះមេត្តាសម្រេចទៅលើបញ្ហានេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៨:២៧]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះអង្គជំនុំជម្រះបានស្តាប់នូវសំណើសុំរបស់លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ដែលមានការស្នើសុំអង្គជំនុំជម្រះ សាមីខ្លួនហ្នឹងលើកយកនូវឯកសារស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-307 មកដេញដោលចំពោះសាក្សីរូបនេះ។ តើមានភាគីផ្សេងទៀត ដែលមានការពាក់ព័ន្ធក្នុងរឿងក្តីនេះមានមតិយោបល់យ៉ាងម៉េចដែរ?

ខាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធាន តុលាការបានបញ្ជាក់កាលពីមុននៅក្នុងសេចក្តីសម្រេចដែលថា-- ខ្ញុំសូមទោសខ្ញុំនឹងបន្តនូវចម្លើយរបស់ខ្ញុំ គឺថាតុលាការបានសម្រេចរួចទៅហើយកាលពីពេលមុនថា ចម្លើយតបរបស់សាក្សីដែលនឹងមិនផ្តល់សក្ខី អាចប្រើប្រាស់បាន ហើយហេតុផលដែលៗបានសម្រេចហ្នឹង គឺខាងអង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចទៅហើយ។ ដូច្នេះតាមគំនិតរបស់ខាងព្រះរាជអាជ្ញា គឺមិនមានការជំទាស់នោះទេ ប្រសិនបើខាងសាលាដំបូងយល់ស្របថា ជារឿងសមស្រប។

ហើយម្យ៉ាងទៀត ចម្លើយហ្នឹងគឺវាពាក់ព័ន្ធទៅនឹងកាលយល់ដឹងរបស់សាក្សី ហើយសាក្សីនុំងមិនត្រូវបានកំណត់បញ្ជាក់។ ដូច្នេះនៅពេលដែលមានអ្វីដែលសមគ្រប់រួចរាល់អស់ហើយ គឺយើងមិនមានការជំទាស់នោះឡើយ ប៉ុន្តែនេះគឺជាឆន្ទានុសិទ្ធិ ដូចដែលខាងអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនកាលពីពេលមុនរួចមកហើយ។

[១៤:៣០:៤៤]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ចំពោះយើងក៏យើងមិនជំទាស់ដែរ ព្រោះថាភាគីទាំងអស់ ទទួលបានសិទ្ធិដូចគ្នា។ សូមតែប៉ុណ្ណឹងទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ដោយជាសំណើសុំសមស្របផង ហើយគ្មានការជំទាស់ពីភាគីផង អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យមេធាវីការពារក្តីលោក នួន ជា អាចប្រើប្រាស់ខ្លឹមសារនៃឯកសារកំណត់ហេតុស្តាប់សក្ខីកម្មសាក្សី TCW-307 នេះមកដេញដោលសាក្សីនេះបាន។ ប៉ុន្តែសូមឲ្យប្រើប្រាស់តែកម្រិតត្រឹមតែរហស្សនាម

របស់សាក្សីនេះប៉ុណ្ណោះ។

**លោក ហ្សាស្តើ ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសូមអនុញ្ញាតបន្ត ប៉ុន្តែទាក់ទងទៅនឹងចម្លើយមួយនេះ គឺថាអាចនឹងមានសំណួរមួយចំនួន ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅក្នុង-- នៅលើអេក្រង់នោះផងដែរ។ ប្រសិនបើខ្ញុំមិនអាចបញ្ចប់នៅពេលនេះ គឺថាបន្ទាប់ពីសម្រាកនឹងតទៀតបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣២:៥៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី តើលោកធានាថា ការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រហ្នឹង វាបែកព័ត៌មានដែលនាំឲ្យមានចេញនូវព័ត៌មានស្គាល់ឈ្មោះពិត សាក្សី TCW-307 ដែរឬទេ? ឬក៏លោកមានការកោសលុបរួចហើយ នៅក្នុងឯកសារដែលលោកមានការស្នើសុំ ដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័រនាពេលនេះ?

**លោក ហ្សាស្តើ ប៉ោះ**

សូមអរគុណលោកប្រធានដែលលោកបានបញ្ជាក់ គឺថាមុននឹងខ្ញុំចង់ជម្រាបតុលាការថា វាអាចប្រសើរជាងដើម្បីការពារការសម្ងាត់នោះ ប្រសិនបើខ្ញុំអានចេញពីសេចក្តីដកស្រង់នេះជាមុនសិន មុននឹងឲ្យសាក្សីឆ្លើយ ដើម្បីកុំឲ្យទម្លាយនូវព័ត៌មានសម្ងាត់នេះ។ នេះជាវិធីដែលត្រឹមត្រូវដែលខ្ញុំចង់សួរ ហើយនិងជម្រាបតុលាការ ដើម្បីការពារនូវព័ត៌មានសម្ងាត់។ នេះហើយជាវិធីដែលខ្ញុំស្នើសុំបន្តតាមវិធីនេះបាទ។

[១៤:៣៤:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ហ្សាស្តើ ប៉ោះ**

សូមអរគុណលោកប្រធាន។

ឥឡូវនេះ ខ្ញុំនឹង-- ខ្ញុំមិនសូមការអនុញ្ញាតដើម្បីបង្ហាញលើអេក្រង់ទេ គឺចម្លើយនេះគឺថា D200/4 ក៏មានឯកសារ E3/57 ERN ជាភាសាអង់គ្លេសហ្នឹង អឺ! ខ្មែរ ERN គឺ 00287705។ សូមអភ័យទោស

ខ្ញុំមិនមាន ERN ជាភាសាអង់គ្លេសទេ អ៊ំ បារាំងទេ។

[១៤:៣៥:០០]

**សួរដោយលោក ហ្សាស្តេី ប៉ោះ៖**

**ស៖** នៅក្នុងចម្លើយនេះ លោក សារុន សាក្សីមួយនោះគឺសាក្សី 307 គេបានសួរសាក្សីនោះ អំពីតំបន់១០៥ ហើយខ្ញុំដកស្រង់សំណួរទៅសាក្សីនោះ ហើយជាសំណួរដែលសហចៅក្រមស៊ើបអង្កេត សួរទៅសាក្សី 305 "សំណួរ តើលោកស្គាល់-- ដឹងអំពីការសម្លាប់នៅក្នុងតំបន់របស់លោកដែរឬទេ?"។ ផ្នែកមួយ នៃចម្លើយរបស់សាក្សីនោះ ឆ្លើយថា "នៅអំឡុងពេលដែល សារុន គ្រប់គ្រងគឺមានការចាប់ខ្លួន គ្រួសារទាំងមូល ប៉ុន្តែខ្ញុំមិនដឹងថា គេយកគ្រួសារទាំងមូលនោះ យកទៅសម្លាប់កន្លែងណាទេ។" លោក សៅ សារុន តើលោកនៅចាំដឹងទេ នៅពេលដែលលោកគ្រប់គ្រងនៅក្នុងតំបន់នោះថា មានការខ្លួន មនុស្សមួយគ្រួសារទាំងមូលអ៊ីចឹងដែរទេ បែបហ្នឹងដែរឬទេ?

[១៤:៣៦:២៩]

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺអត់មានទេ មិនដែលចាប់ជនណា គ្រួសារទាំងមូលៗទៅសម្លាប់ទេ បាទ។ អាហ្នឹងជាការ អ្នករាយការណ៍ហ្នឹង ជាអ្នករាយការណ៍មួលបង្កាច់ទេបាទ។ ខ្ញុំសូមបដិសេធ ខ្ញុំមិនដែលចាប់ មិនដែលចង មិនយក-- មិនដែលយកប្រជាពលរដ្ឋទៅសម្លាប់ទេបាទ។

**ស៖** ហើយនៅខាងក្រោមនោះបន្តិច នៅក្នុងឯកសារដដែល គឺសាក្សីដដែល សាក្សី307 សហចៅក្រមសួរទៅគាត់ថា "តើអ្នកទោសគេយកពីតំបន់ណាខ្លះ?" គាត់ឆ្លើយថា "អ្នកទោសគឺយកមកពីតំបន់១០៥ តាមស្រុក។ អ្នកទោសភាគច្រើន គឺគេចោទថា ជាអ្នកធ្វើមន្តអាគម អូមអាម អាប ហើយ គេចាប់យកទៅដាក់មន្ទីរសន្តិសុខនេះតែម្តង។ តើត្រឹមត្រូវដែរទេ? មានកងទ័ពត្រូវបានគេចាប់យកមក ដាក់ទីនោះដែរ។" លោក សៅ សារុន តើលោកនៅចាំដែរឬទេថា នៅក្នុងពេលដែលលោកគ្រប់គ្រង តំបន់១០៥នោះ ថាតើនោះជាមូលហេតុនៃការចាប់ខ្លួនមនុស្ស យកទៅឃុំខ្លួននោះដែរឬទេ? ឬក៏ជា មូលហេតុដែលថា គេធ្វើមន្តអាគម អូមអាម អាប អីជាដើមហ្នឹង ជាមូលហេតុនៃការចាប់ខ្លួន លោកនៅចាំទេ?

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ បញ្ជាក់ថា មានការអូមអាម ឬអាប ធ្មប់អីមិនដែលបានចាប់ទេ។ គេក៏ ណែនាំរឿងអាប រឿងធ្មប់ មិនឲ្យចាប់ទេ គេឲ្យរៀបចំភូមិករឲ្យគេដោយឡែក អ៊ីចឹងមាន ថាឲ្យចាប់ឲ្យ

ចង ឲ្យសម្លាប់ អត់មាន។

**សៈ** ខ្ញុំមានសំណួរចុងក្រោយមួយ អំពីប្រធានបទនេះ គឺឯកសារដដែល។ សូមអភ័យទោស គឺឯកសារ E3/58 ERN 00250088, ខ្មែរ ERN 00239936។ នៅទីនេះ លោកសាក្សី 307 នោះគាត់និយាយថា សូមដកស្រង់ "អ្នកដែលគេយកទៅអប់រំនៅភ្នំក្រោលនោះ ដែលរាប់បញ្ចូលទាំងអ្នកមិនគោរពវិន័យ ខុសសីលធម៌ លួច ហើយនិងដើរសេរី ហើយនៅក្នុងករណីនោះ គឺអ្នកដែលគេចោទត្រូវរៀបចំប្រវត្តិរូប ហើយថ្នាក់មជ្ឈិមមិនដែលសម្រេចថា ឲ្យក-១៧ ហ្នឹងចាប់ខ្លួនមនុស្សនោះទេ។" តើនេះជាបទពិសោធន៍របស់ខ្លួនលោកទេគឺថា ខាងមជ្ឈិមមិនដែលបញ្ជាឲ្យ ក-១៧ ដើម្បីឲ្យមានការចាប់ខ្លួននោះទេ។ តើអ៊ីចឹងដែរឬទេ?

[១៤:៤០:០៩]

**ឆះ** បាទ អត់មែនទេ។ មិនដែលៗចាប់ មិនដែលចងទេបាទ ពីព្រោះគោរពណាស់ បើគេប្រកាសជាផ្លូវការហើយ មិនប៊ានធ្វើទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាក ដល់សាក្សី និងមេធាវីប្រឹក្សាសាក្សី ហើយនិងឲ្យអញ្ជើញគាត់ មកកាន់កន្លែងផ្តល់សក្ខីកម្មវិញ នៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង១៥:០២ នាទី)*

[១៥:០១:៥៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ តែមុននឹងបន្តការតាំងសំណួរ អង្គជំនុំជម្រះសូមសួរលោក ទៅលោកមេធាវីអន្តរជាតិ ហ្សាស្តេ ប៉ៅ ក្រោកឈរ! លោកមេធាវីអត្ថបទមួយដែលលោកបានដកស្រង់ចេញពីអត្ថបទនិពន្ធ ដោយអ្នកនិពន្ធ ស្ទីវ ហេដឌ័រ ដែលលោកលើកយកមកសួរដេញដោលសាក្សីក្នុងអំឡុងពេលសវនាការវគ្គមុននេះ តើឯកសារនេះមាននៅក្នុងសំណុំរឿង ឬនៅក្នុងបញ្ជីឯកសារណាមួយរបស់ភាគីដែលស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះដែរឬទេ? ហើយអត្ថបទនោះមានចំណងជើងអីដែរ?

[១៥:០៣:៤៣]

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ គឺថាអត្ថបទរបស់ ស្ទីវ ហេដឌ័រ គឺនៅលើបណ្តុំឯកសារ-- កន្លែងផ្ទុកឯកសាររួម ហើយខ្ញុំអាចផ្តល់នូវលេខ ERN។ ប៉ុន្តែដោយសារតែមន្ត្រីច្បាប់គាត់មកមុននេះ គឺខ្ញុំឥឡូវហ្នឹង ដូចជាឯកសារ បាត់អាលេខ កន្លែងទុកដាក់ ERN ហ្នឹងទៅហើយ។ ប៉ុន្តែឯកសារហ្នឹងគឺគេហៅថាមានចំណងជើងថា "គឺការនិយាយការវាយតម្លៃអំពីតួនាទីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"។ ហើយខ្ញុំអាចថា បន្ទាប់ពីបញ្ចប់ពេលសវនាការលើកនេះ ខ្ញុំនឹងផ្តល់នូវលេខ ERN ហើយខ្ញុំបានដាក់កាលពីមុននេះ គឺនៅក្នុងពាក្យសុំកាលពីមុននេះ ដែលស្នើសុំឲ្យមានលេខដាក់លេខ "E" សម្រាប់ឯកសារមួយនេះ។ ប៉ុន្តែខ្ញុំជាថ្មីម្តងទៀត ខ្ញុំមិនអាចផ្តល់ព័ត៌មានបានទេនៅក្នុងខណៈពេលនេះ។ ខ្ញុំគ្រាន់តែនិយាយយោងទៅលើឯកសារនេះ ហើយឯកសារនេះគឺវាមាននៅក្នុងបណ្តុំឯកសាររួមជាឯកសារសាធារណៈ ហើយម្យ៉ាងទៀត វាគ្រាន់តែ-- ខ្ញុំយកមកដើម្បីគ្រាន់តែសួរផ្ទួញទៅលើសាក្សី ហើយខ្ញុំគិតថាការសួរបែបនេះគឺមានលក្ខណៈគ្រប់គ្រាន់។ សូមអរគុណលោកប្រធាន។

[១៥:០៥:១៦]

**ប្រធានអង្គជំនុំ៖**

លោកអត់ទាន់ឆ្លើយនឹងសំណួរយើងទេ លោក ហ្សាស្តេ ប៉ៅ។ តើមាននៅក្នុងសំណុំរឿងក្តី០០២ដែរឬទេ ឯកសារនុំង? ឬនៅក្នុងបញ្ជីឯកសារណាមួយនៃភាគីដែលបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ

រួចហើយ ដែរឬទេ? នេះជាសំណួរ។ លោកមិនគប្បីឆ្លើយវាងទេ ឆ្លើយឲ្យចំនឹងសំណួររបស់យើងមក គឺត្រឹមត្រូវហើយ។

[១៥:០៥:៥៥]

**លោក ហ្សាស្ពើ ប៉ៅ៖**

លោកប្រធាន ខ្ញុំកំពុងតែ-- ខ្ញុំបានឆ្លើយត្រឹមត្រូវរួចទៅហើយ គឺឯកសារនេះមាននៅក្នុងបណ្ដុំឯកសារ បណ្ដុំ-- ប្រព័ន្ធផ្ទុកឯកសាររួម ហើយតាមដែលខ្ញុំដឹង គឺខ្ញុំមិនដឹងថា តើវាមាននៅក្នុងបញ្ជីឯកសារដែលដាក់ដោយភាគី ឬអត់នោះទេ គឺខ្ញុំអត់ដឹងទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអាចជម្រាបលោកប្រធាន ពីព្រោះថា ខាងមេធាវីមិនបានផ្ដល់ព័ត៌មានលម្អិតនោះទេ។ តាមពិតទៅ គឺមានការដកស្រង់ៗ ដែលនិយាយអំពីអត្ថបទរបស់លោក ស្ទីវ ហេដឌ័រ ដែលនិយាយថា ជាការវាយតម្លៃទៅលើតួនាទីរបស់កម្មាភិបាលនៅរបបកម្ពុជាប្រជាធិបតេយ្យ ហើយឯកសារហ្នឹង គឺមាននៅក្នុងឧបសម្ព័ន្ធរបស់យើង គឺឯកសារ D366/7.1.828។ អ្វីដែលខ្ញុំអាចប្រាប់បាន គឺថាឯកសារ-- មិនៗ ខ្ញុំមិនច្បាស់ថា ឯកសារទាំងមូលមានទេ ប៉ុន្តែការដកស្រង់មួយផ្នែកនៃឯកសារហ្នឹង គឺមាននៅក្នុងសំណុំរឿង។

[១៥:០៧:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការផ្ដល់ព័ត៌មានពីតំណាងសហព្រះរាជអាជ្ញា។ លោក ហ្សាស្ពើ ប៉ៅ អង្គជំនុំជម្រះសូមរំឭកសាជាថ្មីម្ដងទៀត ដោយអង្គជំនុំជម្រះបានរំឭកក្រុមមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា ហ្នឹង ញឹកញាប់ហើយ សូមឲ្យលោកគោរព និងអនុវត្តឲ្យបានត្រឹមត្រូវជាអតិបរមា ចំពោះសេចក្ដីណែនាំអនុវត្តអំពីការស្នើសុំដាក់ឯកសារដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយអង្គជំនុំជម្រះសូមរំឭកបន្ថែមថា នៅពេលណាដែលលោកមេធាវីត្រូវលើកឯកសារណាមួយមកដាក់ដេញដោលសាក្សី ដើមបណ្ដឹង-- ឬដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ លោកមេធាវីត្រូវតែបង្ហាញជាមុនអំពីឯកសារនោះ ថាតើពិតជាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងបញ្ជីឯកសារណាមួយរបស់

ភាគីណាមួយ ឬក៏របស់ក្រុមខ្លួនហើយឬនៅ?

[១៥:០៨:២៦]

ទីពីរ បង្ហាញអំពីអត្តសញ្ញាណឯកសារ ដូចជាលេខកូដ លេខសម្គាល់ឯកសារ ចំណងជើងឯកសារ លេខERN ជាពីរ ឬបីភាសា ទៅតាមស្ថានភាពនៃឯកសារដែលពាក់ព័ន្ធជាក់ស្ដែង។ ហើយការនេះ គឺភាគីពាក់ព័ន្ធដទៃទៀត គេបានអនុវត្តត្រឹមត្រូវ ហើយល្អច្រើនហើយ ពីព្រោះដំណើរការសវនាការហ្នឹង ៧០ថ្ងៃជាងមកហើយ។ មិនគួរមាននូវបញ្ហានេះដដែលៗដូច្នេះទេ។ សង្ឃឹមថា លោកមេធាវីនឹងប្រឹងប្រែងខិតខំអនុវត្តឲ្យបានល្អនូវការណែនាំរបស់អង្គជំនុំជម្រះ។

សូមអញ្ជើញបន្តការតាំងសំណួរដេញដោលចំពោះសាក្សីចុះ!

**លោក ហ្វាស្ដើ ប៉ោះ**

ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ថាតើខ្ញុំមិនអាចដកស្រង់អំពីអត្ថបទដែលមាននៅក្នុងប្រព័ន្ធសាធារណៈតើមែនឬទេ? ថាតើខ្ញុំមិនអាចពឹងផ្អែកទៅលើអត្ថបទសិក្សាស្រាវជ្រាវដែលធ្វើឡើងដោយអ្នកស្រាវជ្រាវដែលមានកេរ្ដិ៍ឈ្មោះល្អ អាចថាខាង-- គឺខ្ញុំមិនអាចពឹងផ្អែកបានដែរឬទេ? គឺឯកសារដែលខ្ញុំអាចចូលមើលបានតាមបណ្ណាល័យ ឬមួយក៏តាមកន្លែងណាមួយ។ ខ្ញុំមិនប្រាកដថា ហេតុអ្វីក៏យើងមិនអាចយោងទៅលើឯកសារបែបនេះបាន ហើយមិនអាចបង្ហាញឯកសារនេះ ទៅលើសាក្សី ដោយគ្រាន់តែយើងខ្ញុំចង់ផ្ដល់ព័ត៌មាន ហើយម្យ៉ាងទៀត ឯកសារនេះ មាននៅក្នុងប្រព័ន្ធសាធារណៈរួចទៅហើយ។

[១៥:១០:១០]

ប្រសិនបើខ្ញុំមិនអាចធ្វើបាន ដូច្នេះ វាជាការប្រើប្រាស់មួយដែលមិនត្រឹមត្រូវ ដែលគ្មានន័យ។ ដូច្នេះ ខ្ញុំគិតថា អ្វីដែលខ្ញុំចង់ធ្វើ គឺថា ប្រសិនបើដូច្នេះ គឺវាគ្មានបញ្ហាអ្វីនោះទេ នៅពេលដែលយើងនិយាយដល់ការដំណើរការរយៈពេលជាង៧០ថ្ងៃ។ ទោះបីថាយើងដំណើរការជាង៧០ថ្ងៃក៏ដោយ ក៏វាដូចជាគ្មានការស៊ីសង្វាក់គ្នា ការស្របគ្នាឲ្យច្បាស់លាស់សោះ។ ដូច្នេះ តើខ្ញុំអាចដកស្រង់នូវអត្ថបទដែលធ្វើឡើងដោយអ្នកសិក្សាស្រាវជ្រាវដែលមាននៅក្នុងប្រពន្ធសាធារណៈ ឬក៏នៅក្នុងវិស័យសាធារណៈដែលយើងអាចទទួលបាននោះ។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាចេញនូវគោលការណ៍ណែនាំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:១១:០៥]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយសង្ខេបទៅលើការឆ្លើយតប។ គឺថា ការឆ្លើយតបហ្នឹង វាហាក់ដូចជាត្រឹមត្រូវនោះឡើយ ព្រោះថា យើងបានបញ្ជាក់រួចទៅហើយ អំពីការជូនដំណឹងដល់គ្រប់ភាគីនូវឯកសារដែលភាគីចង់ប្រើប្រាស់។ ដូច្នេះមេធាវី គួរតែជូនដំណឹងភាគីដទៃ ដែលឯកសារ ដែលខ្លួនចង់ប្រើប្រាស់ ដើម្បីឲ្យភាគីដទៃអាចនឹងធ្វើការពិនិត្យទៅលើឯកសារនោះ។

បន្ថែមពីលើនេះទៀត ខ្ញុំមិនមានបញ្ហាអ្វីទេ ប្រសិនបើមេធាវីធ្វើការយោងទៅលើឯកសារដែលខ្លួនគិតថាមានសារៈសំខាន់ក្នុងការចោទសួរទៅលើសាក្សី ហើយជាឯកសារដែលនិពន្ធឡើងដោយអ្នកសិក្សាស្រាវជ្រាវខ្ពង់ខ្ពស់។ ប៉ុន្តែប្រសិនបើគាត់សួរសំណួរថា អ្នកណាមានសិទ្ធិអំណាចសម្លាប់ ឬក៏ចាប់ថាតើអ្នកហ្នឹងនៅក្នុងឋានៈស្រុក ឋានៈតំបន់អី? ដូច្នេះ ខ្ញុំមិនដឹងថាតើមេធាវីហ្នឹងអាចផ្តល់នូវការណែនាំបែបនោះទេ។ សូមអរគុណ។

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបថា ការព្រួយបារម្ភរបស់ព្រះរាជអាជ្ញា គឺយើងយល់ស្រប ហើយយើងនឹងផ្តល់នូវការជូនដំណឹងឲ្យបានច្បាស់លាស់អំពីឯកសារ ដូចដែលឯកសារដែលខ្ញុំបានប្រើប្រាស់មុននេះ គឺខ្ញុំនឹងចោទសាក្សីសួរទាក់ទងទៅនឹងឯកសារទាំងអស់នេះ។ ដូច្នេះ ខ្ញុំគិតថាមិនមានការជំទាស់ ឬក៏មិនមានការខ្វែងគ្នាអ្វីដែរ។ ខ្ញុំគិតថា ប្រហែលជាថ្ងៃអនាគត ខ្ញុំមិនអាចប្រើប្រាស់ឯកសារបែបនេះ ប្រសិនបើដូច្នេះមែន ខ្ញុំគិតថា ខ្ញុំស្នើសុំឲ្យមានការចេញជាគោលការណ៍ណែនាំពីអង្គជំនុំជម្រះ។

សូមអរគុណ។

[១៥:១៣:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៤:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្តល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលលើកឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា, ហ្សាស្តេ ប៉ោ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋម អង្គជំនុំជម្រះចង់កត់សម្គាល់ថា ជាការសោកស្ដាយណាស់ដែលត្រូវចំណាយពេលយ៉ាងច្រើនដូច្នេះក្នុងការរំឮកវិធានដែលអនុវត្តចំពោះយើងទាំងអស់គ្នានៅទីនេះ។ ការណ៍ដែលយើងចង់ប្រើប្រាស់ឯកសារណាមួយនៅក្នុងការពិភាក្សានៅទីនេះ តម្រូវឲ្យមានថាឯកសារនេះត្រូវបង្ហាញជូនអង្គជំនុំជម្រះ យើង-- អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេច ហើយនិងព្យាយាមពន្យល់ជាច្រើន ហើយសេចក្ដីសម្រេចទាំងអស់នេះត្រូវតែអនុវត្តគ្រប់គ្នាទាំងអស់ ហើយក្រុមនួន ជា ក៏យ៉ាងដូច្នេះដែរ។

[១៥:១៥:៥៧]

ដូច្នេះ ខ្ញុំគិតថា វាល្មមដល់ពេលដែលយើងទាំងអស់ត្រូវដឹងថា គោរពតាមវិធានច្បាប់ដែលអង្គជំនុំជម្រះបានកំណត់។ ឥឡូវនេះ ដែលទាក់ទងនឹងឯកសារ ដែលជាឯកសារក្នុងវិស័យសាធារណៈដែលសរសេរដោយអ្នកស្រាវជ្រាវ គ្រូនៅមហាវិទ្យាល័យ ដែលមានសារៈសំខាន់ ក៏ប៉ុន្តែមិនមែនបានន័យថា លោកមិនត្រូវ មិនចាំបាច់គោរពវិធានច្បាប់នោះទេ យើង-- ភាគទាំងអស់នៅទីនេះចង់ឲ្យជូនដំណឹងជាមុនអំពីឯកសារដែលជាមូលដ្ឋាននៃការសួរចម្លើយសាក្សី។ នេះគឺជាលក្ខខណ្ឌអប្បបរមា ហើយបន្ទាប់មកទៀត គឺអង្គជំនុំជម្រះជាអ្នកធ្វើការវាយតម្លៃថាជាឯកសារថ្មី ឬក៏ឯកសារដែលយើងអាចយកមកពិភាក្សាគ្នា ឬក៏អត់ ដើម្បីឲ្យយើងអាចធ្វើការវាយតម្លៃបានថា មានភាពពាក់ព័ន្ធ ឬក៏មានប្រយោជន៍ក្នុងការរកការឃើញការពិត។ ដូច្នេះ យើងសូមឲ្យអស់លោកព្យាយាមធ្វើការ ត្រៀមការងារដើម្បីសម្រួលការងារយើងជាជាងចំណាយពេលរាប់ម៉ោងដែលថាមានតម្លៃណាស់ចំពោះយើងក្នុងការធ្វើការពិភាក្សាលើបញ្ហាដដែលៗ ដែលមិនត្រូវយកមកពិភាក្សានៅទីនេះ។ បាទ ខ្ញុំសង្ឃឹមថា ខ្ញុំបាននិយាយច្បាស់លាស់ហើយ។

[១៥:១៧:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ហ្សង់ម៉ាក ហើយយើងក៏សូមបញ្ជាក់បន្ថែមដែរ រំឭកបន្ថែមដល់លោកមេធាវីដែរថា ឯកសារដែលភាគីទាំងឡាយបានដាក់នៅក្នុង *អ៊ីនធីហ្វេស* មិនមានន័យថាឯកសារនោះជំនួយឲ្យការអនុវត្តនៅវិធាន៨៧(៤) ទេ។ វិធាន៨៧(៤) គឺនៅតែមានតម្លៃជាច្បាប់ស្ដីពីនីតិវិធីនៃការស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។ ចំណែកឯឯកសារដាក់នៅ *អ៊ីនធីហ្វេស* សម្រាប់ភាគី

ទទួលព័ត៌មានបានមុនពេលដេញដោលនេះ គ្រាន់តែជាការសម្រួលព័ត៌មានដើម្បីត្រៀមលក្ខណៈជាមុន បានពិនិត្យមើលឯកសារពាក់ព័ន្ធជាមុនដើម្បីពេលមកចូលដេញដោលហ្នឹង គឺវាមានល្បឿន និងប្រសិទ្ធភាពប៉ុណ្ណោះ។ ចៀសវាងមានការភ័ន្តច្រឡំ ថាការដែលយកឯកសារណាមួយថ្មីថែសពីកន្លែងណាមួយផ្សេងទៀតដែលខ្លួនបានរកឃើញ ហើយដាក់ក្នុង *អ៊ីនធីហ្វេស* យល់ថាអាហ្នឹងគឺជាការជំនួសឲ្យការអនុវត្តដ៏ត្រឹមត្រូវនៅក្នុងតាមជំនួសនូវវិធាន៨៧(៤) មិនដូច្នេះទេ។ ត្រូវតែធ្វើតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រា-- វិធាន ៨៧(៤) ហើយនិងភ្ជាប់និង៨៧(៣) អំពីលក្ខណៈពាក់ព័ន្ធនៃភស្តុតាង។

សូមអញ្ជើញការតាំងសំណួរចំពោះសាក្សី!

[១៥:១៩:១៨]

**លោក ហ្វស្តើ ប៉ោះ**

សូមអរគុណលោកប្រធាន ហើយខ្ញុំយល់ស្របថាយើងចំណាយពេលវេលាច្រើនណាស់នៅលើបញ្ហាមួយនេះ ហើយខ្ញុំនឹងមិននិយាយឡើងវិញទេ ប៉ុន្តែសម្រាប់ទឡ្ហីករណ៍របស់យើង ដើម្បីការកត់ត្រាប្រសិនបើយើងត្រូវប្រើប្រាស់ឯកសារខាងក្រៅ តួនាទីរបស់យើងក្នុងនាមជាមេធាវីការពារក្តី គឺត្រូវ គឺយើងប្រើប្រាស់ឯកសារហ្នឹងដើម្បីសួរផ្ទៀងទៅលើសាក្សី ហើយយើងគ្មានជម្រើសផ្សេងនោះទេ។ នេះគឺជាតួនាទីរបស់យើងក្នុងនាមជាមេធាវីការពារក្តី។ ហើយខ្ញុំនឹងសូមបញ្ចប់នូវលើបញ្ហានេះក្នុងពេលនេះ។ ហើយខ្ញុំនឹងបន្តនូវការស្តាប់សំណួរសាក្សីបន្តទៅទៀត ដែលវាមានលក្ខណៈសំខាន់ជាង។ ដោយ-- ប្រសិនបើលោកប្រធានអនុញ្ញាតខ្ញុំសូមបន្តសួរទៅលោក សៅ សារុន នៅសំណួរពីរបីបន្តទៀតហើយខ្ញុំអាចបញ្ចប់នៅមុនពេលសម្រាកនៅក្នុងថ្ងៃនេះ។

ជាដំបូងខ្ញុំស្នើសុំថា ខ្ញុំនិយាយអំពីកិច្ចប្រជុំដែលយើងបានពិភាក្សាមុនពេលឈប់សម្រាកនេះ ដូចដែលខ្ញុំបញ្ជាក់នៅពេលនោះអ៊ីចឹង។ ប្រហែល-- ខ្ញុំបានបញ្ជាក់ថា អាចមានការយល់ច្រឡំគ្នាទាក់ទងទៅលើថា តើយើងនិយាយអំពីកិច្ចប្រជុំណាមួយ។

**សួរដោយលោក ហ្វស្តើ ប៉ោះ**

**ស៖** ដូច្នេះ លោក សារុន ខ្ញុំចង់សួរសំណួរលោកអំពីកិច្ចប្រជុំ ដែលលោកបានចូលរួមនៅទីក្រុងភ្នំពេញ ហើយលោកបានបញ្ជាក់ថា-- ហើយលោកបានបញ្ជាក់ប្រាប់សហចៅក្រមស៊ើបអង្កេតថា នៅក្នុងឯកសារដែលមានលេខ E3/367 លោកបាននិយាយដូចតទៅ ហើយខ្ញុំសូមដកស្រង់៖

[១៥:២១:១០]

“ប្រហែលជាពីរបីខែក្រោយពេល ឡាំង និង ខាំ ភួន ស្លាប់ខ្ញុំបានទទួលទូរលេខមកពី ប៉ុល ពត ថាឲ្យទៅប្រជុំ ក្នុងនោះខ្លឹមសារគឺហៅខ្ញុំ, តាវៀង, តាលក, តាគីម, តាឡាន់, តាសុភា ទាំងប្រាំមួយនាក់នេះទៅប្រជុំនៅភ្នំពេញ។ អ្នកដែលទទួល ហើយអ្នកដែលបកស្រាយ អ្នកដែលទទួលទូរលេខ និងបកស្រាយទូរលេខឲ្យខ្ញុំឈ្មោះ សាន ស្លាប់ក្រោយឆ្នាំ១៩៧៩”។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា តើលោកចាំដែរឬទេថា លោកមានការចូលរួមប្រជុំនៅក្នុងទីក្រុងភ្នំពេញ គឺកិច្ចប្រជុំដែលធ្វើឡើងប្រហែលជាពីរបីខែក្រោយពេល ឡាំង និង ខាំ ភួន ស្លាប់ តើលោកចាំដែរឬទេ?

[១៥:២២:១១]

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងគឺដូចខ្ញុំបានជម្រាបលោកសហចៅក្រម និងលោកព្រះរាជអាជ្ញារួចហើយ។ គឺខ្ញុំជម្រាបច្បាស់លាស់ហើយបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលគេសួរលោកអំពីការប្រជុំនេះ គឺនៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោកអំពីកិច្ចប្រជុំនេះ គឺសហព្រះរាជអាជ្ញាសួរលោកអំពីកិច្ចប្រជុំនេះ នៅក្នុងប្រតិចារឹកទំព័រ៥២ និងប្រតិចារឹកទំព័រ៥៣ គឺលោកនិយាយដូចតទៅនេះ៖ ព្រះរាជអាជ្ញាបានចោទសួរលោកថា “នៅពេលដែលមកដល់ទីក្រុងភ្នំពេញ តើលោកជួបអ្នកណានៅទីនោះ?” ហើយលោកឆ្លើយថា “យើងខ្ញុំជួប ប៉ុល ពត”។ បន្ទាប់មកព្រះរាជអាជ្ញាសួរថា “តើលោកចាំដែរឬទេថា លោកមានជួបប្រជុំជាមួយមេដឹកនាំណាផ្សេងទៀតក្រៅពី ប៉ុល ពត ទេ?” ហើយលោកឆ្លើយថា “ខ្ញុំមិនបានជួបជាមួយមេដឹកនាំដទៃទៀតទេ”។

លោក សារុន តើលោកអាចបញ្ជាក់បានទេនៅពេលនេះថា ចម្លើយដែលលោកនិយាយនេះ គឺជាចម្លើយដែលត្រឹមត្រូវ?

[១៥:២៣:៣៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយចាំស្តាប់អង្គជំនុំជម្រះ សម្រេចទៅលើការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។ សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ការជំទាស់របស់យើងគឺថា មេធាវីបានធ្វើ ប៉ុន្តែនិយាយខុសនៅ--

ដោយសារតែគាត់ដកចេញនូវផ្នែកបន្តបន្ទាប់គ្នានៃប្រតិចារឹកនេះ។ ដូច្នេះអ្វីដែលយើងនិយាយគឺថា គាត់ភ្លេចនិយាយពីការដកចេញនូវមួយចំណុចៗមួយចំនួន ដូច្នេះការនិយាយរបស់គាត់ហាក់ដូចជាការនាំទៅរកចំណុចខុសទាក់ទងទៅនឹងប្រតិចារឹក។ ដូច្នេះហើយ ខ្ញុំយល់ឃើញថា សាក្សីគាត់នៅពេលក្រោយបន្តិច គាត់និយាយដោយមានការកែប្រែ ដែលមានការប្រែប្រួល។

[១៥:២៤:២៦]

**លោក ហ្សាស្តើ ប៉ោះ**

លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅនឹងព្រះរាជអាជ្ញា គឺថាខ្ញុំដកចេញៗ នូវការរំឭក ខ្ញុំដកចេញនូវចំណុចមួយចំនួនទាក់ទងទៅនឹងការរំឭក ដូច្នេះហើយខ្ញុំគិតថា សារៈសំខាន់នៃអ្វីដែលចាំវាមិនពាក់ព័ន្ធទេ គឺយើងគ្រាន់តែចង់បញ្ជាក់ថា តើសាក្សីគាត់ចាំបានដែរឬទេ អ្វីដែលគាត់បាននិយាយកាលពីសប្តាហ៍មុន និងអ្វីដែលគាត់បាននិយាយនៅថ្ងៃនេះ តើគាត់ចងចាំហ្នឹង តើដូចគ្នាដែរឬទេ រវាងឆ្នាំនេះ ឆ្នាំមុន និងប៉ុន្មានឆ្នាំកន្លងមកនោះ។ ដូច្នេះហើយខ្ញុំគិតថា អ្វីដែលសំខាន់គឺ យើងចង់ស្តាប់ឮថាតើសាក្សីគាត់និយាយ ឬក៏នឹងឆ្លើយតបបែបណាទៅនឹងសំណួរទាំងអស់នេះ ព្រោះថាយើងមិនអាចសន្មតបានទេថា អ្វីដែលគាត់និយាយជាមួយសហចៅក្រមស៊ើបអង្កេតនោះ គឺជាចម្លើយដែលត្រឹមត្រូវ។

យើងត្រូវធ្វើការពិនិត្យ យើងត្រូវធ្វើការបញ្ជាក់ថាតើគាត់នឹកឃើញដោយរបៀបណា? ហើយនេះ គឺជាចំណុចមួយដែលសំខាន់សម្រាប់សាក្សីមួយនេះ ព្រោះសាក្សីនេះគាត់បញ្ជាក់ដដែលថា គាត់មិនចាំនូវអ្វីៗច្បាស់លាស់នោះទេ។ ពេលខ្លះគាត់អាចនឹងធ្វើនូវការផ្តល់ចម្លើយដែលផ្ទុយគ្នា ដែលគាត់បានធ្វើកាលពីសប្តាហ៍មុន អាចថាដោយសារគាត់មានការបាត់បង់ការចងចាំ ឬក៏ដោយសារហេតុផលផ្សេងៗទៀតដែលយើងមិនដឹង។ ដូច្នេះ យើងគ្រាន់តែធ្វើការបញ្ជាក់លម្អិត អ្វីដែលព្រះរាជអាជ្ញានិយាយកាលពីសប្តាហ៍មុន គឺប្រើប្រាស់វិធីសាស្ត្រដូចគ្នា។

[១៥:២៦:១៣]

ព្រះរាជអាជ្ញាសួរដដែលៗ ហើយពេលនុ៎ងគឺ ខាងសាក្សី គាត់បញ្ជាក់អំពីភាពពិតប្រាកដ ដែលគាត់ផ្តល់ចម្លើយជាមួយនឹងសហព្រះរាជអាជ្ញា ហើយឥឡូវនេះ ខ្ញុំគ្រាន់តែធ្វើដូចគ្នា គឺគ្រាន់តែបញ្ជាក់ថាតើគាត់យល់ថា ចម្លើយដែលគាត់ផ្តល់ដោយសម្បថ ទៅសហព្រះរាជអាជ្ញាហ្នឹង តើវាជាចម្លើយដែលត្រឹមត្រូវ ឬក៏អត់នោះ។ ដូច្នេះហើយជាថ្មីម្តងទៀត ខ្ញុំសូមស្នើថា អនុញ្ញាតឲ្យខ្ញុំចោទសួរនូវសំណួរបែបនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាត ឲ្យលោកតបទៅនឹងសេចក្ដីតបរបស់ភាគីម្ខាងទៀតទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៧:៤៨]

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរ សួរចុងក្រោយដោយមេធាវីការពារក្ដី លោក នួន ជា ទេ ពីព្រោះជាសំណួរច្រំដែល។

**លោក ហ្វ្រាស្ដើ ប៉ោ៖**

ខ្ញុំមិនប្រាកដថា ហេតុអ្វីបានជាដូច្នេះ ប៉ុន្តែកាលពីសប្ដាហ៍មុន មេ ខាងសហព្រះរាជអាជ្ញា គាត់ធ្វើដូចគ្នាចំនួន១៧ដង ទៅលើចម្លើយ ដែលការផ្ដល់ជាមួយនឹង--

**ប្រធានអង្គជំនុំ៖**

លោកត្រូវបន្តសំណួរថ្មីទៀត។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកប្រើពេលវេលា ក្នុងកិច្ចដំណើរការសវនាការទៅធ្វើអត្ថាធិប្បាយផ្សេងៗទៀត នាំឲ្យបាត់បង់ពេលវេលាទេ។ ប្រសិនបើលោកអស់សំណួរហើយ លោកអាចប្រាប់យើង ដើម្បីឲ្យយើងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីផ្សេងទៀត។

**លោក ហ្វ្រាស្ដើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបថា ខ្ញុំមិនមានសំណួរបន្តទៀតទេ ប៉ុន្តែខ្ញុំមានសំណួរបន្តទៅទៀតគឺទាក់ទងទៅនឹងទូរលេខ។ ខ្ញុំចង់សួរអំពីទូរលេខ ដែលបានពិភាក្សាជាមួយលោកបានឆ្លើយទៅខាងសហព្រះរាជអាជ្ញាហើយទូរលេខទីមួយដែលខ្ញុំចង់លើកយកមកនិយាយនោះគឺ ឯកសារដែលមានលេខ D201/5.3, ERN ភាសាអង់គ្លេស 00361189, ភាសាខ្មែរគឺ 002099293 (ស៊ីក)។ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ គឺទូរលេខលេខ 46។

[១៥:២៩:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ហ្វ្រាស្ដើ ប៉ោ៖**

**ស៖** គឺជាទូរលេខដែលយើងបានពិភាក្សាកាលពីពេលមុនរួចមកហើយ ហើយទូរលេខនេះគឺផ្ញើ

ជូនបង ម៨៧០ ជាទីគោរព។ ហើយទូរលេខនេះគឺនិយាយអំពីហេតុការណ៍ ដែលកើតឡើងចំពោះភ្លើងឆេះកាណូត។ តើលោកចាំអំពីទូរលេខដែលយើងកំពុងតែនិយាយនេះដែរឬទេ លោក សារុន?

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំបានឆ្លើយជម្រាប រាយការណ៍ជូនព្រះរាជអាជ្ញារួចស្រេចហើយ គឺអស់ប៉ុណ្ណឹង។

[១៥:៣១:០២]

**ស៖** នៅក្នុងទូរលេខនេះ គឺបានសរសេរ ហើយខ្ញុំសូមដកស្រង់៖ “វិធានការរបស់តំបន់ មួយ គឺត្រូវចាប់ពួកពីរនាក់ហ្នឹង។ ពីរ គឺត្រូវចាប់ អាលាន។ តាមការពិនិត្យគឺមានការចាត់តាំងពី អាលាន ទៅ”។ ហើយនៅបន្ទាត់ខាងក្រោម៖ “ថ្ងៃ០៩ នេះបានអនុវត្តចាប់ពួកទាំងនេះ”។ ប្រសិនបើខ្ញុំអានទូរលេខនេះ គឺចំពោះខ្ញុំហាក់ដូចជាថា តំបន់ខ្លួនឯងគឺបានសម្រេចក្នុងការចាប់ពួកពីរនាក់នោះ ដោយមិនចាំបាច់ទទួលនូវបញ្ជាពីខាងមជ្ឈិមនោះឡើយ។ តើខ្ញុំអានបែបនេះ តើខ្ញុំបកស្រាយបែបនេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ អត់ត្រឹមត្រូវទេ ខ្ញុំមិនបាននិយាយអ៊ីចឹងទេបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំនឹងចូលទៅរកទូរលេខមួយទៀត គឺទូរលេខ៥៤ ដែលខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញលើអេក្រង់ គឺ ERN អង់គ្លេស 0029206220 (ស៊ីក), បាទ ERN មួយទៀត 0012027។ ទូរលេខមួយនេះ លោក សារុន គឺទាក់ទងទៅនឹងសមមិត្ត សុត ដែលយើងបានពិភាក្សា ហើយសហព្រះរាជអាជ្ញាក៏បានពិភាក្សាដែរ តេឡេក្រាម--។ ទូរលេខនេះនិយាយថា៖ “បញ្ហាសភាពការណ៍ផ្ទៃក្នុង គឺមានសមមិត្ត សុត ប្រធានរោងចក្រជួសជុលបានប៉ះពាល់សីលធម៌ជាមួយនារី។ ឥឡូវនេះគឺបានចាប់ហើយ គឺចាប់ទាំងបុរស ចាប់ទាំងនារី”។ លោក សារុន តាមដែលខ្ញុំអានទូរលេខនេះ គឺខ្ញុំយល់ថា ថ្នាក់ក្រោម កម្មាភិបាលក្រោមក៏មានអំណាចក្នុងការចាប់មនុស្សចំពោះបទល្មើសតូចតាចផងដែរ តើត្រឹមត្រូវឬទេ?

[១៥:៣៣:៣៩]

**ឆ៖** បាទ អត់ត្រឹមត្រូវទេ។ រឿង សុត ហ្នឹង អាហ្នឹងខ្ញុំបានជម្រាបបញ្ជាក់ឲ្យលោកព្រះរាជអាជ្ញាតាំងពីម្សិលមិញហើយ។

**ស៖** ខ្ញុំជិតនឹងបញ្ចប់ផ្នែកមួយនិយាយការសួរសំណួររបស់ខ្ញុំហើយលោក សៅ សារុន ប៉ុន្តែសហព្រះរាជអាជ្ញាពីសប្តាហ៍មុននោះគាត់បានសួរលោក ថាតើមេដឹកនាំកម្ពុជាប្រជាធិបតេយ្យមានការ

ពិភាក្សា ឬក៏អនុញ្ញាតឲ្យមានការកសាងវត្តដែលខ្មែរក្រហមខូចខ្ទីរួចឡើងហើយនោះឡើងវិញដែរឬអត់? សំណួររបស់ខ្ញុំចំពោះលោកនោះ គឺថាតាមអ្វីដែលលោកដឹង តើរដ្ឋាភិបាលសហរដ្ឋអាមេរិកធ្លាប់ស្នើដើម្បីសាងសង់វត្តដែលខ្មែរក្រហមខូចខ្ទី នោះឡើងវិញដែរឬទេ ដែលថាខូចដោយសារការទម្លាក់គ្រាប់បែករបស់គេនោះ?

[១៥:៣៥:២២]

**ឆ៖** បាទ ដូចខ្ញុំបញ្ជាក់ឲ្យព្រះរាជអាជ្ញារួចហើយ។

**លោក ហ្វាស្តើ ប៉ៅ៖**

ឥឡូវនេះ មិនមានសំណួរអ្វីទៀតទេ លោកប្រធាន ប្រហែលជាសហសេវិករបស់ខ្ញុំ លោក សុន អរុណ មានសំណួរមានដែរឬអត់ទេ។ គាត់ថាមិនមានទេលោកប្រធាន។

ឥឡូវនេះ មេធាវីការពារក្តីលោក នួន ជា ទាំងក្រុម គឺថាចង់ដាក់សំណើ ទាក់ទងទៅនឹងសំណើនេះ គឺនេះគឺជាឱកាសដ៏ល្អដើម្បីរកឲ្យឃើញការពិត ហើយជាសំណើដ៏ខ្លីមួយដែលអាចនឹងសមស្របនឹងលើកឡើងនៅក្នុងសវនាការនេះ ពីព្រោះវាទាក់ទងទៅនឹងការចងចាំ និងប្រភពនៃការដឹងរបស់លោក សៅ សារុន នេះ។ ហើយយើងអាច គឺថា តើការចងចាំរបស់គាត់នោះល្អប៉ុនណា? ខ្ញុំនឹងប្រើពេលតែពីរនាទីតែប៉ុណ្ណោះបាទ។

[១៥:៣៦:៣១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានរំឭករួចហើយ អំពីបញ្ហាទាំងនេះ គឺជាហួរហែមកហើយ។

**លោក ហ្វាស្តើ ប៉ៅ៖**

លោកប្រធាន សូមកែតម្រូវ បើខ្ញុំខុសគឺថា គឺទាក់ទងទៅនឹងការតាំងសំណួរសាក្សី គឺអាចធ្វើនៅតុលាការ ឬមិនអាចធ្វើនោះ។ ខ្ញុំសូមជម្រាបថា ការព្រួយបារម្ភរបស់យើងខ្ញុំទាក់ទងទៅនឹងការភាពជឿជាក់បាននៃសាក្សីរូបនេះ។ ពីព្រោះថា យើងចង់មានសំណើ ឬក៏សេចក្តីសន្និដ្ឋានហ្នឹង គឺថាខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានដោយខ្លី តែពីរ *មីនុត*តែប៉ុណ្ណោះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតធ្វើដូច្នេះទេ ហើយឲ្យលោកអានឡើងវិញនូវបទប្បញ្ញត្តិនៃវិធាន ៩២ ស្តីពីការដាក់សេចក្តីសន្និដ្ឋាន រហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល។ រហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល ភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងសេចក្តី

អនុវត្តស្ដីពីការដាក់ឯកសារ។ ដូច្នេះ នៅក្នុងលក្ខខណ្ឌនៃការស្នើសុំរបស់លោកនេះ គឺវាចូលទៅក្នុងបទប្បញ្ញត្តិនៃ ដែលមានចែងក្នុងវិធាន៩២ នៃវិធានផ្ទៃក្នុង ដែលអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្ដីពីការដាក់សេចក្ដីសន្និដ្ឋានរហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល។

បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[១៥:៣៩:០៥]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ មានសំណួរមួយចំនួនចោទទៅសាក្សី ហើយខ្ញុំគិតថាខ្ញុំនឹងអាចចោទសំណួរទាំងអស់នេះ ឲ្យចប់មុនពេលដែលចប់សវនាការថ្ងៃនេះ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី យើង-- នៅក្នុងសំណុំរឿង យើងមានតេឡេក្រាម-- ទូរលេខចំនួនបួន ដែលមានចុះហត្ថលេខាលោកផ្ទាល់ ហើយអត្ថបទទាំងអស់នេះ ត្រូវបានអានជូនលោកហើយ នៅរយៈពេលប៉ុន្មានថ្ងៃនេះ ហើយខ្ញុំមិនបានសង្កេតឃើញថាលោកជំទាស់ហ្នឹងទូរលេខទាំងអស់នោះនោះទេ។ ទូរលេខទីមួយ គឺចុះនៅថ្ងៃទី០១ កក្កដា ឆ្នាំ១៩៧៨, E3/248 ហើយនិងផ្ញើជូនទៅ សូមដកស្រង់៖ "ដល់បងម៨៧០ ជាទីស្នេហា"។ ខ្ញុំសួរថាតើទូរលេខនេះ ផ្ញើទៅកាន់អ្នកណា?

[១៥:៤០:០៩]

**លោក សៅ សារុន៖**

**ឆ៖** បាទ ផ្ញើទៅកាន់ ប៉ុល ពត។ ៨៧០ នេះ គឺជាគាត់ហើយ។

**ស៖** ទូរលេខទីពីរ គឺចុះថ្ងៃទី០៩ មេសា ៧៨ គឺលេខកូដ 201 300 /5.3 (ស៊ីក) ហើយផ្ញើទៅការិយាល័យ ម៧៧០, ៨៧០ សូមទោស។ តើចង់សួរថា តើទូរលេខនេះផ្ញើជូនទៅអ្នកណាដែរ?

**ឆ៖** បាទ ផ្ញើជូន ប៉ុល ពត ដដែល។

**ស៖** ទូរលេខទីបី ចុះថ្ងៃទី២៣ មេសា ឆ្នាំ១៩៧៨ គឺឯកសារ E3/155 ផ្ញើជូន "ទៅជូនទៅបងជាទីគោរពស្នេហា"។ សំណួរដដែល គឺថាតើទូរលេខនេះផ្ញើជូនទៅអ្នកណាដែរ?

**ឆ៖** បាទ ដូចខ្ញុំជម្រាបខាងលើ គឺជូន ប៉ុល ពត ដដែលៗ។

[១៥:៤២:០៣]

**សៈ** បាទ ដើម្បីបញ្ចប់។ ទូរលេខបី គឺថា D201/6.1 នៅខែ-- ចុះថ្ងៃទី២៤ មេសា ឆ្នាំ៧៨ ហើយផ្ញើជូនទៅបងជាទីគោរព។ ហើយខ្ញុំសួរថា តើទូរលេខនេះផ្ញើទៅកាន់អ្នកណាដែរ?

**ឆៈ** បាទ ដូចខ្ញុំជម្រាបខាងលើហើយដដែល ប៉ុល ពត ដដែល។

**សៈ** លោកសាក្សី អ៊ីចឹងខ្ញុំអាចយល់ឃើញថា ទោះបីជាមានពាក្យពេចន៍គោរពជាដំបូងនោះ ទូរលេខទាំងបួននេះ សុទ្ធតែផ្ញើទៅកាន់ជូន ប៉ុល ពត ទាំងអស់។ តើពិតជាអ៊ីចឹងមែនទេ?

**ឆៈ** បាទ គឺអ៊ីចឹងមែន។

**សៈ** លោកបាននិយាយជាច្រើនដង ប៉ុន្មានថ្ងៃកន្លងមកនេះ ថានៅពេលដែលលោកជាលេខាតំបន់១០៥ លោកបានផ្ញើទូរលេខទៅតែ ប៉ុល ពត ម្នាក់ទេ។ ខ្ញុំចង់សួរលោកថា តើអ្នកណាដែលប្រើឱ្យលោកធ្វើយ៉ាងដូច្នេះ?

**ឆៈ** បាទ គឺគាត់ជាបញ្ជា បើរាយការណ៍ អត់មានរាយការណ៍ គឺរាយការណ៍ជូនគាត់។

**សៈ** តើលោកអាចបញ្ជាក់ថា អ្នកណា អម្បាញ់មិញនេះលោកនិយាយអំពីអ្នកណា?

**ឆៈ** បាទ ខ្ញុំបញ្ជាក់ដូចខ្ញុំបញ្ជាក់អំមិញនេះហើយ គឺរាយការណ៍ គឺជូន ប៉ុល ពត ដដែលហ្នឹង។

**សៈ** ហើយ ប៉ុល ពត ហ្នឹងជាអ្នកបញ្ជាឱ្យលោករាយការណ៍ អ៊ីចឹងឬក៏យ៉ាងម៉េច?

**ឆៈ** បាទ គឺបញ្ជាឱ្យរាយការណ៍អ៊ីចឹង គឺតាមការកំណត់មួយថ្ងៃ ពីរថ្ងៃ ឬមួយថ្ងៃម្ដង គឺតាមបញ្ជាអ៊ីចឹងមែន។

[១៥:៤៥:០៧]

**សៈ** ហើយ ប៉ុល-- តើ ប៉ុល ពត បានពន្យល់ប្រាប់លោកអំពីមូលហេតុនៃការសម្រេចចិត្តដែរឬទេ?

**ឆៈ** បាទ បញ្ហាការសម្រេចចិត្តហ្នឹង ខ្ញុំអត់យល់ មិនដឹងសម្រេចចិត្តបញ្ហាអី។ សូមបញ្ជាក់ម្ដងទៀត។

**សៈ** តើ ប៉ុល ពត បានពន្យល់ពីមូលហេតុថា ហេតុអ្វីបានជាគាត់ចង់ឱ្យលោកផ្ញើទូរលេខទៅគាត់ ហើយមិនត្រូវផ្ញើទៅអ្នកផ្សេងនោះទេ?

**ឆៈ** បាទ ខ្ញុំសូមឆ្លើយ។ ពីព្រោះគាត់ជាប្រធាន រាយការណ៍អី គឺរាយការណ៍ជូនគាត់ បាទ។ សូម្បីអត់មានសភាពការណ៍អីក៏រាយការណ៍ថាធម្មតា ថាអត់មានសភាពការណ៍ ក៏ប្រាប់អត់មាន។

**សៈ** បាទ ខ្ញុំសូមអានសម្រង់ចម្លើយរបស់លោក ដែលលោកឆ្លើយទៅសហចៅក្រមស៊ើប

អង្កេត ហ្នឹងគឺជាចម្លើយដែលលោកបានឆ្លើយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ហើយសម្រង់នេះត្រូវបានដកស្រង់ច្រើនហើយនៅក្នុងការស្តាប់ចម្លើយលោកនេះ គឺថាលេខឯកសារ E3/367។ អ្វីដែលខ្ញុំចង់អាននោះ គឺការសម្រង់ គឺជាខ្សែអាត់នៃការស្តាប់ចម្លើយរបស់លោក គឺថាជាខ្សែអាត់នៃការឆ្លើយរបស់នៅសហចៅក្រមស៊ើបអង្កេត។ ហើយនេះជាសំណើរបស់ខ្ញុំប៉ុន្មានថ្ងៃមុននេះ ដែលអង្គជំនុំជម្រះបានឆ្លើយតបមក ហើយនិងផ្តល់មកឲ្យយើងតាមសេវាកម្មរបស់ខ្លួន គឺឯកសារ D125/167.1 ហើយខ្ញុំចង់អានវគ្គមួយដែលនៅទំពីរទីប្រាំ នៃសំណៅជាភាសាបារាំងនៃការស្តាប់ចម្លើយរបស់លោកនៅថ្ងៃទី១៧ ធ្នូ ឆ្នាំ២០០៨៖

[១៥:៤៨:០៩]

“សំណួររបស់អ្នកស៊ើបអង្កេត៖ តើលោកធ្លាប់ទទួលទូរលេខពី ខៀវ សំផន ដែរឬទេ? ចម្លើយរបស់លោក៖ សូមទោស! សំណួររបស់អ្នកស៊ើបអង្កេត តើលោកធ្លាប់ទទួលទូរលេខពី ខៀវ សំផន, អៀង សារី ដែរឬទេទាក់ទងទៅនឹងកិច្ចការសេដ្ឋកិច្ច? តើលោកធ្លាប់ទទួលទូរលេខពី ខៀវ សំផន ដែរឬទេ? ចម្លើយរបស់លោក៖ ទេ មិនដែលទេ។ សំណួរ៖ លោកមិនដែលបានទទួលទាល់តែសោះឬ? អត់ទេ ក៏ប៉ុន្តែខ្ញុំជួបគាត់នៅពេលដែលខ្ញុំទៅភ្នំពេញ ហើយពេលដែលខ្ញុំត្រូវពិភាក្សាជាមួយគាត់អំពីរឿងសេដ្ឋកិច្ច។ សំណួរ៖ ជួប នៅណា? អ៊ំ មិនដែលនិយាយប្រាប់ខ្ញុំផង ហើយជួបពេលណា? ចម្លើយ៖ ពេលប្រជុំហ្នឹងចេញ។ សំណួរ៖ សន្និបាតហ្នឹង? លោកឆ្លើយ៖ បាទ។ ពេលសន្និបាតទៅ ហើយរួចនឹងក៏ចេញ។ សំណួរ៖ សន្និបាតច្រើន តែ នួន ជា មិនដែលនិយាយ តើអ៊ំប្រាប់ថា អត់ដែលឃើញ ខៀវ សំផន និយាយណា? លោកឆ្លើយថា៖ អត់ទេ លោក ខៀវ សំផន មិនដែលនិយាយទេ ពេលប្រជុំសន្និបាត ឬបើកវគ្គ មិនដែលបញ្ជាក់ទេ។ សំណួរ៖ អ៊ីចឹងនិយាយក្រៅទេ? ឆ្លើយ៖ បាទ និយាយក្រៅទេយើងនិយាយពីរឿងសេដ្ឋកិច្ចហ្នឹងណ៎ា។ សំណួរ៖ និយាយក្រៅ ដូចពេលបាយពេលអីហ្នឹង? ឆ្លើយ៖ ពេលបាយ ពេលនុំងក៏សន្ទនាគ្នាក្រៅទៅ។ សំណួរ៖ អ៊ីចឹងៗខ្ញុំដាក់ពេលបាយ? ឆ្លើយ លោកឆ្លើយ៖ បាទ។ សំណួរ៖ សន្ទនាក្រៅពេលប្រជុំ? ឆ្លើយ៖ បាទ, នៅពេលខ្ញុំ-- ពេលសុំរឿង យើងត្រូវការសុំអីជូនបញ្ជើខាងសេដ្ឋកិច្ចអីហ្នឹងណ៎ា! សំណួរ--”។

បាទខ្ញុំសូមបញ្ចប់ការដកស្រង់សម្រង់ត្រឹមនេះលោកសាក្សី ហើយខ្ញុំចង់សួរលោកថា តើបើសិនជាលោកចាំថា តើលោកបានសន្ទនាក្រៅផ្លូវការជាមួយលោក ខៀវ សំផន ប៉ុន្មានដងទាក់ទងទៅនឹងផ្នែកសេដ្ឋកិច្ច រឿងសេដ្ឋកិច្ចនេះ ហើយលោកអាចជម្រាបជូនយើងបានទេ នៅថ្ងៃនេះ?

[១៥:៥១:២៨]

**ឆ៖** បាទ តែម្តងតែប៉ុណ្ណឹងឯង។

**ស៖** ហើយនៅក្នុងឱកាសនោះ តើលោកបានផ្តល់ជូនលោក ខៀវ សំផន នូវបញ្ជីមួយទាក់ទងទៅនឹងផ្នែកសេដ្ឋកិច្ចដែរឬទេ?

**ឆ៖** បាទ អត់ទេ គឺសំណេះសំណាលតែពីរឿងដាំដុះ រឿងធ្វើស្រែ ធ្វើចម្ការធ្វើអី។ សំណេះសំណាលក៏ក្រៅការប្រជុំផងបាទ ជួបគ្នាក្រៅការប្រជុំពេលរួចបាយបាទ។

**ស៖** ចុះនៅឱកាសផ្សេងទៀតនោះ តើលោកធ្លាប់បានផ្តល់បញ្ជីសេដ្ឋកិច្ចឱ្យលោក ខៀវ សំផន ទេ ក្រៅពីឱកាសម្តងហ្នឹង ឱកាសផ្សេងទៀត ទោះបីជាឱកាសណាក៏ដោយ?

**ឆ៖** អត់ទេ។ អត់ដែលជូនបញ្ជីអីឱ្យគាត់ទេ។

[១៥:៥៣:០៥]

**ស៖** ដូច្នេះ ដើម្បីឱ្យវាច្បាស់តែម្តងលោកសាក្សី អ៊ីចឹងបានន័យថា លោកច្រឡំហើយនៅពេលដែលលោកឆ្លើយទៅអ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៨ នោះ អ៊ីចឹងបានន័យថាលោកច្រឡំហើយមែនទេ?

**ឆ៖** បាទ។ ខ្ញុំអត់ តាំងពីខ្ញុំឈឺហ្នឹង ជួនកាលខ្ញុំបាននិយាយហើយ ខ្ញុំច្រឡំយ៉ាងម៉េចក៏សូមបញ្ជាក់ម្តងទៀតបាទ។

**ស៖** បាទ លោកសាក្សីមិនបាច់សូមទោសអីខ្ញុំទេ។ ខ្ញុំគ្រាន់តែចង់ដឹងថា នៅពេលដែលលោកឈឺនោះ លោកនិយាយអំពីពេលដែលលោកឆ្លើយទៅខាងអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេត លោកនិយាយនៅ-- បាទ លោកនិយាយថា រឿងឈឺហ្នឹង? ចង់និយាយថា ឈឺនៅពេលដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេត ឬក៏ឈឺឥឡូវហ្នឹង?

**ឆ៖** បាទ ឈឺមុន។ ឈឺមុនសហចៅក្រមស៊ើបអង្កេតបាទ។ អ៊ីចឹងបានខ្ញុំនិយាយមក ឥឡូវនេះវាជួនកាលភ្លេចការចងចាំច្រើនបាទ។

[១៥:៥៥:០៦]

**ស៖** បាទ អរគុណ ហើយសក្ខីកម្មរបស់លោកនៅថ្ងៃនេះ គឺលោកចង់និយាយថា លោកមិនបានផ្តល់បញ្ជីសេដ្ឋកិច្ចទៅឱ្យលោក ខៀវ សំផន ទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**លោក អាកទូរ វែកគែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវពេលវេលាក៏ដូចជាសល់តិចតួចដែរ ហើយអង្គជំនុំជម្រះសូមសួរទៅលោកក្រុមមេធាវីការពារក្ដីលោក អៀង សារី តើលោកត្រូវការពេលវេលាប៉ុន្មានដែរ ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ?

**លោក អាង ឧត្តម៖**

សូមក្រាបថ្វាយបង្គំព្រះសង្ឃ ព្រះតេជគុណ ព្រះអង្គគ្រប់ព្រះអង្គ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សួស្ដី ព្រះរាជអាជ្ញា សហភាគាទាំងអស់ សួស្ដីលោកអ្នកចូលរួមសវនាការនៅក្នុងបន្ទប់នេះ និងនៅក្រៅបន្ទប់ក្ដី។

សួស្ដីលោក សៅ សារុន, ខ្ញុំ អាង ឧត្តម ជាសហមេធាវីរបស់លោក អៀង សារី ខាងខាងស្ដាំដៃខ្ញុំជាសហមេធាវីរបស់លោក អៀង សារី ដែរ គឺលោក ម៉ៃខល កាណាវាស នៅពេលនេះយើងគ្មានសំណួរនឹងសួរលោកទេ។ តែយ៉ាងណាក្ដី យើងសូមថ្លែងអំណរគុណចំពោះលោកដែលបានឡើងមកផ្ដល់សក្ខីកម្មជូនតុលាការ ដើម្បីស្វែងរកការពិត និងយុត្តិធម៌។ សូមអរគុណលោកប្រធាន។

[១៥:៥៦:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណដល់ចំពោះក្រុមមេធាវីការពារក្ដី លោក អៀង សារី ដែលបានបង្ហាញជំហរច្បាស់លាស់ក្នុងការមិនមានសំណួរសួរដេញដោលចំពោះសាក្សីរូបនេះ ដើម្បីបង្កលទ្ធភាពនៅក្នុងការអង្គជំនុំជម្រះងាយស្រួល ក្នុងការកំណត់កាលបរិច្ឆេទសវនាការ សម្រាប់ថ្ងៃស្អែក។

លោក ស សារុន អ៎! លោក សៅ សារុន ឥឡូវនេះ កិច្ចដំណើរការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មរបស់លោក ពាក់ព័ន្ធនៅក្នុងសំណុំរឿង០០២ ទាំងមូល ឃើញថាដល់ទីបញ្ចប់ហើយ។ ហើយអង្គជំនុំជម្រះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ដែលបានចំណាយពេលដ៏មានតម្លៃ ហើយនិងខិតខំប្រឹងប្រែង ទោះបីមានវ័យចំណាស់ ហើយមានការថមថយនូវសុខភាពក៏ដោយ ក៏ឃើញថាកិច្ចប្រឹងប្រែងផ្ដល់សក្ខីកម្មរបស់លោកប៉ុន្មានថ្ងៃនេះ ល្អប្រសើរណាស់ ហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅ ដែលលោកចង់ទៅវិញបានហើយ។ អង្គជំនុំជម្រះឈប់

ត្រូវការក្នុងការអញ្ជើញលោក មកផ្តល់សក្ខីកម្មទៀតហើយ។

[១៥:៥៨:០០]

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ឃើញថា ដល់ទីសមល្មមនឹងពេលសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាក ផ្អាកកិច្ចដំណើរការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ហើយនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-488។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សី សៅ សារុន ត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ហើយនិងសាក្សី TCW-488 ដែលជាសាក្សីបម្រុងថ្ងៃនេះ ជូនត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យនាំសាក្សី TCW-488 មកកាន់បន្ទប់សវនាការ កន្លែងផ្តល់សក្ខីកម្មនេះ នៅថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយដោយឡែក លោក អៀង សារី ប្រសិនបើគាត់បង្ហាញជំហរច្បាស់លាស់ក្នុងការដាក់ពាក្យសុំ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ បានមុនពេលអង្គជំនុំជម្រះ-- មុនពេលម៉ោងប្រាំបួន ដែលអង្គជំនុំជម្រះចាប់ផ្តើមបើកសវនាការនោះ គឺសូមរក្សាទុកគាត់នៅកន្លែងបន្ទប់ឃុំខ្លួនខាងក្រោម ដើម្បីឲ្យគាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០០ នាទី)*